Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា



## មាគ៌ាឆ្ពោះទៅការស្តារឡើងវិញ

### អត្ថបទផ្តោតពិសេស
### ការផ្តល់អត្ថប្រយោជន៍សង្គមពីរដ្ឋាភិបាលជូនប្រជាពលរដ្ឋ

ខែ មិថុនា ឆ្នាំ 2021

ក្រុមធនាគារពិភពលោក



# បច្ចុប្បន្នភាព
# សេដ្ឋកិច្ច
# កម្ពុជា

ខែ មិថុនា ឆ្នាំ 2021

## មាគ៌ាឆ្ពោះទៅ
## ការស្តារឡើងវិញ

ក្រុមធនាគារពិភពលោក

# មាតិកា


**សេចក្តីថ្លែងអំណរគុណ ..... 7**

**អក្សរកាត់ ..... 8**

**សេចក្តីសង្ខេប ..... 9**

**ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ ..... 16**

**ការអភិវឌ្ឍថ្មីៗ ..... 16**

- ទោះបីមានការប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទប់ស្កាត់ជំងឺកូវីដ 19 ក្តី ក៏ការផ្ទុះការឆ្លងក្នុងសហគមន៍នៅតែកើតមានសាជាថ្មី ..... 16
- កម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 បានចាប់ផ្តើម ..... 16
- ទោះជាមានការទប់ស្កាត់មិនដូចគ្នាលើជំងឺកូវីដ 19 ក្តី ក៏សេដ្ឋកិច្ចក្នុងតំបន់បានងើបឡើងវិញ ..... 17
- ការនាំចេញកំពុងងើបឡើងវិញជាបណ្តើរៗ ដោយសារតែកំណើនតម្រូវការពិភពលោក ..... 17
- ការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាទៅសហរដ្ឋអាមេរិក កើនឡើង ..... 20
- លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសចាប់ផ្តើមងើបឡើងវិញ ..... 20
- កំណែទម្រង់បរិយាកាសវិនិយោគនៅតែជួបប្រទះបញ្ហា ..... 21
- វិស័យសំណង់បន្តថយចុះ ដោយសារការផ្គត់ផ្គង់លើសពីតម្រូវការ ..... 23
- ផលិតកម្មកសិកម្មនៅតែមានភាពធន់ ..... 24
- ការប្រែប្រួលតម្លៃក្នុងស្រុកធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មកសិកម្ម ..... 24
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ត្រូវបានរំពឹងថានឹងជួយជំរុញផលិតកម្មកសិកម្ម ..... 25
- សាជីវកម្មធានាឥណទានដំបូងគេក្រោមការគ្រប់គ្រងដោយរដ្ឋ ត្រូវបានបង្កើតឡើង ..... 25
- កំណើនតម្លៃដឹកជញ្ជូនតាមសមុទ្របានពន្យឺតការនាំចេញអង្កររបស់កម្ពុជា ..... 25
- ការបិទខ្ទប់ដែលមិនធ្លាប់មាន បានប៉ះពាល់ថែមទៀតលើឧស្សាហកម្មទេសចរណ៍ ..... 26
- ការថយចុះនៃការប្រើប្រាស់រងផលប៉ះពាល់បន្ថែមទៀតដោយសារការបិទខ្ទប់នាពេលថ្មីនេះ ..... 26
- អតិផរណាថយចុះបន្ថែមទៀតដោយសារតម្លៃអាហារថយចុះ ..... 27
- កំណើនការនាំចេញប្រភេទផលិតផលថ្មីបានជួយមួយផ្នែកដល់ការរក្សាស្ថិរភាពនៃស្ថានភាពក្រៅប្រទេស ..... 27
- គោលនយោបាយរូបិយវត្ថុបែបបន្ធូរបន្ថយនៅតែបន្ត ..... 28
- កំណើនរូបិយវត្ថុទូលាយនៅតែរឹងមាំ ដោយសារតែកំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេស ..... 28
- កំណើនឥណទាន និងប្រាក់បញ្ញើក្នុងស្រុក មានស្ថិរភាព ដោយទទួលបានទំនុកចិត្តកាន់តែច្រើន ..... 29
- ភាពក្រីក្រត្រូវបានប៉ាន់ស្មានថាកើនឡើង បើទោះជាមានការឆ្លើយតបរបស់រដ្ឋាភិបាល ..... 30
- ការប្រមូលចំណូល មានភាពយឺតយ៉ាវដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ 19 ..... 30
- កញ្ចប់ថវិកាអន្តរាគមន៍របស់រដ្ឋាភិបាលមានចំនួន 719 លានដុល្លារ ..... 32
- ឱនភាពជារួមនៅតែទទួលហិរញ្ញប្បទានពីប្រាក់សន្សំចរន្ត និងកម្ចីខាងក្រៅ ..... 33
- កំណើនមូលធនដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 បានបង្កើនចំណាយមូលធនសរុប ..... 34
- បំណុលសាធារណៈរបស់កម្ពុជាបានកើនឡើង ប៉ុន្តែហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប ..... 35
- កាលពីឆ្នាំមុន ធនាគារអភិវឌ្ឍន៍អាស៊ីជាភាគីផ្តល់កម្ចីច្រើនជាងគេ ..... 36
- ខុសពីប្រទេសជិតខាង បំណុលសាធារណៈរបស់កម្ពុជាជាបំណុលខាងក្រៅទាំងស្រុង ..... 36
- ទស្សនវិស័យ ..... 37
- បញ្ហាប្រឈម និងហានិភ័យ ..... 38
- ជម្រើសគោលនយោបាយ ..... 40

**អត្ថបទផ្តោតពិសេស៖ ការផ្តល់អត្ថប្រយោជន៍សង្គមពីរដ្ឋាភិបាលជូនប្រជាពលរដ្ឋ (G2P) ..... 44**

**សេចក្តីផ្តើម ..... 44**

**ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការរាតត្បាតជាសកលនៃជំងឺកូវីដ 19 ..... 44**

**កម្មវិធីជំនួយសង្គម ៖ យន្តការបើកប្រាក់ ..... 46**

**អនុសាសន៍គោលនយោបាយ ..... 52**

- កែលម្អទិដ្ឋភាពរួមអំពីជំនួយសង្គមនៅកម្ពុជា ..... 52
- កែលម្អជំនួយសាច់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋនៅក្នុងសេណារីយ៉ូបច្ចុប្បន្ន ..... 52
- កែលម្អការផ្តល់ជំនួយសាច់ប្រាក់របស់រដ្ឋាភិបាល ៖ សេណារីយ៉ូដែលអាចកើតមាននាពេលអនាគត ..... 53
- កម្មវិធីជំនួយសាច់ប្រាក់រដ្ឋាភិបាលនៅប្រទេសកម្ពុជា ៖ អភិក្រមជាយុទ្ធសាស្ត្រសម្រាប់កែទម្រង់ ..... 54

**ឧបសម្ព័ន្ធ ៖ សូចនាករសំខាន់ៗ ..... 56**

**គន្ថនិទ្ទេស ..... 57**

# ប្រអប់

**ប្រអប់ 1 ៖** ការអភិវឌ្ឍសេដ្ឋកិច្ចសកល និងទស្សនវិស័យ ........ 18
**ប្រអប់ 2 ៖** កត្តាជំរុញកំណើនសេដ្ឋកិច្ចរឹងមាំរបស់វៀតណាម ........ 22
**ប្រអប់ 3 ៖** ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ៖ លទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ ........ 31
**ប្រអប់ S1 ៖** ការឆ្លើយតបផ្នែកគាំពារសង្គមរបស់កម្ពុជាចំពោះវិបត្តិជំងឺកូវីដ 19 ........ 45
**ប្រអប់ S2 ៖** ប្រព័ន្ធទូទាត់សម្រាប់អតិថិជនទូទៅនៅកម្ពុជា ........ 49
**ប្រអប់ S3 ៖** ទីផ្សារសម្រាប់សេវាទូទាត់សម្រាប់អតិថិជនទូទៅនៅកម្ពុជា ........ 50
**ប្រអប់ S4 ៖** ករណីសិក្សារបស់ប្រទេសហ្សំដង់៖ ការបិទខ្ទប់មិនមែនជាការបិទទាំងស្រុងឡើយ ........ 51

# រូប

**រូប ES.1៖** ទិដ្ឋភាពរួមស្តីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា ........ 14
**រូប 1 ៖** ករណីវីរុសក្លូណាកើនឡើង ........ 16
**រូប 2 ៖** ការចាក់វ៉ាក់សាំងបង្ការកើនឡើង ........ 16
**រូប 3 ៖** សន្ទស្សន៍ស្តីពីនិន្នាការចល័តភាព Apple របស់កម្ពុជា បានថយចុះ ........ 16
**រូប 4 ៖** ការនាំចេញទំនិញក្នុងតំបន់កើនឡើង ........ 19
**រូប 5 ៖** ការថយចុះចំណែកនៃការនាំចេញសម្លៀកបំពាក់ធៀបនឹងការនាំចេញទំនិញសរុប ........ 19
**រូប 6 ៖** ការនាំចេញរបស់កម្ពុជាងើបឡើងវិញ ........ 19
**រូប 7 ៖** ទំហំទឹកប្រាក់នៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តកើនឡើង ........ 21
**រូប 8 ៖** ការកើនឡើងនៃគម្រោងវិនិយោគផ្ទាល់ពីបរទេស ប្រមូលផ្តុំក្នុងឧស្សាហកម្មក្រៅពីសម្លៀកបំពាក់ ........ 21
**រូប 9 ៖** លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជា និងវៀតណាម មាននិន្នាការស្រដៀងគ្នា ........ 21
**រូប 10 ៖** តម្លៃអចលនទ្រព្យថយចុះ ........ 23
**រូប 11 ៖** ការនាំចូលសម្ភារសំណង់សំខាន់ៗថយចុះ ........ 23
**រូប 12 ៖** ចំនួនលិខិតអនុញ្ញាតការសាងសង់ដែលត្រូវបានអនុម័តថយចុះ ........ 23
**រូប 13 ៖** ផលិតកម្មស្រូវវស្សាមានភាពថយចុះបន្តិច ........ 24
**រូប 14 ៖** ទិន្នផលស្រូវប្រាំងប្រែប្រួល ........ 24
**រូប 15 ៖** តម្លៃទំនិញកសិកម្មក្នុងស្រុកប្រែប្រួល ........ 24
**រូប 16 ៖** ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំណូលពីការចូលទស្សនាតំបន់អង្គរធ្លាក់ចុះ ........ 26
**រូប 17 ៖** ការនាំចូលទំនិញប្រើប្រាស់ងើបឡើងវិញយឺតៗ ........ 26
**រូប 18 ៖** អតិផរណាថយចុះបន្ថែមទៀត ........ 26
**រូប 19 ៖** អត្រាប្តូរប្រាក់ល្មមីណល មានស្ថិរភាពក្នុងរង្វង់ ±2 ........ 27
**រូប 20 ៖** លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមានស្ថិរភាព ........ 27
**រូប 21 ៖** ទុនបម្រុងអន្តរជាតិសរុបកើនឡើង ........ 27
**រូប 22 ៖** កំណើនរូបិយវត្ថុទូលាយងើបឡើងវិញ ........ 29
**រូប 23 ៖** ឥណទាន និងបញ្ញើក្នុងស្រុកកើនឡើង ........ 29
**រូប 24 ៖** វិស័យសំណង់រួមចំណែកកាន់តែច្រើនដល់កំណើនឥណទាន ........ 29
**រូប 25 ៖** ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលថយចុះ ........ 32
**រូប 26 ៖** ចំណាយរបស់រដ្ឋាភិបាលមានភាពយឺតយ៉ាវ ........ 32

រូប


រូប 27 ៖ អត្ថប្រយោជន៍សង្គម និងជំនួយឥតសំណងកើនឡើង ..... 32
រូប 28 ៖ ឱនភាពសារពើពន្ធជារួមរបស់រដ្ឋាភិបាលកើនឡើង ..... 33
រូប 29 ៖ កម្ចីបរទេសផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធ ..... 33
រូប 30 ៖ ប្រាក់សន្សំរបស់រដ្ឋាភិបាលនៅតែមានស្ថានភាពល្អប្រសើរ ..... 33
រូប 31 ៖ ការវិនិយោគសាធារណៈកើនឡើង ..... 34
រូប 32 ៖ ការវិនិយោគសរុបរបស់កម្ពុជាលើទ្រព្យសកម្មក្រៅពីហិរញ្ញវត្ថុមានទំហំធំ ..... 34
រូប 33 ៖ ការវិនិយោគលើមូលធនកើនឡើង ..... 34
រូប 34 ៖ បំណុលសាធារណៈកើនឡើង ..... 35
រូប 35 ៖ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើចិនជាឥណទាយកផ្លូវការ ..... 35
រូប 36 ៖ ខុសពីប្រទេសជិតខាង កម្ពុជាគ្មានបំណុលសាធារណៈក្នុងស្រុកនោះទេ ..... 35
រូប B1.1៖ តម្លៃទំនិញ ..... 18
រូប B1.2៖ ករណីឆ្លងថ្មីប្រចាំសប្តាហ៍នៃជំងឺកូវីដ 19 ជាសកល ..... 18
រូប B2.1៖ ការនាំចេញរបស់វៀតណាមបានធ្វើពិពិធកម្មដែលភាគច្រើនជាផលិតផលមានតម្លៃបន្ថែមខ្ពស់ ..... 22
រូប B2.2៖ ការនាំចេញរបស់កម្ពុជានៅតែពឹងផ្អែកខ្លាំងលើសម្លៀកបំពាក់ ..... 22
រូប B2.3៖ ការនាំចេញរបស់វៀតណាម ដែលជំរុញដោយសម្ភារៈអេឡិចត្រូនិក ដំណើរការយ៉ាងល្អ ..... 22
រូប B3.1៖ ការប្រែប្រួលប្រាក់ចំណូល បែងចែកតាមប្រភព ចាប់ពីខែ វិច្ឆិកា ឆ្នាំ 2019 (ភាគរយ) ..... 31
រូប B3.2៖ ការចូលរួមរបស់កុមារនៅក្នុងការអប់រំ ឬសកម្មភាពរៀនសូត្រក្នុងរយៈពេល 7 ថ្ងៃកន្លងមក (ភាគរយ) ..... 31
រូប S1៖ សុខុមាលភាពរបស់គ្រួសារមានការកើនឡើង នៅពេលដែលចំនួនប្រាក់ឧបត្ថម្ភសង្គ្រោះដែលពួកគេបានទទួល កាន់តែមានចំនួនច្រើនឡើង ..... 46
រូប S2៖ ដំណើរការចុះឈ្មោះដើម្បីទទួលបានប្រាក់ឧបត្ថម្ភ និងដំណើរការបើកប្រាក់ឧបត្ថម្ភ ..... 47
រូប S3៖ រយៈពេលធ្វើដំណើរជាមធ្យម ..... 47
រូប S4៖ ភាគរយគ្រួសារដែលធ្វើដំណើរជាមធ្យមជាង 45 នាទី ..... 47
រូប S5៖ ភាគរយមនុស្សពេញវ័យដែលមានគណនីផ្លូវការ ..... 48
រូប S6៖ ភាគរយប្រជាជនដែលមានគណនីជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ឬអ្នកផ្តល់សេវាបើកប្រាក់ចល័ត ..... 48
រូប S7៖ ភាគរយមនុស្សពេញវ័យដែលបានធ្វើការទូទាត់តាមប្រព័ន្ធឌីជីថល ..... 48
រូប S8៖ តើអ្នកមានគណនីសម្រាប់ទូទាត់ដែរឬទេ? ( ភាគរយ) ..... 49
រូប S9៖ តើអ្នកប្រើមធ្យោបាយអ្វីក្រៅពីសាច់ប្រាក់ដើម្បីធ្វើការទូទាត់ដែរឬទេ? ..... 49


# តារាង


តារាង 1 ៖ បំណុល (លានដុល្លារ) និងការរួមចំណែកដល់កំណើននៃការទូទាត់បំណុល (ភាគរយ) ..... 36
តារាង 2 ៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច (សេណារីយ៉ូគោល) ..... 37
តារាង 3 ៖ ការសន្មតក្រោមសេណារីយ៉ូគោល និងសេណារីយ៉ូទាប ..... 39

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ មិថុនា ឆ្នាំ 2021 (CEU) ត្រូវបានរៀបចំឡើងដោយលោក លី សូដេត ដោយមានការរួមចំណែកពីលោក Marcro Nicoli លោក Maheshwor Shrestha លោក Robert J. Palacios លោក Biagio Bossone លោក តុង គឹមស៊ុន លោក Wendy Karamba និងលោកស្រី Ekaterine Vashakmadze។ លោកស្រី ហៀវ ចាន់កេសី ជាជំនួយការផ្នែកស្រាវជ្រាវ។ លោក ប៊ូ សារឿន បានជួយលើការងារផ្សព្វផ្សាយតាមសារព័ត៌មាន ការបង្ហាញតាមគេហទំព័រ និងពិធីផ្សព្វផ្សាយរបាយការណ៍នេះ។

ក្រុមការងារបានធ្វើការក្រោមការណែនាំរួមរបស់ លោក Deepak Mishra។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះការណែនាំ និងយោបល់របស់លោកស្រី Inguna Dobraja លោកស្រី Mariam Sherman និងលោក Hassan Zaman។ សហការីមួយចំនួនរបស់ធនាគារពិភពលោក គឺលោក Aaditya Mattoo លោក Ergys Islamaj លោក Duong Le និងលោក Daisuke Fukuzawa បានផ្តល់យោបល់លើសេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នេះ។

ក្រុមការងារសូមអរគុណដល់អាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាសម្រាប់កិច្ចសហការ និងការគាំទ្រនាពេលកន្លងមក។ របាយការណ៍នេះក៏ទទួលបានផលប្រយោជន៍ពីការណែនាំ យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

របាយការណ៍នេះត្រូវបានរៀបចំឡើងចំនួនពីរដងក្នុងមួយឆ្នាំ និងផ្តល់បច្ចុប្បន្នភាព ស្តីពីការអភិវឌ្ឍផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ ក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើង www.worldbank.org/cambodia។

ដើម្បីស្ថិតនៅក្នុងបញ្ជីស្ថាប័នដែលទទួលបានរបាយការណ៍នេះតាមអ៊ីមែល និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធផ្សេងទៀត សូមទាក់ទងលោកស្រី ហៀវ ចាន់កេសី (cheav@worldbank.org)។ បើមានសំណួរពីខ្លឹមសារនៃរបាយការណ៍នេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

របកគំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋានដែលមានក្នុងរបាយការណ៍នេះ មិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។ ធនាគារពិភពលោកមិនធានាទៅលើភាពត្រឹមត្រូវនៃទិន្នន័យដែលមានក្នុងឯកសារនេះទេ។

# អក្សរកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| **BRGS** | គម្រោងធានាឲ្យមានការស្តារអាជីវកម្មឡើងវិញ |
| **CCFTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **CGCC** | សាជីវកម្មធានាឥណទានកម្ពុជា |
| **COVID-19** | ជំងឺកូវីដ 19 |
| **CR** | ប្រាក់រៀលខ្មែរ |
| **CSS** | ប្រព័ន្ធ CSS |
| **DSA** | ការវិភាគលើនិរន្តរភាពបំណុល |
| **EAP** | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EBA** | អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ |
| **EC** | គណៈកម្មការអឺរ៉ុប |
| **EU** | សហភាពអឺរ៉ុប |
| **FDI** | ការវិនិយោគផ្ទាល់ពីបរទេស |
| **FOB** | មិនគិតថ្លៃរហូតដល់ដឹកទំនិញដល់កប៉ាល |
| **FTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| **G2P** | រដ្ឋាភិបាលទៅប្រជាពលរដ្ឋ |
| **GDP** | ផលិតផលក្នុងស្រុកសរុប (ផសស) |
| **GFT** | សម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ |
| **GPPs** | កម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល |
| **GSP** | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ |
| **HFPSH** | ការអង្កេតគ្រួសារតាមទូរស័ព្ទ |
| **IDPoor** | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| **MDI** | គ្រឹះស្ថានទទួលប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុ |
| **NBC** | ធនាគារជាតិនៃកម្ពុជា |
| **NPIs** | ការអន្តរាគមក្រៅពីឱសថ |
| **NPL** | កម្ចីមិនដំណើរការ |
| **NPS** | ប្រព័ន្ធទូទាត់ថ្នាក់ជាតិ |
| **P2G** | ប្រជាពលរដ្ឋទៅរដ្ឋាភិបាល |
| **PIMSRS** | យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ |
| **PSI** | គ្រឹះស្ថានផ្តល់សេវាទូទាត់ |
| **RCEP** | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RPS** | ប្រព័ន្ធទូទាត់សេវាអតិថិជនទូទៅ |
| **SMEs** | សហគ្រាសធុនតូច និងមធ្យម |
| **UK** | ចក្រភពអង់គ្លេស |
| **U.S.** | សហរដ្ឋអាមេរិក |
| **US$** | ដុល្លារអាមេរិក |
| **y/y** | ធៀបនឹងឆ្នាំមុន |

# សេចក្ដីសង្ខេប

## ការអភិវឌ្ឍថ្មីៗ

**សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញជាបណ្ដើរៗ បន្ទាប់ពីថយចុះ 3.1 ភាគរយនៅក្នុងឆ្នាំ 2020។** ទោះជាយ៉ាងណាក៏ដោយ ការងើបឡើងវិញនេះមានរបាយមិនស្មើគ្នា ដោយផ្នែក និងងាយប្រែប្រួល មួយផ្នែកដោយសារតែការដាក់ចេញជាថ្មីនូវវិធានការបិទខ្ទប់ក្នុងប្រទេស ដែលបណ្ដាលមកពីការផ្ទុះការឆ្លងជំងឺកូវីដ 19 នាពេលថ្មីៗនេះ។ មិនខុសពីបណ្ដាប្រទេសជាច្រើនក្នុងតំបន់ដែរ កម្ពុជាទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារតែវិបត្តិតម្រូវការសកល និងការបិទអាជីវកម្មពាក់ព័ន្ធនឹងជំងឺកូវីដ 19 ដែលបង្កការប៉ះពាល់ខុសៗគ្នាលើវិស័យផ្សេងៗ ដូចដែលបានព្យាករណ៍ទុក។ កសិកម្មជាវិស័យដែលមានភាពធន់ក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 នេះ។ លើសពីនេះទៀត វិស័យនេះត្រូវបានជំរុញដោយកំណើននៃការវិនិយោគ ដោយសារតែភាពវិជ្ជមាននៃកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) ដែលត្រូវបានចុះហត្ថលេខានាពេលថ្មីៗនេះ និងកម្មវិធីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងថ្នាក់តំបន់ (RCEP)។ កាលពីឆ្នាំមុន វិស័យកម្មន្តសាលបានថយចុះខ្លាំង ប៉ុន្តែបានងើបឡើងវិញបន្តិចម្ដងៗចាប់ពីពេលនោះមក ព្រោះថា វិស័យនេះបានកែសម្រួលទៅនឹងការប្រែប្រួលស្ថានភាពនៅក្រៅប្រទេស។ ការថយចុះនៃវិស័យកម្មន្តសាលបែបប្រពៃណី គឺ សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ត្រូវបានប៉ះប៉ូវមួយផ្នែកដោយកំណើនវិស័យកម្មន្តសាលដែលទើបតែងើបឡើង (សម្ភារអគ្គិសនី ឧបករណ៍អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត រួមទាំងកង់) និងឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម។ ផ្នែកមួយចំនួននៃវិស័យសេវាកម្ម ដូចជា ការស្នាក់នៅ ភោជនីយដ្ឋាន និងការដឹកជញ្ជូន នៅតែរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារតែការថយចុះនៃទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ បើទោះជាពាណិជ្ជកម្មលក់ដុំ និងលក់រាយ បានងើបឡើងជាបណ្ដើរៗ ដោយទទួលបានការគាំទ្រពីកំណើនជាបណ្ដើរៗនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។

**រដ្ឋាភិបាលមានលទ្ធភាពផ្ដល់ជំនួយបន្ថែមផ្នែកសារពើពន្ធ និងរូបិយវត្ថុ នៅពេលដែលជំងឺរាតត្បាតនេះកាន់តែឡើងខ្លាំង។** ថវិកាសម្រាប់ជំនួយសង្គ្រោះ និងការអន្តរាគមស្ដារឡើងវិញ ដែលពាក់ព័ន្ធនឹងជំងឺកូវីដ 19 នៅឆ្នាំ 2021 មានចំនួន 719 លានដុល្លារ ដោយថវិកានេះមានចំនួន 823 លានដុល្លារនៅឆ្នាំ 2020។ ធនាគារជាតិបានបន្តអនុវត្តគោលនយោបាយបន្ធូរបន្ថយផ្នែករូបិយវត្ថុរបស់ខ្លួន។ ធនាគារជាតិនៃកម្ពុជាបានសម្រេចក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដែលបានធ្វើឡើងនៅខែ កុម្ភៈ ឆ្នាំ 2021 ដូចតទៅ គឺ ទី 1 បន្តរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ ដោយធ្វើអន្តរាគមន៍ទីផ្សារប្ដូរប្រាក់ ទី 2 ផ្ដល់សន្ទនីយភាពប្រាក់រៀលតាមរយៈប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា ដោយផ្អែកតាមអត្រាប្ដូរប្រាក់រៀល និងលក្ខខណ្ឌសន្ទនីយភាព និងទី 3 រក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចត្រឹម 7 ភាគរយ ទាំងសម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិករហូតដល់បំណាច់ឆមាសទីមួយឆ្នាំ 2021 និងទៅតាមភាពចាំបាច់ជាក់ស្ដែង។ ក្រោយមកទៀត នៅខែឧសភា ឆ្នាំ 2021 ធនាគារកណ្ដាលបានដាក់ចេញនូវវិធានការសម្រួលរូបិយវត្ថុជុំទីបី ដែលរួមមាន (1) ការសម្រេចរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចត្រឹម 7 ភាគរយ ទាំងសម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក រហូតដល់ពេលជូនដំណឹងនៅពេលក្រោយ និង (2) ការអនុញ្ញាតឲ្យវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ បន្តកែសម្រួលកម្ចីរហូតដល់បំណាច់ឆ្នាំ 2021។ កម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 បានចាប់ផ្ដើមនៅខែ កុម្ភៈ ឆ្នាំ 2021 និងបានបង្កើនការចាក់យ៉ាងឆាប់រហ័ស។ ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ត្រូវបានដាក់ចេញនៅខែ ឧសភា ឆ្នាំ 2021។

**ការនាំចេញទំនិញបានងើបឡើងវិញ។** ការនាំចេញទំនិញ (មិនគិតការនាំចេញមាស) កើន 12.2 ភាគរយ នៅក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021។ ទោះបីជាថ្លៃដឹកជញ្ជូនបានកើនឡើងក្ដី ការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ដែលថយចុះយ៉ាងខ្លាំងនៅខែ មករា ឆ្នាំ 2021 ដោយថយចុះ 13.2 ភាគរយធៀបនឹងឆ្នាំមុន បានងើបឡើងវិញចាប់ពីពេលនោះមក ដោយការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ បានកើនចំនួន 10.2 នៅខែ មីនា ឆ្នាំ 2021 និងកើនចំនួន 27.8 ភាគរយ នៅខែ មេសា ឆ្នាំ 2021។ នៅរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021 ការនាំចេញកង់កើន 32.3 ភាគរយ ក្នុងអំឡុងពេលដូចគ្នានេះ ការនាំចេញយានយន្តសម្ភារអគ្គិសនីនិងឧបករណ៍អេឡិចត្រូនិកបញ្ចូលគ្នា កើនចំនួន 16.4 ភាគរយ។ ការនាំចេញផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ លែងជាផលិតផលភាគច្រើននៃទំនិញនាំចេញទៀតហើយ។ ចំណែកនៃការនាំចេញសម្លៀកបំពាក់នៃទំនិញនាំចេញសរុប (មិនរាប់បញ្ចូលមាស) បានថយចុះមកត្រឹម 45.6 ភាគរយនៅបួនខែដំបូងក្នុងឆ្នាំ 2021 ថយពី 52.2 ភាគរយនៅឆ្នាំ 2020 (និង 57.6 ភាគរយនៅឆ្នាំ 2019)។ យ៉ាងណាក៏ដោយ វិស័យសំណង់ និងអចលនទ្រព្យ នៅតែបន្តថយចុះ។ នៅក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021 ទឹកប្រាក់នៃគម្រោងសាងសង់ដែលត្រូវបានអនុម័ត បានថយចុះ 41.5 ភាគរយ នៅខណៈដែលការនាំចូលស៊ីម៉ង់ត៍ថយចុះ 19.2 ភាគរយ។ ការនាំចូលដែកថែប និងបរិក្ខារត្រជាក់ ដូចជា ម៉ាស៊ីនត្រជាក់ កើនឡើង ដោយការនាំចូលដែកថែបកើនឡើង 5.4 ភាគរយ ចំណែកការនាំចូលបរិក្ខារត្រជាក់វិញ កើនឡើង 24.1 ភាគរយ។

**លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសដែលមានភាពរឹងមាំ បានជួយរក្សាវិស័យនាំចេញ។** នៅឆ្នាំ 2020 លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមានចំនួន 3.4 ពាន់លានដុល្លារ ឬស្មើនឹង 13.6 ភាគរយនៃ ផសស ធៀបនឹងចំនួន 3.5 ពាន់លានដុល្លារនៅឆ្នាំ 2019។ នៅឆ្នាំ 2020 ឱនភាពគណនីចរន្តទទួលបានហិរញ្ញប្បទានទាំងស្រុងពីការវិនិយោគផ្ទាល់ពីបរទេស ខណៈដែលទុនបម្រុងអន្តរជាតិសរុបបន្តកើនឡើង មានចំនួន 21.5 ពាន់លានដុល្លារ ឬស្មើនឹងការនាំចូលរយៈពេលជាង 10 ខែ។ ទោះបីជាតម្លៃប្រេងលក់រាយកើនឡើងក្តី ក៏អតិផរណានៅតែនៅរក្សាលំនឹង ដោយថយចុះមកត្រឹម 1.7 ភាគរយនៅខែ កុម្ភៈ ឆ្នាំ 2021 ពី 2.9 ភាគរយនៅបំណាច់ឆ្នាំ 2020 នេះមួយផ្នែកដោយសារតែការថយចុះនៃតម្លៃម្ហូបអាហារ និងស្ថិរភាពនៃអត្រាប្តូរប្រាក់ (អត្រា 4,048 រៀលក្នុងមួយដុល្លារអាមេរិកនៅចុងខែ មេសា ឆ្នាំ 2021 ធៀបនឹងអត្រា 4,042 រៀលក្នុងមួយដុល្លារអាមេរិកនៅបំណាច់ឆ្នាំ 2020)។

**លក្ខខណ្ឌរូបិយវត្ថុនៅតែមានភាពបន្ធូរបន្ថយ។** កំណើនរូបិយវត្ថុទូលាយនៅតែមិនប្រែប្រួល ដោយកើនចំនួន 15.2 ភាគរយនៅខែ កុម្ភៈ ឆ្នាំ 2021។ ដោយសារតែគោលនយោបាយបន្ធូរបន្ថយផ្នែករូបិយវត្ថុរបស់ធនាគារកណ្តាល ការផ្តល់ឥណទានក្នុងស្រុកដល់វិស័យឯកជន កើនឡើងចំនួន 19.5 ភាគរយនៅខែ កុម្ភៈ ឆ្នាំ 2021 ធៀបនឹងកំណើន 17.7 ភាគរយនៅបំណាច់ឆ្នាំ 2020 ដោយសារតែសកម្មភាពសេដ្ឋកិច្ចមានភាពប្រសើរឡើង។ ផលធៀបឥណទាន-ផសស កើនពី 114.2 ភាគរយនៅឆ្នាំ 2019 មក 142.2 ភាគរយនៅឆ្នាំ 2020។ កំណើនប្រាក់បញ្ញើនៅតែបន្ត ដោយកើន 15.4 ភាគរយនៅខែ កុម្ភៈ ឆ្នាំ 2021 ធៀបនឹងកំណើន 15.6 ភាគរយនៅបំណាច់ឆ្នាំ 2020 ដែលបង្ហាញពីភាពរឹងមាំនៃលំហូរមូលធន។

**ឱនភាពសារពើពន្ធជារួមត្រូវបានប៉ាន់ស្មានថាបានកើនឡើង ប៉ុន្តែនៅតែមានកម្រិតទាបស្មើនឹង 2.7 ភាគរយនៃ ផសស នៅឆ្នាំ 2020។** ទោះបីជាមានការកើនឡើងដែលមិនធ្លាប់មាននៃការចំណាយពាក់ព័ន្ធនឹងជំងឺកូវីដ 19 លើកម្មវិធីជំនួយសង្គម ដែលត្រូវបានប៉ាន់ស្មានថាមានចំនួន 4 ភាគរយនៃ ផសស ក្តី ក៏រដ្ឋាភិបាលបានខិតខំគ្រប់គ្រងការចំណាយតាមរយៈការកាត់បន្ថយការចំណាយលើទំនិញ និងសេវា និងការចំណាយមិនអាទិភាពផ្សេងទៀត។ ដូច្នេះ កំណើនចំណាយសរុបត្រូវបានប៉ាន់ស្មានថាមានកម្រិតទាប ដោយកើនដល់ 26.8 ភាគរយនៃ ផសស នៅឆ្នាំ 2020 កើនពី 25.5 ភាគរយនៃ ផសស នៅឆ្នាំ 2019។ លើសពីនេះទៀត ផលប៉ះពាល់នៃជំងឺកូវីដ 19 លើប្រាក់ចំណូលក្នុងស្រុក ត្រូវបានកាត់បន្ថយដោយកំណើននៃពន្ធលើប្រាក់ចំណេញនៅឆ្នាំ 2019 ដែលត្រូវបានប្រមូលនៅខែ មេសា ឆ្នាំ 2020។

**ការឧបត្ថម្ភសាច់ប្រាក់ (ថ្មី) ជូនដល់គ្រួសារក្រីក្រ និងងាយរងគ្រោះកាន់តែត្រូវការខ្លាំង។** គិតត្រឹមខែ មករា ឆ្នាំ 2021 ប្រជាជនជាង 710,000 គ្រួសារ ឬ 19.5 ភាគរយនៃចំនួនគ្រួសារសរុប បានទទួលការឧបត្ថម្ភសាច់ប្រាក់ពីរដ្ឋាភិបាល។ សកម្មភាពការងារកំពុងបង្ហាញពីការងើបឡើងវិញបន្តិច។ យោងតាមការអង្កេតគ្រួសារ ភាគរយអ្នកឆ្លើយដែលកំពុងមានការងារធ្វើនៅខែ ធ្នូ ឆ្នាំ 2020 បានឈានទៅកម្រិតដើមដែលត្រូវបានកត់ត្រានៅខែ ឧសភា និងខែ សីហា ឆ្នាំ 2020 ប៉ុន្តែ នៅតែទាបជាងកម្រិតកាលពីអំឡុងពេលមុនមានវិបត្តិជំងឺកូវីដ 19។

## ទស្សនវិស័យ

**ទស្សនវិស័យកំណើនរបស់កម្ពុជានៅតែមិនច្បាស់លាស់ខ្លាំង** ព្រោះថា សណ្ឋាន និងល្បឿនជាក់ស្តែងនៃការងើបឡើងវិញនៅតែមិនច្បាស់លាស់ខ្លាំង ហើយភាគច្រើនពឹងផ្អែកលើការវិវត្តនៃវីរុសកូរ៉ូណា និងល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺនេះ។ ដូច្នេះ យើងលើកយកសេណារីយ៉ូពីរមកបង្ហាញ។ ទីមួយ គឺសេណារីយ៉ូគោលដែលផ្អែកលើការសន្មតបែបសុទិដ្ឋិនិយមចំពោះការឆ្លងជំងឺនេះ និងការចាក់វ៉ាក់សាំង បង្ការ។ ទីពីរ គឺ សេណារីយ៉ូទាបដែលសន្មតពីហានិភ័យអវិជ្ជមានភាគច្រើន។

**ក្រោមសេណារីយ៉ូគោល សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើន 4 ភាគរយនៅឆ្នាំ 2021** ដែលគាំទ្រដោយការងើបឡើងវិញបណ្តើរៗនៃតម្រូវការក្នុងស្រុក ក្រោយពីចាក់វ៉ាក់សាំងបង្ការរួច និងកំណើននៃតម្រូវការខាងក្រៅ និងលំហូរចូលមូលធន។ ការព្យាករនេះសន្មតថា ទំនុកចិត្តទីផ្សារបានវិលត្រឡប់មកឡើងវិញ នៅខណៈដែលការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍នាពេលថ្មីៗនេះ ដែលបានចាប់ផ្តើមនៅខែ កុម្ភៈ ឆ្នាំ 2021 នៅតែអាចគ្រប់គ្រងបាន ដែលនាំឲ្យមានការបន្ធូរបន្ថយវិធានការបិទខ្ទប់ជាដំណាក់កាលៗ ដោយមិនបង្កផលប៉ះពាល់ខ្លាំងក្នុងរយៈពេលមធ្យម និងរយៈពេលវែង លើវិស័យសាជីវកម្ម ឬវិស័យធនាគារឡើយ។ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនឹងវិលទៅរកភាពប្រក្រតីវិញ។ ក្រោមសេណារីយ៉ូគោលនេះ តាមការរំពឹងទុក អាជ្ញាធរកម្ពុជានឹងចាត់វិធានការផ្សេងៗក្នុងការទាក់ទាញការវិនិយោគបន្ថែម និងជំរុញពាណិជ្ជកម្មតាមរយៈការគ្រោងដាក់ចេញច្បាប់ស្តីពីការវិនិយោគ (ថ្មី) នៅឆមាសទីពីរក្នុងឆ្នាំ 2021 ដោយមានការជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលត្រូវបានចុះហត្ថលេខានាពេលថ្មីៗនេះ។ នៅក្នុងផែនការស្តារសេដ្ឋកិច្ចរបស់ខ្លួន កម្ពុជាខិតខំបង្កើនភាពប្រកួតប្រជែងតាមរយៈកំណែទម្រង់បរិយាកាសវិនិយោគ និងការទាញប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល។ អាជ្ញាធរកម្ពុជាព្យាយាមអនុវត្តគោលនយោបាយសារពើពន្ធគាំទ្រកំណើន ពេលសេដ្ឋកិច្ចមានវិបត្តិ ដោយបន្តអនុវត្តកម្មវិធីគាំពារសង្គម ទន្ទឹមនឹងការជំរុញការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានភាគច្រើនពីប្រាក់សន្សំចរន្តរបស់រដ្ឋាភិបាល។ សម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កើនឡើងយ៉ាងលឿន និងទំនងជាបន្តកើនឡើង ហើយអាជ្ញាធរកម្ពុជានឹងត្រូវពិចារណាលើជម្រើសនានាសម្រាប់ការពង្រឹងផ្នែកសារពើពន្ធ នៅពេលសេដ្ឋកិច្ចស្តារឡើងវិញ។

**ក្រោមសេណារីយ៉ូទាប សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើន 1.0 ភាគរយនៅឆ្នាំ 2021។** សេណារីយ៉ូទាបសន្មតថា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកនឹងកាន់តែដុនដាប ដោយសារតែការបិទខ្ទប់ជាច្រើនលើកច្រើនសា និងការរឹតត្បិតការធ្វើដំណើរ នៅពេលដែលកិច្ចខិតខំប្រឹងប្រែងក្នុងការរាំងខ្ទប់ការផ្ទុះជំងឺកូវីដ 19 មិនទទួលបានជោគជ័យ ដែលនាំឱ្យសេដ្ឋកិច្ចមិនអាចស្តារឡើងវិញបាន បើទោះជា ស្ថានភាពក្រៅប្រទេសមានភាពប្រសើរក្តី។ កិច្ចខិតខំប្រឹងប្រែងរាំងខ្ទប់ធ្វើឱ្យខាតបង់ធនធានសាធារណៈ នៅខណៈដែលការអនុវត្តកម្មវិធីចាក់ថ្នាំបង្ការត្រូវបានសន្មតថាមានល្បឿនយឺត។ ជាលទ្ធផល ទំនុកចិត្តទីផ្សារថយចុះ ដែលនាំឲ្យមានការថយចុះលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសច្រើន ខណៈដែលវិស័យកម្មន្តសាលសំខាន់ៗសម្រាប់នាំចេញ ដូចជា សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ត្រូវបានរាំងស្ទះដោយការបិទខ្ទប់ជាច្រើនលើកច្រើនសា និងទទួលរងផលប៉ះពាល់ពីការដកដោយផ្នែកនូវការអនុគ្រោះពន្ធ EBA និងការផុតកំណត់ជាបណ្តោះអាសន្ននៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP។ ឱនភាពសារពើពន្ធកើនឡើង ព្រោះថា ចំណាយកើនឡើង ខណៈដែលប្រាក់ចំណូលក្នុងស្រុកថយចុះយ៉ាងខ្លាំង ដោយសារតែសកម្មភាពសេដ្ឋកិច្ចអសកម្មរយៈពេលយូរ។ នៅខណៈពេលបន្តមានសម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កម្ចីខាងក្រៅ និងការថយចុះប្រាក់សន្សំចរន្តរបស់រដ្ឋាភិបាល កើនឡើង ដែលត្រូវការពេលវេលាកាន់តែច្រើនដើម្បីឱ្យរដ្ឋាភិបាលអាចស្តារផ្នែកសារពើពន្ធបាន។

**បន្ទាប់ពីវិបត្តិជំងឺកូវីដ 19 ផុតរលត់ទៅ សេដ្ឋកិច្ចកម្ពុជាអាចមានគន្លងថ្មី** (ធម្មតាតាមបែបគន្លងថ្មី) ដោយកើនឡើងកម្រិតទាបក្នុងរយៈពេលខ្លី។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងលើភ្ញៀវទេសចរ។ ទោះជាមានការងើបឡើងវិញនៃវិស័យទេសចរណ៍ក្នុងស្រុកក្រោយការបន្ធូរបន្ថយការបិទខ្ទប់ វិស័យទេសចរណ៍សកលត្រូវបានរំពឹងថានឹងមានកម្រិតទាបជាងកម្រិតមុនពេលមានវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2023។ ការស្តារឡើងវិញនៃសេដ្ឋកិច្ចសកល ដោយទទួលបានការគាំទ្រដោយការជួយជំរុញសេដ្ឋកិច្ចយ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក នឹងស្តារពាណិជ្ជកម្មទំនិញ និងអាចផ្តល់សន្ទុះខាងក្រៅដល់កំណើនជាមធ្យមចំនួន 1 ភាគរយ ប៉ុន្តែ វិស័យទេសចរណ៍សកលត្រូវបានរំពឹងថានៅតែមានកម្រិតទាបជាងកម្រិតមុនពេលមានវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2023 ដែលនឹងអូសបន្លាយការស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់បណ្តាប្រទេសដែលពឹងផ្អែកលើវិស័យទេសចរណ៍។ ការផ្លាស់ប្តូររចនាសម្ព័ន្ធ ដែលជំរុញដោយការធ្វើពិពិធកម្មគម្រោងវិនិយោគផ្ទាល់ពីបរទេស ដែលពីមុនមកប្រមូលផ្តុំភាគច្រើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ ក្រោយមកការនាំចេញទំនិញក្រៅពីសម្លៀកបំពាក់ និងទំនិញកសិកម្ម ហាក់លេចរូបរាងឡើង ដោយសម្រួលទៅនឹងការប្រែប្រួលស្ថានភាពតម្រូវការពីក្រៅប្រទេស និងក្នុងស្រុក។

## បញ្ហាប្រឈម និងហានិភ័យ

**ហានិភ័យចំពោះទស្សនៈវិស័យកំណើនរបស់កម្ពុជាបានកើនឡើង ដោយសារតែរលកនៃការផ្ទុះជំងឺកូវីដ 19 ចេះតែអូសបន្លាយពេល។** ថ្មីៗនេះ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកត្រូវបានបង្អាក់ដោយការដាក់ចេញជាថ្មីនូវវិធានការបិទខ្ទប់ឡើងវិញនៅពាក់កណ្តាលខែ មេសា ឆ្នាំ 2021។ ការបិទខ្ទប់តំបន់ប្រជុំជនធំជាងគេពីរនៅកម្ពុជា គឺ ទីក្រុងភ្នំពេញ និងក្រុងតាខ្មៅ ក្នុងខេត្តកណ្តាល ដែលជាទីក្រុងមានប្រជាជនច្រើនជាងគេបន្ទាប់ពីទីក្រុងភ្នំពេញ គឺជាការចាំបាច់ និងបានសង្គ្រោះជីវិតជាច្រើន ទោះបីជាធ្វើប៉ះពាល់ដល់សេដ្ឋកិច្ចក៏ដោយ។ អត្រាឆ្លងខ្ពស់នាពេលបច្ចុប្បន្ន ក៏គំរាមកំហែងដល់ប្រព័ន្ធសុខាភិបាលសាធារណៈផងដែរ។ រោងចក្រ និងអាជីវកម្ម ទទួលរងផលប៉ះពាល់ ខណៈដែលតម្រូវការក្នុងស្រុក ជាពិសេសតម្រូវការផលិតផលសេវា ដូចជាការធ្វើដំណើរក្នុងស្រុក ទេសចរណ៍ និងសេវាបដិសណ្ឋារកិច្ចរងផលប៉ះពាល់ជាថ្មីដោយសារការរឹតត្បិតការធ្វើដំណើរ ការបញ្ឈៀសការធ្វើដំណើរ និងការថយចុះប្រាក់ចំណូល។ ស្ថានភាពនេះនឹងធ្វើឱ្យមានកំណើនយឺត រហូតដល់មានការចាក់វ៉ាក់សាំងបង្ការបានច្រើនទូទៅ។

**បែបផែនកំណើនរបស់កម្ពុជា ដែលមានមូលដ្ឋាននាំចេញតូច និងផ្តោតលើផលិតផល និងទីផ្សារមួយចំនួនតូច មានភាពទន់ខ្សោយ អស់រយៈពេលជាច្រើនឆ្នាំតាំងពីមុនការប៉ះទង្គិចដោយវិបត្តិជំងឺកូវីដ 19នេះ។** ទោះជាកម្ពុជាមានឧស្សាហកម្មកាត់ដេរដែលមានភាពរឹងមាំ ប្រើប្រាស់កម្លាំងពលកម្មច្រើន និងផ្តោតលើការនាំចេញ អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ វិស័យកម្មន្តសាលនៅតែប្រតិបត្តិការនៅក្នុង “ផ្នែកកាត់ដេរធម្មតា” ដែលជាផ្នែកមានតម្លៃបន្ថែមទាបបំផុតនៅក្នុងសង្វាក់តម្លៃទាំងមូល។ ភាពប្រកួតប្រជែងក្រៅប្រទេសរបស់កម្ពុជា បានថយចុះមួយផ្នែកដោយសារតែកំណើនប្រាក់ឈ្នួលយ៉ាងឆាប់រហ័ស រួមទាំងសេដ្ឋកិច្ចដុល្លារូបនីយកម្ម និងបញ្ហាប្រឈមក្នុងការធ្វើធុរកិច្ច និងកំណែទម្រង់បរិយាកាសវិនិយោគ។ ទោះជាយ៉ាងណាក៏ដោយ ភាពងាយរងគ្រោះទាំងនេះត្រូវបានលាក់បាំងដោយកំណើនលំហូរចូលមូលធននៅអំឡុងមុនមានវិបត្តិជំងឺកូវីដ 19 ដើម្បីផ្តល់ហិរញ្ញប្បទានភាគច្រើនដល់វិស័យសំណង់ និងអចលនទ្រព្យ។ ដោយសារតែការដួលរលំនៃវិស័យទេសចរណ៍ ហើយកំណើនវិស័យសំណង់នៅទ្រឹង ជំងឺកូវីដ 19 លាតត្រដាងភាពទន់ខ្សោយផ្នែករចនាសម្ព័ន្ធរបស់កម្ពុជា។

**ទន្ទឹមនឹងភាពទន់ខ្សោយក្នុងស្រុក ស្ថានភាពសកលមិនច្បាស់លាស់ នៅតែជាហានិភ័យដ៏ធំចំពោះការស្តារសេដ្ឋកិច្ចកម្ពុជា។** ភាពយឺតយ៉ាវនៃការចែកចាយវ៉ាក់សាំងទូទាំងសកលលោក អាចនាំឱ្យជំងឺកូវីដ 19 នៅបន្តកើតមាន ដោយការផ្ទុះជំងឺនេះនឹងនាំឲ្យមានការបិទខ្ទប់កាន់តែច្រើន។ ការនាំចេញទំនិញរបស់កម្ពុជាអាចរងផលប៉ះពាល់បន្ថែមទៀតដោយការដកដោយផ្នែកនៃការអនុគ្រោះពន្ធ EBA និងការផុតកំណត់ជាបណ្តោះ

អាសន្ននៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP។ លើសពីនេះទៀត ប្រទេសកម្ពុជាកាន់តែពឹងផ្អែកលើប្រទេសចិនលើផ្នែកពាណិជ្ជកម្ម ការវិនិយោគ និងជំនួយអភិវឌ្ឍជាផ្លូវការ។ កំណើនឥណទានខ្ពស់ក្នុងវិស័យធនាគារ ជាពិសេស ការផ្ដល់ឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យ នៅតែជាហានិភ័យដ៏ធំចំពោះស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។

**បន្ទាប់ពីការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍ ដែលចាប់ផ្ដើមនៅថ្ងៃទី 20 ខែ កុម្ភៈ ឆ្នាំ 2021 កម្ពុជាមានករណីឆ្លងជំងឺកូវីដ 19 និងករណីស្លាប់ កើនឡើងយ៉ាងឆាប់រហ័ស។** គិតត្រឹមថ្ងៃទី 31 ខែ ឧសភា ឆ្នាំ 2021 កម្ពុជាមានករណីឆ្លងសរុប 30,094 នាក់ និងស្លាប់ 214 នាក់។ ជំងឺកូវីដ 19 នេះ អាចធ្វើឲ្យការអភិវឌ្ឍក្នុងប្រទេសកម្ពុជាដែលបានសម្រេចយ៉ាងច្រើនដើរថយក្រោយរយៈពេលជាច្រើនឆ្នាំ។ បើសិនជាគ្មានវិធានការសម្រាលផលប៉ះពាល់សំខាន់ៗ ជំងឺកូវីដ 19 អាចធ្វើឲ្យមាននិកម្មភាពយ៉ាងច្រើន និងបង្កើនភាពក្រីក្រ។ លំនាំភាពក្រីក្រដោយផ្អែកលើការព្យាករម៉ាក្រូសេដ្ឋកិច្ច បង្ហាញថា ការថយចុះខ្លាំងនៃសេដ្ឋកិច្ចនឹងបង្កើន អត្រាភាពក្រីក្រចន្លោះពី 5.4 ភាគរយ ទៅ 6.0 ភាគរយ ឬស្មើនឹងចំនួនប្រជាជនក្រីក្របន្ថែមចំនួនពី 859,000 ដល់ 950,000 នាក់ និងអាចធ្វើឲ្យការអភិវឌ្ឍលើការកាត់បន្ថយភាពក្រីក្រដើរថយក្រោយរយៈពេល 6 ឆ្នាំ ។ ក្នុងចំណោមនេះ គ្រួសារដែលពឹងផ្អែកលើប្រាក់ឈ្នួលក្នុងវិស័យក្រៅពីកសិកម្ម ជាពិសេស កម្មករសំណង់ នឹងរងផលប៉ះពាល់ខ្លាំងជាងគេដោយសារការផ្ទុះជំងឺនេះ។

## ជម្រើសគោលនយោបាយ

**នៅចំពោះមុខ ចាំបាច់ត្រូវពន្លឿនការអនុវត្តកម្មវិធីចាក់វ៉ាក់សាំងបង្ការ ទន្ទឹមនឹងការបន្តទប់ស្កាត់ការកើនឡើងនៃករណីឆ្លង និងករណីស្លាប់ ដោយប្រសិទ្ធភាព។** ដោយសារតែការផ្ទុះជំងឺនេះ អាចអូសបន្លាយពេលនៅទូទាំងប្រទេស អត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងបង្ការដើម្បីកាត់បន្ថយការកើនឡើងនៃចំនួនករណីសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងការស្លាប់ ទន្ទឹមនឹងការបន្ថយសម្ពាធលើប្រព័ន្ធសុខាភិបាលដែលកំពុងជួបការលំបាក នឹងមានច្រើនជាងគុណវិបត្តិ។ អន្តរាគមន៍លើផ្នែកផ្សេងក្រៅពីឱសថ ក៏អាចដើរតួនាទីបំពេញបន្ថែមទៅនឹងការទប់ស្កាត់ជំងឺនេះដែរ។ ក្នុងចំណោមប្រជាជនកម្ពុជាជាង 15 លាននាក់ មានប្រជាជនជាង 10.1 លាននាក់ដែលមានអាយុពី 18 ឆ្នាំឡើងទៅ ហើយអាចត្រូវចាក់វ៉ាក់សាំង។ ដូច្នេះ កម្ពុជាត្រូវការវ៉ាក់សាំងបង្ការជំងឺកូវីដ 19 ជាង 20 លានដូសសម្រាប់ប្រជាជនក្នុងក្រុមអាយុនេះ។ ផ្អែកតាមផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 កម្ពុជារំពឹងថានឹងទទួលបានវ៉ាក់សាំងចំនួន 13.5 លានដូស ឬស្មើនឹង 66 ភាគរយនៃចំនួនវ៉ាក់សាំងដែលត្រូវការចាំបាច់សម្រាប់ក្រុមអាយុនេះ គិតត្រឹមខែ កញ្ញា ឆ្នាំ 2021។ ផែនការនេះមានគោលដៅចាក់វ៉ាក់សាំងពេញលេញដល់ប្រជាជនប្រមាណ 5 លាននាក់ដែលស្ថិតក្នុងក្រុមអាទិភាពដំបូង ចាប់ពីខែ ឧសភា រហូតដល់ខែវិច្ឆិកា ឆ្នាំ 2021 (7 ខែ) ដែលស្មើនឹងវ៉ាក់សាំងបង្ការជំងឺកូវីដ 19 ចំនួនប្រមាណ 10 លានដូស។ គិតត្រឹមបំណាច់ខែ មេសា ឆ្នាំ 2021 រដ្ឋាភិបាលបានបញ្ចេញវ៉ាក់សាំងប្រមាណ 2.4 លានដូស។ ដូច្នេះ ផែនការនេះគួរសម្រេចបានការចាក់វ៉ាក់សាំងចំនួនជាមធ្យម 1.1 លានដូសក្នុងមួយខែៗ ចាប់ពីខែ ឧសភា ដល់ខែ វិច្ឆិកា ឆ្នាំ 2021 ដើម្បីបញ្ចប់ការចាក់វ៉ាក់សាំងដែលនៅសល់ចំនួន 7.6 លានដូសទៀត។ ផែនការមេសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ដែលត្រូវបានចេញផ្សាយនៅខែ មីនា ឆ្នាំ 2021 ដោយក្រសួងសុខាភិបាល មានគោលដៅចាក់វ៉ាក់សាំងបង្ការដល់ប្រជាជនចំនួន 10 លាននាក់ ត្រឹមពាក់កណ្ដាលឆ្នាំ 2022។

**ដោយសារកម្ពុជាមានលំហសារពើពន្ធធំបង្គួរ ការជំរុញបន្ថែមលើកម្មវិធីគាំទ្រជនក្រីក្រ និងការវិនិយោគសាធារណៈលើការជំរុញកំណើន រួមទាំងគម្រោងផ្ដល់ការងារដោយផ្ដល់ប្រាក់កម្រៃ ពិតជាសំខាន់ណាស់សម្រាប់ការស្ដារសេដ្ឋកិច្ចឡើងវិញ។** ត្រង់ចំណុចនេះ ថវិកាឆ្នាំ 2021 បានជំរុញការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកដែលជាលើកដំបូងមានបរិមាណលើសការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ។ ទោះជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគជាពិសេស ដើម្បីសម្របសម្រួលការផ្លាស់ប្ដូររចនាសម្ព័ន្ធ ព្រោះថាវិស័យសំណង់បាននៅទ្រឹង ហើយបច្ចុប្បន្ន មានការវិនិយោគកាន់តែច្រើនលើផលិតកម្មសម្រាប់នាំចេញ ទន្ទឹមនឹងការបង្កើនទំនុកចិត្តតាមរយៈការដាក់ចេញនូវច្បាប់ថ្មីស្ដីពីការវិនិយោគ ដែលទាញប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន និងកម្មវិធីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់។ ដោយសារសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្ពស់ គោលនយោបាយសារពើពន្ធនឹងនៅតែជាឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចតែមួយគត់ក្នុងការគាំទ្រដល់ការដោះស្រាយវិបត្តិ ការស្ដារឡើងវិញ និងកំណើន។ ការដោះស្រាយវិបត្តិនៅតែជាការចាំបាច់ ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ ការស្ដារឡើងវិញតម្រូវឲ្យមានការកែលម្អបរិយាកាសវិនិយោគ និងការលើកទឹកចិត្តដើម្បីជំរុញការវិនិយោគ និងបង្កើនការនាំចេញ ព្រោះវិបត្តិជំងឺកូវីដ 19 អាចធ្វើឱ្យសេដ្ឋកិច្ចជួបប្រទះកង្វះការងារធ្វើ។ កំណើនតម្រូវឲ្យមានការវិនិយោគសាធារណៈបន្ថែមទៀត ដើម្បីបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង (រូបវ័ន្ត) និងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ (បទបញ្ញត្តិ) ដើម្បីកាត់បន្ថយការចំណាយលើការដឹកជញ្ជូន និងភ័ស្តុភារ និងបង្កើនភាពប្រកួតប្រជែងក្រៅប្រទេស។

**ជាការសំខាន់ត្រូវបន្តពិនិត្យតាមដានយ៉ាងល្អិតល្អន់លើភាពងាយរងគ្រោះកើតចេញពីកំណើនរយៈពេលយូរនៃវិស័យអចលនទ្រព្យ និងកំណើននៃការផ្ដល់ឥណទានដល់វិស័យសំណង់នៅមុនពេលមានវិបត្តិជំងឺកូវីដ 19។** ផលធៀបកម្ចី-ប្រាក់បញ្ញើ មានចំនួន 120 ភាគរយនៅឆ្នាំ 2020 កើនពី 78.7 ភាគរយក្នុង

រយៈពេលមួយទសវត្សរ៍មុន។ ចំណុចនេះជាការសំខាន់ខ្លាំង ព្រោះថា ការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍នាពេលថ្មីៗនេះនៅតែអូសបន្លាយ ហើយចំនួនរោងចក្រ និងសហគ្រាសដែលរងផលប៉ះពាល់ធ្ងន់ធ្ងរចេះតែកើនឡើងជាលំដាប់។ ព្រឹត្តិការណ៍ទាំងនេះនឹងបន្តកាត់បន្ថយសមត្ថភាពអាជីវកម្ម និងគ្រួសារ ក្នុងការសងប្រាក់កម្ចី ដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុទាំងមូលរងសម្ពាធកាន់តែខ្លាំង។ ថ្មីៗនេះ អាជ្ញាធរកម្ពុជាបានអំពាវនាវឱ្យម្ចាស់លំនៅដ្ឋានយល់ព្រមលើការពន្យារពេលបង់ប្រាក់រំលោះ។ តម្លៃសរុបនៃប្រាក់កម្ចី និងគណនីរបស់អ្នកខ្ចីដែលរងផលប៉ះពាល់ដែលត្រូវរៀបចំឡើងវិញ អាចនឹងកើនឡើងបន្ថែមទៀតនៅឆ្នាំនេះ ដោយកើនពីចំនួនគណនីសរុបនៅឆ្នាំមុន 285,000 គណនី ស្មើនឹងទឹកប្រាក់សរុប 4.2 ពាន់លានដុល្លារ ឬស្មើនឹង 11.2 ភាគរយនៃឥណទានមិនទាន់សងសរុប សម្រាប់ទាំងវិស័យធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុរួមគ្នា។ ក្នុងចំនួនទឹកប្រាក់ 4.2 ពាន់លានដុល្លារនេះ ទឹកប្រាក់ចំនួន 1.73 ពាន់លានដុល្លារ ឬស្មើនឹង 41.5 ភាគរយ ត្រូវបានផ្ដល់ជូនទៅអ្នកខ្ចីដែលរងផលប៉ះពាល់ក្នុងវិស័យសំណង់ ទេសចរណ៍ និងដឹកជញ្ជូន (និងភ័ស្តុភារ)។ ដោយសារតែវិស័យទាំងនេះនៅតែបន្តរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារការបន្តផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍ នឹងមានតម្រូវការកាន់តែច្រើនក្នុងការរៀបចំប្រាក់កម្ចីឡើងវិញលើវិស័យទាំងនេះ។ កម្ចីមិនដំណើរការត្រូវបានរំពឹងថានឹងកើនឡើងពីអត្រាទាបនាពេលបច្ចុប្បន្ន 2.7 ភាគរយសម្រាប់វិស័យធនាគារ និង 1.8 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនៅឆ្នាំ 2020។ ធនាគារកណ្ដាលត្រូវបន្តត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើហានិភ័យហិរញ្ញវត្ថុ ដោយផ្ដោតសំខាន់លើលក្ខខណ្ឌសន្ទនីយភាព មូលធន និងគុណភាពនៃឥណទាន រួមទាំងវិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដូចបរិយាយនៅក្នុងផ្នែកស្តីពីរូបិយវត្ថុក្នុងរបាយការណ៍គោល។

# រូប ES.1៖ ទិដ្ឋភាពរួមស្តីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា

**កំណើនពិត ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅឆ្នាំនេះ...**

*កំណើនពិត (ភាគរយ)*




**...នៅពេលការនាំចេញទំនិញ (មិនគិត មាស) ចាប់ផ្តើមកើន...**

*(ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)*




**...ខណៈដែលលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនៅតែរឹងមាំ...**

*(ភាគរយនៃ ផសស)*




**...ហើយទុនបម្រុងអន្តរជាតិសរុប កើនឡើងថែមទៀត**

*(ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)*




**ទោះបីជាថយចុះ ប៉ុន្តែ កំណើនរូបិយវត្ថុទូលាយ នៅតែមានភាពល្អប្រសើរ...**

*បំណុលជារូបិយវត្ថុទូលាយ (ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)*




**...ប៉ុន្តែ ការបិទខ្ទប់ដោយសារការផ្ទុះជំងឺកូវីដ 19 នាពេលថ្មីៗនេះ បានបង្អាក់សកម្មភាពក្នុងស្រុក**

*សន្ទស្សន៍ស្តីពីនិន្នាការចល័តភាព Apple របស់កម្ពុជា (ភាគរយ)*




*ប្រភព ៖* អាជ្ញាធរកម្ពុជា ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់ ៖* e =ការប៉ាន់ស្មាន, GIR=ទុនបម្រុងអន្តរជាតិសរុប, p=ការព្យាករ, RHS=ខាងស្តាំ, YTD=ឆ្នាំនេះ, y/y=ធៀបនឹងឆ្នាំមុន

## ផ្នែកទី ១

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ



# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

## ការអភិវឌ្ឍថ្មីៗ

### ទោះបីមានការប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទប់ស្កាត់ជំងឺកូវីដ 19 ក្ដី ក៏ការផ្ទុះការឆ្លងក្នុងសហគមន៍នៅតែកើតមានសាជាថ្មី

**កម្ពុជាទទួលបានជោគជ័យក្នុងការទប់ស្កាត់ការឆ្លងរាលដាលវីរុសកូរ៉ូណា រហូតដល់ត្រីមាសទីមួយក្នុងឆ្នាំ 2021។** កម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសដែលមានករណីវីរុសកូរ៉ូណាតិចជាងគេនៅអាស៊ី ដោយកម្ពុជាមានករណីឆ្លងជំងឺកូវីដ 19ត្រឹមតែ1,753ករណី(ក្នុងនោះ:967ករណីបានជាសះស្បើយ និងស្លាប់ 3 ករណី) គិតត្រឹមថ្ងៃទី 22 ខែ មីនា ឆ្នាំ 2021 បន្ទាប់ពីការរកឃើញករណីទីមួយនៅថ្ងៃទី 27 ខែ មករា ឆ្នាំ 2020[1]។ ទោះជាយ៉ាងណា ថ្មីៗនេះ កម្ពុជាបានជួបប្រទះការផ្ទុះឡើងជាថ្មីនៃការឆ្លងវីរុសកូរ៉ូណាដែលអាចបង្កបញ្ហាដល់ប្រព័ន្ធសុខាភិបាលសាធារណៈរបស់ខ្លួន។ គិតត្រឹមថ្ងៃទី 31 ខែ ឧសភា ឆ្នាំ 2021 កម្ពុជាមានករណីឆ្លងជំងឺកូវីដ 19 ចំនួន 30,094 ករណី និងស្លាប់ 214 ករណី (រូប 1)។ ជាការឆ្លើយតប អាជ្ញាធរកម្ពុជាបានបង្កើនការតាមដានរកខ្សែរយៈនៃការប៉ះពាល់តាមរយៈការកំណត់អត្តសញ្ញាណមនុស្សទាំងអស់ដែលប៉ះពាល់ជាមួយអ្នកជំងឺកូវីដ 19 ការបើកមណ្ឌលចត្តាឡីស័កបន្ថែម ការបង្កើនចំនួនមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺកូវីដ 19 ដែលបន្តកើនឡើងជាលំដាប់ និងការធ្វើលទ្ធកម្មបរិក្ខារវេជ្ជសាស្ត្រ និងរថយន្តសង្គ្រោះបន្ថែម។ ក្នុងចំណោមតំបន់ដែលរងផលប៉ះពាល់ខ្លាំងជាងគេ គឺ តំបន់ប្រជុំជនសំខាន់ៗ ដែលរួមមាន ទីក្រុងភ្នំពេញ ខេត្តកណ្ដាល ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តព្រៃវែង។ នៅខែ មេសា ឆ្នាំ 2021 អាជ្ញាធរកម្ពុជាបានបិទខ្ទប់តំបន់ប្រជុំជនធំជាងគេចំនួនពីរ គឺ ទីក្រុងភ្នំពេញ និងក្រុងតាខ្មៅ ក្នុងខេត្តកណ្ដាល ដែលជាទីក្រុងមានប្រជាជនច្រើនជាងគេបន្ទាប់ពីទីក្រុងភ្នំពេញ។

### កម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 បានចាប់ផ្ដើម

**កម្មវិធីចាក់វ៉ាក់សាំងបង្ការវីរុសកូរ៉ូណាបានចាប់ផ្ដើមនៅថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ 2021 បន្ទាប់ពីកម្ពុជាទទួលបានវ៉ាក់សាំង Sinopharm ចំនួន 600,000 ដូសពីប្រទេសចិននៅថ្ងៃទី 7 ខែ កុម្ភៈ ឆ្នាំ 2021។** គិតត្រឹមបំណាច់ខែ មេសា ឆ្នាំ 2021 កម្ពុជាបានចាក់វ៉ាក់សាំងចំនួន 1.3 លានដូសរួចហើយ (រូប 2)។ ក្នុងអំឡុងពេលដូចគ្នានេះ កម្ពុជាបានទទួលវ៉ាក់សាំងបង្ការវីរុសកូរ៉ូណាជាង 4.0 លានដូស ក្នុងនោះ វ៉ាក់សាំងចំនួន 324,000 ដូស ត្រូវបានផលិតដោយ Covishield ដែលទទួលបានតាមរយៈកម្មវិធី COVAX ហើយ វ៉ាក់សាំងផ្សេងទៀតគឺជាវ៉ាក់សាំង Sinovac និងវ៉ាក់សាំង Sinopharm ដែលជាជំនួយរបស់ប្រទេសចិន។ នៅខែ មេសា ឆ្នាំ 2021 ជើងចុងក្រោយនៃវ៉ាក់សាំង Sinopharm ចំនួន 400,000 ដូស ត្រូវបានដឹកជញ្ជូនមកដល់កម្ពុជានៅថ្ងៃទី 28 ខែ មេសា ឆ្នាំ 2021។ ក្នុងចំណោមប្រជាជនកម្ពុជាជាង 15 លាននាក់ ប្រជាជនជាង 10.1 លាននាក់ ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ហើយប្រហែលជាត្រូវចាក់វ៉ាក់សាំងដែលមាននាពេលបច្ចុប្បន្ននេះ។ ដូច្នេះ កម្ពុជាត្រូវការវ៉ាក់សាំងបង្ការវីរុសកូរ៉ូណាជាង 20 លានដូស។

**រូប 1 ៖ ករណីវីរុសកូរ៉ូណាកើនឡើង** (មធ្យមភាគនៃការធ្វើដំណើរក្នុងរយៈពេល 7 ថ្ងៃ គិតត្រឹមថ្ងៃទី 31 ខែ ឧសភា ឆ្នាំ 2021)




*ប្រភព ៖* Our World in Data

**រូប 2 ៖ ការចាក់វ៉ាក់សាំងបង្ការ កើនឡើង** ចំនួនដូសនៃវ៉ាក់សាំងដែលបានចាក់ជូន ក្នុងចំណោមប្រជាជន 100 នាក់




*ប្រភព ៖* Our World in Data

**រូប 3 ៖ សន្ទស្សន៍ស្ដីពីនិន្នាការចល័តភាព Apple របស់កម្ពុជា បានថយចុះ** (ភាគរយគិតត្រឹមថ្ងៃទី 16 ខែ ឧសភា ឆ្នាំ 2021)




*ប្រភព ៖* និន្នាការចល័តភាព Apple, Apple

1 សេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ថ្ងៃទី 5 ខែ វិច្ឆិកា ឆ្នាំ 2020។

**ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ត្រូវបានដាក់ចេញនៅខែ ឧសភា ឆ្នាំ 2021។** នៅក្នុងផែនការនេះ ប្រជាជនកម្ពុជាប្រហែលជា 5 លាននាក់ ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ (ឬស្មើនឹង 49 ភាគរយនៃចំនួនប្រជាជនសរុបនៃក្រុមអាយុនេះ) ជាក្រុមអាទិភាពដែលត្រូវចាក់វ៉ាក់សាំងបង្ការមុនគេ ផ្អែកលើទីកន្លែងរស់នៅដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ បណ្តុំសកម្មភាពក្រៅពីកសិដ្ឋានច្រើនជាងគេ និងសារៈសំខាន់ខ្លាំងផ្នែកសេដ្ឋកិច្ច។ ក្នុងក្រុមអាយុនេះ ប្រជាជន 2.5 លាននាក់ដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល នឹងទទួលបានវ៉ាក់សាំងនៅជំហានដំបូង (ខែ ឧសភា-ពាក់កណ្តាលខែ កក្កដា ឆ្នាំ 2021)។ ប្រជាជនអាទិភាពចំនួន 2.5 លាននាក់ផ្សេងទៀតដែលកំពុងរស់នៅទូទាំងផ្ទៃប្រទេសនឹងទទួលបានវ៉ាក់សាំងនៅជំហានទីពីរ (ចំនួន 2 លាននាក់ចាប់ពីពាក់កណ្តាលខែ កក្កដា រហូតដល់ខែ កញ្ញា) និងជំហានទីបី (ចំនួន 0.5 លាននាក់ ចាប់ពីខែ តុលា រហូតដល់ ខែ វិច្ឆិកា ឆ្នាំ 2021)។ ក្រោមផែនការនេះ ប្រជាជនទាំង 5 លាននាក់នេះជាក្រុមគោលដៅដែលត្រូវទទួលបានការចាក់វ៉ាក់សាំងបង្ការពេញលេញក្នុងរយៈពេល 7 ខែ (ខែឧសភា-ខែវិច្ឆិកា) ដែលស្មើនឹងវ៉ាក់សាំងសរុបចំនួន 10 លានដូស។ គិតត្រឹមបំណាច់ខែ មេសា ឆ្នាំ 2021 វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ចំនួន 2.4 លានដូសត្រូវបានចាក់រួចហើយ។ ដូច្នេះ ផែនការនេះគួរសម្រេចបានការចាក់វ៉ាក់សាំងចំនួន 1.1 លានដូស/ខែ នៅអំឡុងខែ ឧសភា-វិច្ឆិកា ឆ្នាំ 2021 ដើម្បីបញ្ចប់ការចាក់វ៉ាក់សាំងដែលនៅសល់ចំនួន 7.6 លានដូសនោះ។ ផែនការមេសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ដែលត្រូវបានចេញផ្សាយនៅខែ មីនា ឆ្នាំ 2021 ដោយក្រសួងសុខាភិបាល មានគោលបំណងផ្តល់ការចាក់វ៉ាក់សាំងបង្ការដល់ប្រជាជន 10 លាននាក់ គិតត្រឹមពាក់កណ្តាលឆ្នាំ 2022។

**ការផ្ទុះឡើងវិញនៃការឆ្លងក្នុងសហគមន៍បណ្តាលឱ្យមានការរឹតត្បិតការធ្វើដំណើរទូទាំងប្រទេស។** អាជីវកម្ម សាលារៀន មហាវិទ្យាល័យ និងសារមន្ទីរ ត្រូវបានបិទទ្វារជាបណ្តោះអាសន្ននៅអំឡុងខែ មីនា និងខែ មេសា ឆ្នាំ 2021។ ការងើបឡើងវិញនៃតម្រូវការក្នុងស្រុក ដោយមានការគាំទ្រដោយកំណើនជាបណ្តើរៗនៃការប្រើប្រាស់ក្នុងស្រុករហូតដល់ត្រីមាសទីមួយក្នុងឆ្នាំ 2021 ត្រូវបានបង្អាក់ ដោយសារតែសកម្មភាពសេដ្ឋកិច្ចត្រូវបានរាំងស្ទះសាជាថ្មី(រូប3)ជាពិសេសនៅតំបន់ប្រជុំជនសំខាន់ៗ គឺ រាជធានីភ្នំពេញ និងទីរួមខេត្តកណ្តាល សៀមរាប ព្រះសីហនុ និងព្រៃវែង។

### ទោះជាមានការទប់ស្កាត់មិនដូចគ្នាលើជំងឺកូវីដ 19 ក្តី ក៏សេដ្ឋកិច្ចក្នុងតំបន់បានងើបឡើងវិញ

**វីរុសកូរ៉ូណាពិតជាពិបាកគ្រប់គ្រងណាស់ ចាប់តាំងពីការឃើញមានករណីដំបូងនៅទីក្រុងវូហាន កាលពីខែ ធ្នូ ឆ្នាំ 2019។** ប្រទេសចិន និងវៀតណាម ដែលជាទូទៅ បានទប់ស្កាត់ជំងឺនេះជួបប្រទះការផ្ទុះឡើងម្តងម្កាលនៅមូលដ្ឋាន[2]។ ប្រទេសម៉ាឡេស៊ីបានជួបប្រទះការផ្ទុះការឆ្លងទ្រង់ទ្រាយធំជាថ្មី ចំណែកប្រទេសមីយ៉ាន់ម៉ា ម៉ុងហ្គោលី និងថៃ ជួបប្រទះការឆ្លងក្នុងទ្រង់ទ្រាយតូចមួយចំនួន។ ក្នុងចំណោមប្រទេសដែលមានការផ្ទុះការឆ្លងវីរុសកូរ៉ូណាកាលពីពីរបីខែមុន ស្ថានភាពនៅប្រទេសទាំងនោះមានភាពប្រសើរឡើងនៅប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ប៉ុន្តែ ចំនួនករណីឆ្លងនៅតែខ្ពស់ដដែល។ ទោះជាយ៉ាងណា ការលេចឡើងនៃវីរុសបម្លែងខ្លួនថ្មីដែលងាយឆ្លងជាងមុន បានបង្កជាបញ្ហាប្រឈមថ្មីចំពោះការទប់ស្កាត់ជំងឺនេះនៅជុំវិញពិភពលោក។

**សេដ្ឋកិច្ចក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកចាប់ផ្តើមងើបឡើងវិញ។** ទោះជាយ៉ាងណា ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំក្នុងតំបន់នេះ មានតែប្រទេសចិន និងវៀតណាមប៉ុណ្ណោះដែលមានគន្លងស្តារឡើងវិញជាទម្រង់អក្សរ V ដោយមានផលសេដ្ឋកិច្ចនៅឆមាសទីពីរក្នុងឆ្នាំ 2020 កើនលើសពីកម្រិតមុនពេលមានការផ្ទុះជំងឺកូវីដ 19។ ភាគច្រើននៃបណ្តាប្រទេសផ្សេងទៀត មិនទាន់មានការស្តារឡើងវិញពេញលេញឡើយ មិនថា គិតជាសេដ្ឋកិច្ច ឬសន្ទុះកំណើននោះទេ។ គិតត្រឹមបំណាច់ឆ្នាំ 2020 សេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសមានសេដ្ឋកិច្ចធំៗទាំង 4 ក្នុងតំបន់ (ឥណ្ឌូណេស៊ី ថៃ ហ្វីលីពីន និងម៉ាឡេស៊ី) នៅតែមានអត្រាជាមធ្យម ទាបជាងកម្រិតមុនវិបត្តិជំងឺកូវីដ 19 ចំនួន 5 ភាគរយ ដោយគម្លាតតិចជាងគេគឺនៅឥណ្ឌូណេស៊ី (2.2 ភាគរយ) និងគម្លាតច្រើនជាងគេនៅហ្វីលីពីន (8.4 ភាគរយ)។ ការស្តារឡើងវិញនៃសេដ្ឋកិច្ចសកល (សូមមើលប្រអប់ 1) ដោយទទួលការគាំទ្រមួយផ្នែកដោយការជំរុញសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក ត្រូវបានរំពឹងថានឹងស្តារពាណិជ្ជកម្មទំនិញ និងអាចជំរុញសន្ទុះពីខាងក្រៅដល់កំណើនជាមធ្យម 1 ភាគរយ ប៉ុន្តែ វិស័យទេសចរណ៍នៅជុំវិញពិភពលោកត្រូវបានរំពឹងថានៅតែមានកម្រិតទាបជាងកម្រិតមុនវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2023 ដែលពន្យារការស្តារសេដ្ឋកិច្ចក្នុងបណ្តាប្រទេសដែលពឹងផ្អែកលើវិស័យទេសចរណ៍។

### ការនាំចេញកំពុងងើបឡើងវិញជាបណ្តើរៗ ដោយសារតែកំណើនតម្រូវការពិភពលោក

**ប្រទេសមួយចំនួនទទួលបានអត្ថប្រយោជន៍ពីតម្រូវការពិភពលោកច្រើនលើផលិតផលដែលប្រទេសទាំងនោះមានឯកទេស។** ការស្តារឡើងវិញនៃតម្រូវការពិភពលោក នឹងកើនឡើងថែមទៀតដោយកញ្ចប់ជំរុញសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក។ ប្រទេសមួយចំនួន ដូចជា ចិន ថៃ និងវៀតណាម មិនត្រឹមតែរក្សាបាននូវតម្រូវការនៃការនាំចេញរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនចំណែកនៃការនាំចេញរបស់ខ្លួនក្នុងការនាំចេញផលិតផលទាំងនេះនៅទូទាំងពិភពលោកផងដែរ[3]។ ការបង្អាក់ការផ្គត់ផ្គង់មិនមានកម្រិតធ្ងន់ធ្ងរក្នុងបណ្តាប្រទេសទាំងនេះឡើយ ដោយសារតែស្ថានភាពជំងឺកូវីដ 19 មិនសូវធ្ងន់ធ្ងរ។ ការនាំចេញទំនិញរបស់ចិន និងវៀតណាម កើនឡើងយ៉ាងឆាប់រហ័ស ដោយកើនលើស

2 ធនាគារពិភពលោក 2021a
3 ធនាគារពិភពលោក 2021a

**ប្រអប់ 1 ៖**

## ការអភិវឌ្ឍសេដ្ឋកិច្ចសកល និងទស្សនៈវិស័យ[1 2]

កំណើនសកលកំពុងងើបឡើងវិញ ទោះបីជាមានការផ្ទុះឡើងជាថ្មីនៃជំងឺកូវីដ 19 ក្នុងបណ្តាប្រទេសមួយចំនួនក្តី។ សូចនាករស្តីពីសន្ទស្សន៍ពីអ្នកគ្រប់គ្រងលើការទិញជាសកល បង្ហាញពីកំណើនយ៉ាងខ្លាំងនៅខែ មីនា ដែលជាសញ្ញាបង្ហាញពីកំណើននៃសន្ទុះកំណើនសកល។ ការស្តារឡើងវិញយ៉ាងខ្លាំងនៃវិស័យផលិតជាសកលកំពុងគាំទ្រដល់ការងើបឡើងនៃពាណិជ្ជកម្មទំនិញ។ ការដឹកជញ្ជូនតាមផ្លូវអាកាសមានកំណើនក្នុងរយៈពេលពីរបីខែដំបូងក្នុងឆ្នាំ 2021 ប៉ុន្តែនៅតែទាបជាងកម្រិតមុនវិបត្តិជំងឺកូវីដ 19 ចំនួន 25 ភាគរយ។

ស្ថានភាពហិរញ្ញប្បទានជាសកលនៅតែមានប្រសើរជារួម ដោយគម្លាតការប្រាក់របស់មូលបត្របំណុលសាជីវកម្ម និងរដ្ឋាភិបាលអាមេរិកទាប ធ្វើឱ្យតម្លៃនៃប្រាក់កម្ចីទាប។ តម្លៃទំនិញបានកើនឡើងនៅឆ្នាំ 2021 ដែលភាគច្រើនកើនលើសតម្លៃកាលពីមុនវិបត្តិជំងឺកូវីដ 19 (រូប B1.1)។ ទោះជាយ៉ាងណា ករណីជំងឺកូវីដ 19 នៅជុំវិញពិភពលោក កំពុងកើនឡើង ហើយវីរុសនេះបានបម្លែងខ្លួន និងងាយឆ្លងជាងមុន (រូប B1.2)។ ចល័តភាពជាសកលបានថយចុះនៅដើមខែ មេសា ព្រោះប្រទេសជាច្រើនបានអនុវត្តវិធានការបង្កើនការរឹតត្បិតជំងឺរាតត្បាតនេះ។

បន្ទាប់ពីការថយចុះយ៉ាងខ្លាំងនៅឆ្នាំ 2020 ការស្តារឡើងវិញជាសកលក្នុងកម្រិតខ្ពស់ជាងការប៉ាន់ស្មាន ត្រូវបានរំពឹងទុកសម្រាប់ឆ្នាំ 2021 ដោយមានការគាំទ្រពីការពង្រីកសារពើពន្ធនៅសហរដ្ឋអាមេរិក។ កំណើននៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានព្យាករណ៍ថានឹងកើន 7.4 ភាគរយនៅឆ្នាំ 2021 នាំមុខដោយការស្តារសេដ្ឋកិច្ចយ៉ាងខ្លាំងនៅប្រទេសចិន។ ការស្តារឡើងវិញក្នុងតំបន់នេះ (មិនគិត ចិន) ត្រូវបានរំពឹងថានឹងមានភាពយឺតយ៉ាវ និងមានកំណើនជាមធ្យម 4.4 ភាគរយនៅឆ្នាំ 2021 ដោយមានភាពខុសគ្នាខ្លាំងនៅតាមបណ្តាប្រទេសនានា។ កំណើនដែលបានព្យាករណ៍នេះនឹងមិនអាចប៉ះប៉ូវទាំងស្រុងលើការខាតបង់ផលសេដ្ឋកិច្ចពាក់ព័ន្ធនឹងជំងឺកូវីដ 19 ក្នុងបណ្តាប្រទេសជាច្រើនក្នុងតំបន់បានឡើយ ដោយផលសេដ្ឋកិច្ចក្នុងបណ្តាប្រទេសទាំងនោះត្រូវបានរំពឹងថា នៅតែមានកម្រិតទាបជាងកម្រិតមុនវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2022។

ការព្យាករកំណើនសកលនៅតែមានភាពមិនប្រាកដប្រជាខ្លាំង។ និរន្តរភាពនៃការស្តារឡើងវិញអាស្រ័យលើរយៈពេលនៃជំងឺកូវីដ 19 ប្រសិទ្ធភាពនៃវិធានការគោលនយោបាយក្នុងការសម្រេចបានការចាក់វ៉ាក់សាំងបង្ការទូលំទូលាយ និងការទប់ស្កាត់វិបត្តិហិរញ្ញវត្ថុ និងការងើបឡើងវិញនៃការធ្វើដំណើរជាសកល។ ការថយចុះនៃសេដ្ឋកិច្ចសកលនឹងមានកម្រិតខ្ពស់ជាងការព្យាករកម្រិតគោល ប្រសិនបើការគ្រប់គ្រងជំងឺកូវីដ 19 ត្រូវចំណាយពេលយូរជាងការរំពឹងទុក ឬប្រសិនបើសម្ពាធហិរញ្ញវត្ថុបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរ។ កន្លងមក ការឆ្លើយតបពិសេសលើផ្នែកគោលនយោបាយបានទប់ស្កាត់ការថយចុះសកម្មភាពមិនឱ្យក្លាយជាវិបត្តិហិរញ្ញវត្ថុ។ ទោះជាយ៉ាងណា ស្ថានភាពហិរញ្ញវត្ថុនៅតែមានភាពផុយស្រួយសម្រាប់តួអង្គទីផ្សារជាច្រើន។ ការបង្អាក់យូរលើសកម្មភាពសេដ្ឋកិច្ចអាចបង្កើនសម្ពាធកាន់តែខ្លាំងលើវិស័យហិរញ្ញវត្ថុ ដែលអាចនាំឲ្យមានវិបត្តិហិរញ្ញវត្ថុទ្រង់ទ្រាយធំ។

ជំងឺកូវីដ 19 អាចប៉ះពាល់យូរអង្វែងតាមរបៀបជាច្រើន រួមទាំង ការថយចុះការវិនិយោគ ទំនុកចិត្តតិចតួច និងការថយចុះនៃមូលធនមនុស្ស។ ផលប៉ះពាល់រយៈពេលវែងពាក់ព័ន្ធនឹងជំងឺកូវីដ 19 នឹងមានភាពធ្ងន់ធ្ងរនៅបណ្តាប្រទេសដែលរងគ្រោះខ្លាំងបំផុតដោយសារការមានការឆ្លងជំងឺកូវីដ 19 រយៈពេលយូរ និងការដួលរលំនៃវិស័យទេសចរណ៍សកល និងពាណិជ្ជកម្ម និងប្រទេសដែលរងគ្រោះដោយវិបត្តិហិរញ្ញវត្ថុ (ធនាគារពិភពលោក ឆ្នាំ 2021 ចេញផ្សាយឆាប់ៗនេះ)។

**រូប B1.1៖ តម្លៃទំនិញ**




*ប្រភព ៖* Haver Analytics ធនាគារពិភពលោក

*សម្គាល់ ៖* ការសង្កេតចុងក្រោយនៅខែ មីនា ឆ្នាំ 2021

**រូប B1.2៖ ករណីឆ្លងថ្មីប្រចាំសប្តាហ៍នៃជំងឺកូវីដ 19 ជាសកល**




*ប្រភព ៖* Bloomberg ធនាគារពិភពលោក អង្គការសុខភាពពិភពលោក

*សម្គាល់ ៖* បន្ទាត់ក្រហមបង្ហាញពីករណីឆ្លងថ្មីសរុបប្រចាំសប្តាហ៍នៃជំងឺកូវីដ 19 សម្រាប់បណ្តាប្រទេសនានា ដែលនៅថ្ងៃទី 25 ខែ មេសា មានប្រជាជនជាង 20 ភាគរយបានចាក់វ៉ាក់សាំងបង្ការជំងឺនេះយ៉ាងតិចមួយដូស។

---

1 ប្រអប់នេះត្រូវបានរៀបចំឡើងដោយ Ekaterine Vashakmadze ក្រុមព្យាករណ៍។

2 ផ្អែកលើរបាយការណ៍ព្យាករណ៍សេដ្ឋកិច្ចសកល ខែ មករា និងបច្ចុប្បន្នភាពតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2021 របស់ធនាគារពិភពលោក។ បច្ចុប្បន្នភាពនៃការព្យាករណ៍ជាសកលនឹងចេញផ្សាយក្នុងរបាយការណ៍ព្យាករណ៍សេដ្ឋកិច្ចសកល ខែ មិថុនា ឆ្នាំ 2021។

អត្រាកំណើនមុនវិបត្តិជំងឺកូវីដ 19 (រូប 4)។ ការនាំចេញរបស់វៀតណាមមានភាពល្អប្រសើរបំផុត ជាពិសេស ការនាំចេញទៅសហរដ្ឋអាមេរិក មួយផ្នែកដោយសារតែឥទ្ធិពលនៃការបង្វែរពាណិជ្ជកម្ម ដែលបណ្តាលមកពីភាពតានតឹងរវាងសហរដ្ឋអាមេរិក និងចិន[4]។ ចិន និងវៀតណាម ត្រូវបានរំពឹងថានឹងមានកំណើនយ៉ាងខ្លាំងនៅឆ្នាំ 2021 ដោយចិនមានកំណើន 8.1 ភាគរយ ចំណែកវៀតណាមមានកំណើន 6.6 ភាគរយ ខណៈដែលប្រទេសផ្សេងទៀតក្នុងតំបន់ត្រូវបានរំពឹងថាមានកំណើនត្រឹមតែ 4.4 ភាគរយប៉ុណ្ណោះ។ ផ្ទុយទៅវិញ បណ្តាប្រទេសដែលមានដំណើរការសេដ្ឋកិច្ចទន់ខ្សោយបំផុត គឺជាប្រទេសដែលពឹងផ្អែកលើចំណូលពីវិស័យ ទេសចរណ៍ ជាជាងការនាំចេញទំនិញផលិត ជាពិសេស សម្ភារអេឡិចត្រូនិក។

**ការនាំចេញទំនិញរបស់កម្ពុជាបានកែសម្រួលទៅនឹងការប្រែប្រួលនៃស្ថានភាពតម្រូវការខាងក្រៅ ហើយចំណែកនៃការនាំចេញសម្លៀកបំពាក់ធៀបនឹងការនាំចេញទំនិញសរុប (មិនគិត មាស) ថយមកត្រឹម 45.6 ភាគរយក្នុងរយៈពេល 4 ខែដំបូងក្នុងឆ្នាំ 2021** ថយពី 52.2 ភាគរយនៅឆ្នាំ 2020 (និងថយពី 57.6 ភាគរយនៅឆ្នាំ 2019) (រូប 5)។ គិតត្រឹមខែ មេសា ឆ្នាំ 2021 ការនាំចេញសម្លៀកបំពាក់ (និងវាយនភណ្ឌ) លែងមានចំណែកខ្ពស់នៅក្នុងការនាំចេញទំនិញរបស់កម្ពុជាទៀតហើយ ។ ដោយសារការផ្លាស់ប្តូរបរិមាណនៃការនាំចេញទំនិញរបស់កម្ពុជា ការថយចុះនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរនៅត្រីមាសទីពីរ និងត្រីមាសទីបីក្នុងឆ្នាំ 2020 ត្រូវបានប៉ះប៉ូវមួយផ្នែកដោយកំណើននៃការនាំចេញទំនិញកសិកម្ម ផលិតផលកសិកម្មកែច្នៃ ផលិតផលផលិតថ្មីៗ (គ្រឿងបន្លាស់អគ្គិសនី គ្រឿងបន្លាស់អេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត រួមទាំង កង់) និងផលិតផលផ្សេងទៀត (រូប 6)។ ស្ថានភាពនេះបានជួយឱ្យកម្ពុជារក្សាបានអត្រាកំណើននៃការនាំចេញទំនិញចំនួន 16.7 ភាគរយធៀបនឹងឆ្នាំមុន (កំណត់ត្រា) នៅឆ្នាំ 2020 ប្រសិនបើបញ្ចូលការនាំចេញមាសនោះ។បើទោះជាមានចំណែកតូចត្រឹមតែ 3.2 ភាគរយនៃការនាំចេញទំនិញសរុប (មិនគិតមាស) ការនាំចេញគ្រឿងបន្លាស់អគ្គិសនី ខ្សែភ្លើង និងគ្រឿងបង្គុំ និងគ្រឿងបន្លាស់យានយន្ត នៅឆ្នាំ 2020 មានតម្លៃសរុប 456 លានដុល្លារ ស្មើនឹងកំណើន 18.1 ភាគរយ។ ការនាំចេញកង់បានកើនដល់ 527 លានដុល្លារ ស្មើនឹងកំណើន 27.7 ភាគរយនៅឆ្នាំ 2020។

**ការនាំចេញទំនិញបានងើបឡើងវិញ។** ការនាំចេញទំនិញ (មិនគិតការនាំចេញមាស) កើន 12.2 ភាគរយនៅរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021។ ទោះជាថ្លៃដឹកជញ្ជូនបានកើនឡើងក៏ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរដែលថយចុះយ៉ាងខ្លាំងនៅខែ មករា ឆ្នាំ 2021 ចំនួន 13.2 ភាគរយធៀបនឹងឆ្នាំមុនបានងើបឡើងវិញចាប់ពីពេលនោះមក។ ទោះជាថ្លៃដឹកជញ្ជូនបានកើនឡើង បានងើបឡើងវិញចាប់ពីពេលនោះមក។ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ កើនចំនួន 10.2 នៅខែ មីនា ឆ្នាំ 2021 និងកើន 27.8 ភាគរយ នៅខែ មេសា ឆ្នាំ 2021។ ការនាំចេញកង់កើនចំនួន 32.3 ភាគរយក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021 កើនពី 27.8 ភាគរយក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2020។ ក្នុងអំឡុងពេលដូចគ្នានេះ សរុបការនាំចេញគ្រឿងបន្លាស់យានយន្ត គ្រឿងបន្លាស់អគ្គិសនី និងគ្រឿងបន្លាស់អេឡិចត្រូនិក បញ្ចូលគ្នា កើនចំនួន 16.4 ភាគរយនៅខែ មីនា ឆ្នាំ 2021 និងកើនចំនួន 18.2 ភាគរយនៅខែ មេសា ឆ្នាំ 2021។

**រូប 4 ៖ ការនាំចេញទំនិញក្នុងតំបន់កើនឡើង[1]**
(ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)




*ប្រភព ៖* Haver Analytics
*សម្គាល់ ៖* 1.ការនាំចេញរបស់កម្ពុជា មិនគិតការនាំចេញមាស, YTD=ឆ្នាំនេះ

**រូប 5 ៖ ការថយចុះចំណែកនៃការនាំចេញសម្លៀកបំពាក់ធៀបនឹងការនាំចេញទំនិញសរុប**
(មិនគិតមាស) (ភាគរយ)




*ប្រភព ៖* អាជ្ញាធរកម្ពុជា

**រូប 6 ៖ ការនាំចេញរបស់កម្ពុជា[1] ងើបឡើងវិញ**
(ការរួមចំណែកដល់កំណើននៃការនាំចេញ ភាគរយ)




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*សម្គាល់ ៖* 1.ការនាំចេញរបស់កម្ពុជា មិនគិតការនាំចេញមាស

4 ធនាគារពិភពលោក 2021a

## ការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជាទៅសហរដ្ឋអាមេរិកកើនឡើង

**សហរដ្ឋអាមេរិកនៅតែជាទីផ្សារនាំចេញធំជាងគេបំផុតរបស់កម្ពុជាដែលបន្តកើនឡើងនៅឆ្នាំ 2020។** ទីផ្សារសហរដ្ឋអាមេរិកមានចំណែក 36.7 ភាគរយនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុបរបស់កម្ពុជានៅឆ្នាំ 2020 កើនពី 31.9 ភាគរយនៅឆ្នាំ 2019។ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុបទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមានទំហំទឹកប្រាក់ 3.5 ពាន់លានដុល្លារ ឬស្មើនឹងកំណើន 3.6 ភាគរយធៀបនឹងឆ្នាំមុន ហើយកំណើននេះបានមកមួយផ្នែកដោយសារតែការនាំចូលដោយមិនគិតពន្ធ (និងកូតា) ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់សហរដ្ឋអាមេរិក។ កម្មវិធី GSP ដែលកម្ពុជាទទួលបាននៅឆ្នាំ 2016 បានបង្កើនការនាំចេញទំនិញធ្វើដំណើររបស់កម្ពុជា ដូចជា វ៉ាលី កាបូបស្ពាយក្រោយខ្នង កាបូបស្ពាយចំហៀង និងកាបូបលុយ[5]។ ទោះជាយ៉ាងណា កម្មវិធីនេះបានអស់សុពលភាពនៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 និងរង់ចាំការអនុម័តពីសភាសហរដ្ឋអាមេរិក[6]។

**ផ្ទុយទៅវិញ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ សរុបទៅកាន់ទីផ្សារសហភាពអឺរ៉ុប បានថយចំនួន 35 ភាគរយ ដោយមានទំហំទឹកប្រាក់តែ 2.6 ពាន់លានដុល្លារនៅឆ្នាំ 2020។** ទីផ្សារសហភាពអឺរ៉ុប មានចំណែកចំនួន 27.5 ភាគរយនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុបរបស់កម្ពុជា ថយចុះពី 38.2 ភាគរយនៅឆ្នាំ 2019 (និងថយពី 42.6 ភាគរយនៅឆ្នាំ 2018)។ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារចក្រភពអង់គ្លេស និងសហភាពអឺរ៉ុប សរុបគ្នា មានចំនួន 36.7 ភាគរយនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុបរបស់កម្ពុជា ដែលនៅតែទាបជាងចំណែកនៃការនាំចេញផលិតផលទាំងនេះទៅកាន់ទីផ្សារសហរដ្ឋអាមេរិកដែលមានចំនួន 36.7 ភាគរយនោះ។ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ 19 និងការដកប្រព័ន្ធអនុគ្រោះពន្ធ EBA មួយផ្នែក ដែលបានចូលជាធរមានតាំងពីថ្ងៃទី 12 ខែ សីហា ឆ្នាំ 2020 (ប៉ះពាល់ដល់ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបប្រហែល 20 ភាគរយ)[7] ជាមូលហេតុចម្បងនៃការថយចុះការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប។ ប្រហាក់ប្រហែលគ្នានេះ ខណៈដែលការនាំចេញកង់របស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកកើនឡើងដង មានចំនួន 147 លានដុល្លារនៅឆ្នាំ 2020 ការនាំចេញកង់របស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបបានថយចំនួន 3.9 ភាគរយ មានចំនួន 275 លានដុល្លារ។

## លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសចាប់ផ្តើមងើបឡើងវិញ

**ដោយសារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលទើបតែត្រូវបានចុះហត្ថលេខា ទំហំទឹកប្រាក់នៃគម្រោងដែលបានទទួលការអនុម័តក្នុងវិស័យពិតដែលទទួលហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស បានកើនឡើង។** ការកើនឡើងនេះបានជំរុញការធ្វើពិពិធកម្មគម្រោងវិនិយោគផ្ទាល់ពីបរទេស ដែលកន្លងមកប្រមូលផ្តុំភាគច្រើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ ប៉ុន្តែ បច្ចុប្បន្នបានងាកទៅវិស័យថាមពល ការថែទាំសុខភាព ទូរគមនាគមន៍ សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងកសិកម្ម (រួមទាំងឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម) ដើម្បីសម្របទៅតាមការប្រែប្រួលនៃស្ថានភាពតម្រូវការសេដ្ឋកិច្ចក្នុងស្រុក និងស្ថានភាពតម្រូវការខាងក្រៅ។ ទោះជាយ៉ាងណា វិស័យទេសចរណ៍នៅតែមានចំណែកដ៏ធំនៃគម្រោងវិនិយោគផ្ទាល់ពីបរទេស (ដែលទទួលបានការអនុម័ត)។ នៅឆ្នាំ 2020 ទំហំទឹកប្រាក់នៃគម្រោងសរុបដែលបានទទួលការអនុម័ត (អចលនទ្រព្យ) ដែលទទួលបានហិរញ្ញប្បទានពីលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យផលិតរបស់កម្ពុជា កើនដល់ 3.6 ពាន់លានដុល្លារ ស្មើនឹងកំណើន 4.3 ភាគរយធៀបនឹងឆ្នាំមុន (រូប 7)។ ចិនមានចំណែកប្រហែលជាពាក់កណ្តាលនៃទំហំទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសសរុប (ដែលបានទទួលការអនុម័ត)។

**នៅឆ្នាំ 2020 លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនជាគម្រោង "ឆ្ពោះទៅមុខ" ដែលផ្តោតលើផលចំណេញរយៈពេលខ្លី និងរយៈពេលវែងពីការវិនិយោគ។** ចំណុចនេះឆ្លុះបញ្ចាំងថា ជំងឺកូវីដ 19 មិនងាយផុតរលត់ទេ។ ដូច្នេះ គម្រោងផ្តល់ផលចំណេញឆាប់រហ័ស ដូចជា គម្រោងដែលវិនិយោគលើការលក់រាយ ការលក់ដុំ និងវិស័យអចលនទ្រព្យ មិនសូវទទួលបានចំណាប់អារម្មណ៍នោះទេ។ សមាសភាគធំជាងគេនៃទំហំទឹកប្រាក់គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តនៅឆ្នាំ 2020 ផ្តោតលើវិស័យទេសចរណ៍ (សណ្ឋាគារលំដាប់ផ្កាយ 5 សួនកំសាន្ត និងមជ្ឈមណ្ឌលពាណិជ្ជកម្ម) ដែលមានទំហំទឹកប្រាក់ 1.75 ពាន់លានដុល្លារ ទោះបីជាវិស័យទេសចរណ៍រងផលប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺរាតត្បាតនេះក្តី។ សមាសភាគធំជាងគេទីពីរនៃទំហំទឹកប្រាក់គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ផ្តោតលើឧស្សាហកម្ម "ក្រៅពីសម្លៀកបំពាក់ ដែលមានទំហំទឹកប្រាក់ 1.36 ពាន់លានដុល្លារ (រូប 8)។ ឧស្សាហកម្មទាំងនេះរួមមាន ថាមពល រួមទាំង ថាមពលកកើតឡើងវិញ (588 លានដុល្លារ) ការថែទាំសុខភាព (358 លានដុល្លារ) និងទូរគមនាគមន៍ (102 លានដុល្លារ)។ វិស័យបន្ទាប់មកទៀតគឺវិស័យកាត់ដេរ ដែលមានទំហំទឹកប្រាក់ 220 លានដុល្លារ និងវិស័យកសិកម្ម និងវិស័យកែច្នៃផលិតផលកសិកម្មដែលមានទំហំទឹកប្រាក់ 110 លានដុល្លារ។ ទំហំទឹកប្រាក់គម្រោង

5 សូមមើល https://kh.usembassy.gov/duty-free-access-travel-goods-made-cambodia/ ។

6 សូមមើល https://www.cbp.gov/trade/priority-issues/trade-agreements/special-trade-legislation/generalized-system-preferences ។

7 សម្រាប់ព័ត៌មានលម្អិត សូមមើល https://trade.ec.europa.eu/doclib/press/index.cfm?id=2113.។

វិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក្នុង វិស័យសំណង់ និងអចលនទ្រព្យ បានថយចុះខ្លាំង ដោយមានទឹកប្រាក់តែ 140 លានដុល្លារនៅឆ្នាំ 2020 ថយពី 1.79 ពាន់លានដុល្លារនៅឆ្នាំ 2019។

**ដូចបានពិភាក្សាពីខាងលើ ការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំងលើឧស្សាហកម្មកាត់ដេរ ដែលជាប្រតិបត្តិការ “កាត់ដេរធម្មតា” ក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ និងជាផ្នែកដែលមានតម្លៃបន្ថែមទាបបំផុតក្នុងសង្វាក់តម្លៃទាំងមូល។** ខុសពីកម្ពុជា ប្រទេសវៀតណាមអាចធ្វើពិពិធកម្មមូលដ្ឋាននៃការនាំចេញផលិតផលកម្មន្តសាលរបស់ខ្លួនបានយ៉ាងឆាប់រហ័ស ហើយសំខាន់ជាងនេះ បានរំកិលដោយជោគជ័យឆ្ពោះទៅការនាំចេញសម្ភារអេឡិចត្រូនិកដែលមានតម្លៃបន្ថែមខ្ពស់ (សូមមើលប្រអប់ 2)។ ខណៈដែលចិននៅតែមានចំណែកប្រហែលពាក់កណ្តាលនៃលំហូរចូលការវិនិយោគសរុបនៅកម្ពុជា លំហូរចូលការវិនិយោគផ្ទាល់របស់ចិនមានចំណែកតែ 11 ភាគរយប៉ុណ្ណោះនៃលំហូរចូលការវិនិយោគផ្ទាល់សរុបនៅវៀតណាម។ វៀតណាមជាប្រទេសដែលទទួលបានការវិនិយោគផ្ទាល់ពីប្រទេសសំខាន់ៗជាច្រើន។ ក្រៅពីចិន វៀតណាមទទួលបានលំហូរចូលការវិនិយោគផ្ទាល់ពីសាធារណរដ្ឋកូរ៉េចំនួន 18.7 ភាគរយ ពីជប៉ុនចំនួន 16.3 ភាគរយ ពីសិង្ហបុរីចំនួន 13.7 ភាគរយ ពីតៃវ៉ាន់ (ចិន) ចំនួន 8.9 ភាគរយ ពីប្រជុំកោះ British Virgin ចំនួន 6.0 ភាគរយ ពីម៉ាឡេស៊ីចំនួន 3.5 ភាគរយ និងពីថៃចំនួន 3.0 ភាគរយ នៅឆ្នាំ 2019[8]។ ប្រមាណ 60 ភាគរយនៃលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនៅវៀតណាម ប្រមូលផ្តុំក្នុងវិស័យកម្មន្តសាល 16.0 ភាគរយ ប្រមូលផ្តុំក្នុងសកម្មភាពអចលនទ្រព្យ និង 6.1 ភាគរយប្រមូលផ្តុំក្នុងការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងម៉ាស៊ីនត្រជាក់។ ទោះជាយ៉ាងណា លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា និងវៀតណាម ហាក់មាននិន្នាការស្រដៀងគ្នា (រូប 9) ដែលឆ្លុះបញ្ចាំងពីស្ថានភាពតម្រូវការខាងក្រៅ ជំរុញការសម្រេចចិត្តរបស់វិនិយោគិនបរទេសក្នុងការវិនិយោគនៅសេដ្ឋកិច្ចដែលងើបឡើង។

### កំណែទម្រង់បរិយាកាសវិនិយោគនៅតែជួបប្រទះបញ្ហា

**ក្រៅពីការកែប្រែគោលនយោបាយពាណិជ្ជកម្ម ការកែប្រែប្រសិទ្ធផលនៃការផលិតទំនិញ អាចនាំទៅការកែប្រែសមាសភាគទំនិញដែលប្រទេសមួយនាំចេញ (និងនាំចូល)[9]។** កម្ពុជា និងវៀតណាមសុទ្ធតែជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសុទ្ធតែអនុវត្តគោលនយោបាយពាណិជ្ជកម្មសេរី។ ទោះជាយ៉ាងណា វៀតណាមទទួលបានជោគជ័យក្នុងការបង្កើនប្រសិទ្ធផលដែលមានចំណាត់ថ្នាក់ខ្ពស់ជាងលើភាពងាយស្រួលធ្វើធុរកិច្ច មានន័យថា បរិយាកាសនិយ័តកម្មនៅវៀតណាម មានភាពអំណោយផលជាងសម្រាប់ការចាប់ផ្តើម និងប្រតិបត្តិការរបស់ក្រុមហ៊ុន និងអាជីវកម្ម។ នៅឆ្នាំ 2020 ការធ្វើធុរកិច្ចរបស់វៀតណាមឈរនៅលេខរៀងទី 70 ចំណែកកម្ពុជាឈរនៅលេខរៀងទី 144 (ក្នុងចំណោម 170 ប្រទេស)[10]។ ការកាត់បន្ថយឧបសគ្គលើការចាប់ផ្តើមប្រតិបត្តិការរបស់ក្រុមហ៊ុន និងបរិយាកាសអំណោយ

**រូប 7 ៖ ទំហំទឹកប្រាក់នៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត កើនឡើង**
(ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*សម្គាល់ ៖* YTD=ឆ្នាំនេះ

**រូប 8 ៖ ការកើនឡើងនៃគម្រោងវិនិយោគផ្ទាល់ពីបរទេស ប្រមូលផ្តុំក្នុងឧស្សាហកម្មក្រៅពីសម្លៀកបំពាក់**
(ពាន់លានដុល្លារ)




*ប្រភព ៖* អាជ្ញាធរកម្ពុជា

**រូប 9 ៖ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជា និងវៀតណាម មាននិន្នាការស្រដៀងគ្នា**
(3mma ធៀបនឹងឆ្នាំមុន)




*ប្រភព ៖* អាជ្ញាធរកម្ពុជា និង Haver Analytics
*សម្គាល់ ៖* RHS=ខាងស្តាំ; 3mma=មធ្យមភាគរំកិល 3 ខែ

8 គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលទទួលបានអាជ្ញាប័ណ្ណ (សរុបគម្រោងដែលត្រូវបានអនុម័ត គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019) បែងចែកតាមសមភាគីសំខាន់ៗ (ការិយាល័យស្ថិតិទូទៅវៀតណាម)។

9 Kehoe និង Ruhl (2003) តើទំនិញថ្មីៗមានសារៈសំខាន់ដូចម្តេចក្នុងពាណិជ្ជកម្មអន្តរជាតិ? របាយការណ៍លេខ 324 របស់បុគ្គលិកនាយកដ្ឋានស្រាវជ្រាវ ទីក្រុងនៃធនាគារសហព័ន្ធសហរដ្ឋអាមេរិក។

10 សូមមើល របាយការណ៍របស់ធនាគារពិភពលោកស្តីពីការធ្វើធុរកិច្ច ៖ https://www.doingbusiness.org/en/data/exploreeconomies/cambodia។

## ប្រអប់ 2 ៖

## កត្តាជំរុញកំណើនសេដ្ឋកិច្ចរឹងមាំរបស់វៀតណាម

**វៀតណាមជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលមានកំណើនក្នុងអំឡុងវិបត្តិនេះ។** ផ.ស.ស របស់វៀតណាមកើន 2.9 ភាគរយនៅឆ្នាំ 2020 ដោយសារភាពធន់ក្នុងការនាំចេញ និងវិស័យក្នុងស្រុករបស់វៀតណាម ទោះបីជាកំណើននេះមានកម្រិតទាបជាងអត្រាកំណើនចំនួន 7 ភាគរយនៅឆ្នាំ 2019 ក្តី។ ក្នុងរយៈពេលពីរទសវត្សរ៍មុនវិបត្តិនេះ វៀតណាមសម្រេចបានកំណើនពីរខ្ទង់លើចំណែកនៃការនាំចេញសម្ភារអេឡិចត្រូនិក និងគ្រឿងម៉ាស៊ីន (កុំព្យូទ័រ សម្ភារអេឡិចត្រូនិក ទូរស័ព្ទ ទូរស័ព្ទចល័ត ម៉ាស៊ីនថតរូប និងម៉ាស៊ីនថតវីដេអូ គ្រឿងម៉ាស៊ីន បរិក្ខារការិយាល័យ ឧបករណ៍ជាងឧបករណ៍តន្រ្តី មធ្យោបាយដឹកជញ្ជូនផ្សេងទៀត និងខ្សែភ្លើងស្រោប និងខ្សែកាប) ដែលកើនចំនួន 60.3 ភាគរយនៃការនាំចេញទំនិញសរុប (146 ពាន់លានដុល្លារ) នៅឆ្នាំ 2018 កើនពី 5.9 ភាគរយនៃការនាំចេញទំនិញសរុប (3.6 ពាន់លានដុល្លារ) នៅឆ្នាំ 2008 (រូប B2.1)។ ចំណុចនេះផ្តល់លទ្ធភាពឱ្យវៀតណាមអាចរួចផុតពីវិបត្តិតម្រូវការសកលដែលបង្កឡើងដោយជំងឺកូវីដ 19។

**ផ្ទុយទៅវិញ ការនាំចេញរបស់កម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំងលើផលិតផលសម្លៀកបំពាក់ដែលមានតម្លៃបន្ថែមទាប ទោះបីជាផលិតផលទាំងនោះលែងជាចំណែកច្រើនលើសលប់ក្នុងការនាំចេញទំនិញ គិតត្រឹមខែ មេសា ឆ្នាំ 2021 ក្តី** (រូប B2.2)។ ខណៈដែលកម្ពុជាមានឧស្សាហកម្មកាត់ដេរដ៏រឹងមាំដែលផ្តោតលើការនាំចេញ និងផ្តល់ការងារច្រើនដូចលើកឡើងខាងលើ វិស័យកម្មន្តសាលនៅតែជាប្រតិបត្តិការ "កាត់ដេរធម្មតា" អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ និងជាវិស័យដែលមានតម្លៃបន្ថែមទាបបំផុតនៃសង្វាក់តម្លៃទាំងមូល។ មូលដ្ឋាននាំចេញដ៏តូចចង្អៀតរបស់កម្ពុជាទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារវិបត្តិតម្រូវការខាងក្រៅនៅឆ្នាំ 2020។ កំណើនពិតរបស់កម្ពុជា គឺ -3.1 ភាគរយនៅឆ្នាំ 2020 ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាថយចុះជាលើកដំបូងក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ។

**ខណៈដែលការនាំចេញរបស់ប្រទេសភាគច្រើនក្នុងតំបន់ ថយចុះដោយសារជំងឺរាតត្បាតនេះ ការនាំចេញដែលត្រូវបានធ្វើពិពិធកម្មដោយជោគជ័យរបស់វៀតណាមដំណើរការបានយ៉ាងល្អ** ជាពិសេសការនាំចេញទៅកាន់សហរដ្ឋអាមេរិក មួយផ្នែកដោយសារតែឥទ្ធិពលនៃការបង្វែរពាណិជ្ជកម្មដែលបណ្តាលមកពីភាពតានតឹងរវាងសហរដ្ឋអាមេរិក និងចិន (រូប B2.3)។ នៅឆ្នាំ 2021 សេដ្ឋកិច្ចរបស់វៀតណាមត្រូវបានព្យាករណ៍ថាមានកំណើន 6.6 ភាគរយ ដែលទទួលការគាំទ្រដោយដំណើរការល្អប្រសើរនៃវិស័យកម្មន្តសាលដែលផ្តោតលើការនាំចេញ និងការស្តារឡើងវិញនៃតម្រូវការក្នុងស្រុក។

**ដើម្បីសម្រេចបានឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 គំរូអភិវឌ្ឍន៍របស់វៀតណាមត្រូវបានផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចផ្អែកតាមចំណេះដឹង ឌីជីថលភាវូបនីយកម្ម និងបៃតង។** ក្នុងដំណាក់កាលអន្តរកាលប៉ុន្មានឆ្នាំខាងមុខ វៀតណាមត្រូវធ្វើការវិនិយោគយ៉ាងច្រើនលើមូលធនមនុស្ស នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធបៃតង ដើម្បីបង្កើនផលិតភាព ក្នុងគោលដៅសម្រេចបានសេដ្ឋកិច្ចផ្អែកតាមចំណេះដឹង និងកាន់តែមានភាពធន់។ វៀតណាមប្តេជ្ញា ១) បង្កើនគុណភាពស្ថាប័ន និងអភិបាលកិច្ចសេដ្ឋកិច្ចទីផ្សារ ២) អភិវឌ្ឍមូលធនមនុស្ស វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៣) បន្តធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកល និង ៤) បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ថាមពល និងព័ត៌មានវិទ្យា និងទីក្រុងធំៗដែលធន់ និងបៃតង។

**សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងស្តារឡើងវិញ ដោយមានកំណើន 4 ភាគរយនៅឆ្នាំ 2021។** ទោះបីជាយ៉ាងណា គំរូកំណើនរបស់កម្ពុជាដែលមានមូលដ្ឋាននាំចេញតូចចង្អៀត រួមនឹងការប្រមូលផ្តុំផលិតផល និងទីផ្សារ និងគ្របដណ្តប់ដោយការកើនឡើងនៃលំហូរចូលមូលធនដែលជំរុញកំណើនវិស័យសំណង់ និងអចលនទ្រព្យ មុនពេលមានវិបត្តិ អាចលែងមាននិរន្តរភាពក្នុងរយៈពេលខ្លីរហូតដល់រយៈពេលវែង។ ប្រសិនបើមិនដោះស្រាយបញ្ហាកម្សោយផ្នែករចនាសម្ព័ន្ធទេនោះ សេដ្ឋកិច្ចកម្ពុជានឹងមានគន្លងថ្មី (ធម្មតាតាមបែបគន្លងថ្មី) ដែលកើនឡើងតែបន្តិចក្រោយវិបត្តិជំងឺកូវីដ 19។

**រូប B2.1៖ ការនាំចេញរបស់វៀតណាមបានធ្វើពិពិធកម្ម ដែលភាគច្រើនជាផលិតផលមានតម្លៃបន្ថែមខ្ពស់**




*ប្រភព ៖* Haver Analytics

*សម្គាល់ ៖* RHS=ខាងស្តាំ

**រូប B2.2៖ ការនាំចេញរបស់កម្ពុជានៅតែពឹងផ្អែកខ្លាំងលើសម្លៀកបំពាក់**




*ប្រភព ៖* Haver Analytics

**រូប B2.3៖ ការនាំចេញរបស់វៀតណាមដែលជំរុញដោយសម្ភារៈអេឡិចត្រូនិក ដំណើរការយ៉ាងល្អ**




*ប្រភព ៖* Haver Analytics

ផល បានទាក់ទាញការវិនិយោគថ្មីៗ។ ការកែសម្រួលវិធាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការនាំចេញ ទន្ទឹមនឹងការកាត់បន្ថយចំណាយលើការដឹកជញ្ជូន គយ កំពង់ផែ និងចំណាយផ្នែករដ្ឋបាល បានជួយជំរុញកំណើនពាណិជ្ជកម្ម និងពិពិធកម្មការនាំចេញ។ ក្នុងសន្ទស្សន៍ដំណើរការភ័ស្តុភារឆ្នាំ 2018 វៀតណាមឈរនៅលេខរៀងទី 39 ចំណែកកម្ពុជាឈរនៅលេខរៀងទី 98 (ក្នុងចំណោម 160 ប្រទេស)[11]។

### វិស័យសំណង់បន្តថយចុះ ដោយសារការផ្គត់ផ្គង់លើសពីតម្រូវការ

**ក្នុងរយៈពេលជាច្រើនឆ្នាំមុនវិបត្តិជំងឺកូវីដ 19 វិស័យសំណង់ និងអចលនទ្រព្យនៅកម្ពុជាទទួលបានកំណើនមិនធ្លាប់មាន ដែលធ្វើឱ្យមានការផ្គត់ផ្គង់លើសពីតម្រូវការ។** តម្រូវការខាងក្រៅលើទ្រព្យសម្បត្តិពាណិជ្ជកម្ម និងលំនៅដ្ឋានរបស់កម្ពុជា បានរួមចំណែកមួយផ្នែកដល់កំណើនយ៉ាងឆាប់រហ័សនេះ។ នៅពេលជំងឺរាតត្បាតនេះផ្ទុះឡើង គួបផ្សំជាមួយនឹងការបិទខ្ទប់ និងការបង្កើនការរឹតត្បិតការធ្វើដំណើរអន្តរជាតិ រួមទាំងការតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល 14 ថ្ងៃ តម្រូវការខាងក្រៅត្រូវបានបង្អាក់ ហើយការវិនិយោគលើផ្នែកទ្រព្យសម្បត្តិដែលភាគច្រើនទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសគម្រោងអភិវឌ្ឍន៍អគារខ្ពស់ៗនៅមជ្ឈមណ្ឌលប្រជុំជន ដូចជាទីក្រុងភ្នំពេញ និងខេត្តព្រះសីហនុ ត្រូវបានផ្អាក។ ទោះបីជាចំណែកតូចមួយនៃទីផ្សារលំនៅដ្ឋានទ្រព្យសម្បត្តិលំនៅដ្ឋានដែលមានតម្លៃទាប និងសមរម្យ នៅតែមានភាពធន់ មានភ័ស្តុតាងកាន់តែច្រើនបង្ហាញពីការថយចុះនៃទីផ្សារទ្រព្យសម្បត្តិ ហើយតម្លៃអចលនទ្រព្យបន្តថយចុះ (រូប 10)។ តម្លៃខុនដូទទួលរងការប៉ះពាល់ខ្លាំងជាងគេ[12]។ នៅឆ្នាំ 2020 ការថយចុះនៃសកម្មភាពសាងសង់ត្រូវបានបង្ហាញដោយការថយចុះការនាំចូលដែកថែប ស៊ីម៉ង់ត៍ និងសម្ភារសាងសង់សំខាន់ៗផ្សេងទៀត។ តម្លៃនៃការនាំចូលដែកថែប និងស៊ីម៉ង់ត៍ ដែលជាវត្ថុធាតុប្រើប្រាស់យ៉ាងសំខាន់ក្នុងឧស្សាហកម្មសំណង់ បានថយចុះ ដោយការនាំចូលដែកថែបថយចុះ 34.5 ភាគរយ ចំណែកការនាំចូលស៊ីម៉ង់ត៍ថយ 48.6 ភាគរយធៀបនឹងឆ្នាំមុន នៅឆ្នាំ 2020 (រូប 11)។

**ការផ្គត់ផ្គង់លើសតម្រូវការអាចកាត់បន្ថយទំនុកចិត្តរបស់វិនិយោគិនបរទេសក្នុងការវិនិយោគលើគម្រោងអភិវឌ្ឍន៍អចលនទ្រព្យ។** ជាលទ្ធផល ទំហំទឹកប្រាក់នៃលិខិតអនុញ្ញាតសាងសង់ដែលបានទទួលការអនុញ្ញាត បានថយចុះចំនួន -63.8 ភាគរយ នៅឆ្នាំ 2020 (រូប 12) នៅខណៈដែលផ្ទៃក្រឡាសាងសង់ (គិតជាម៉ែត្រការ៉េ) ថយចុះ -24.3 ភាគរយ។ ការផ្គត់ផ្គង់ និងតម្លៃជាមធ្យមនៃអចលនទ្រព្យក្នុងឧស្សាហកម្មអចលនទ្រព្យ ត្រូវបានរំពឹងថានឹងថយចុះថែមទៀតនៅឆ្នាំ 2021[13] ខណៈការងើបឡើងវិញនៃតម្រូវការអចលនទ្រព្យពាណិជ្ជកម្ម និងលំនៅដ្ឋាន នឹងត្រូវការពេលវេលាយូរ ព្រោះថា តម្រូវការនេះអាស្រ័យលើការវិលត្រឡប់មកវិញនៃតម្រូវការសកល ដោយសារថា កម្ពុជាមានទីផ្សារក្នុងស្រុកតូច។ ការបន្ធូរបន្ថយការរឹតត្បិតការធ្វើដំណើរជាអន្តរជាតិ និងការលើកលក្ខខណ្ឌតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល 14 ថ្ងៃ បន្ទាប់ពីការគ្រប់គ្រងការផ្ទុះការឆ្លងក្នុងសហគមន៍ដោយជោគជ័យ អាចធ្វើឲ្យមានការស្តារតម្រូវការពីបរទេស ដែលនឹងជួយជំរុញទីផ្សារអចនទ្រព្យ។ ទោះជាយ៉ាងណា មិនច្បាស់ថាតើតម្រូវការខាងក្រៅនឹងមានរយៈពេលយូរប៉ុណ្ណោះទេ ប្រសិនបើមានការវិលត្រឡប់មករកប្រក្រតីភាពវិញ ដោយសារតែឱកាសតិចតួចនៃការផ្តល់ផលចំណេញពីការវិនិយោគលើការកាន់កាប់

**រូប 10 ៖ តម្លៃអចលនទ្រព្យថយចុះ**
( ដុល្លារអាមេរិក/ម៉ែត្រការ៉េ)




*ប្រភព ៖* CBRE, កម្ពុជា
*សម្គាល់ ៖* RHS=ខាងស្តាំ

**រូប 11 ៖ការនាំចូលសម្ភារសំណង់សំខាន់ៗ ថយចុះ**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 12 ៖ ចំនួនលិខិតអនុញ្ញាតការសាងសង់ដែលត្រូវបានអនុម័ត ថយចុះ**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

11 សូមមើលលម្អិតស្តីពីសន្ទស្សន៍ដំណើរការភ័ស្តុភារ ៖ https://lpi.worldbank.org/international/aggregated-ranking។
12 សូមមើល https://www.globalpropertyguide.com/Asia/Cambodia/Price-History។
13 2021 ការព្យាករដោយមិនបារម្ភ ៖ ការថយចុះ ឬការងើបឡើងវិញ CBR កម្ពុជា។ សូមមើល https://images.cbre.com.kh/2021/02/2021_Fearless-Forecast_For-Circulation.pdf។

អចលនទ្រព្យនៅកម្ពុជា (ក្រុងព្រះសីហនុសម្រេចបានកំណើនយ៉ាងឆាប់រហ័សក្នុងវិស័យសំណង់ នៅអំឡុងឆ្នាំ 2017-2019 ដោយមានលំហូរចូលយ៉ាងច្រើននៃការវិនិយោគរបស់ចិន ដោយសារការរំពឹងថានឹងទទួលបានផលចំណេញខ្ពស់ពីសកម្មភាពវិនិយោគ ដែលទទួលបានការគាំទ្រដោយឧស្សាហកម្មកាស៊ីណូរយៈពេលខ្លី)។

### ផលិតកម្មកសិកម្មនៅតែមានភាពធន់

**ផលិតកម្មស្រូវសរុបបានកើនឡើង ដោយសារតែកំណើនផលិតកម្មស្រូវប្រាំងនៅអំឡុងឆ្នាំ 2020-2021។** ផ្ទៃដីដាំដុះ(និងផល) ស្រូវប្រាំងបានកើនដល់ 0.65 លានហិកតា ឬកើន 9.0 ភាគរយនៅឆ្នាំ 2020 (រូប 13)។ ក្រៅពីនេះ ទិន្នផលស្រូវប្រាំងកើនដល់ 4.5 តោនក្នុងមួយហិកតា ឬកើន 2.2 ភាគរយនៅឆ្នាំ 2020។ ជាលទ្ធផល ផលិតកម្មស្រូវប្រាំងនៅឆ្នាំ 2020 កើនដល់ 2.93 លានតោន ស្មើនឹងកំណើន 12.1 ភាគរយ។ ទោះជាយ៉ាងណា ផលិតកម្មស្រូវវស្សានៅតែថយចុះ ដោយសារតែស្ថានភាពធាតុអាកាសមិនទៀងទាត់។ ទោះជាមានការប្រឹងប្រែងក្នុងការពង្រីកផ្ទៃដីដាំដុះស្រូវវស្សារហូតដល់ 2.79 លានហិកតា ឬស្មើនឹងកំណើន 2.2 ភាគរយនៅឆ្នាំ 2020 ក្តី ក៏គ្រោះរាំងស្ងួតនៅពាក់កណ្តាលរដូវវស្សា និងគ្រោះទឹកជំនន់នៅចុងរដូវវស្សាបានធ្វើឱ្យផ្ទៃដីប្រមូលផល ថយចុះ 3.0 ភាគរយ។ ដូច្នេះ ផលិតកម្មស្រូវវស្សាថយមកត្រឹម 8.22 លានតោន ឬថយចុះ 0.6 ភាគរយធៀបនឹងឆ្នាំមុននៅឆ្នាំ 2020។ ដោយសារតែការកើនឡើងនៃផលិតកម្មស្រូវប្រាំង ផលិតកម្មស្រូវសរុបកើនដល់ 11.15 លានតោន ឬកើន 2.4 ភាគរយនៅឆ្នាំ 2020។ ខណៈដែលផ្ទៃដីដាំដុះ (និងផល) ស្រូវប្រាំងកើនឡើងជាបន្តបន្ទាប់តាមរយៈការប្រឹងប្រែងពង្រីកប្រព័ន្ធស្រោចស្រពស្រូវប្រាំង ទិន្នផលស្រូវប្រាំងនៅតែប្រែប្រួល (រូប 14) ដែលបង្ហាញពីបញ្ហាប្រឈមបន្តទៀតក្នុងការប្រើប្រាស់ធនធានកសិកម្មទំនើប និងការអនុវត្តបច្ចេកវិទ្យាថ្មីក្នុងការបង្កបង្កើនផល។ ផ្ទុយទៅវិញ ទិន្នផលស្រូវវស្សាមិនប្រែប្រួល និងកើនឡើងបន្តិចម្តងៗ ដោយកើនដល់ 3.1 តោនក្នុងមួយហិកតា ឬស្មើនឹងកំណើន 70.3 ភាគរយនៃទិន្នផលស្រូវប្រាំងនៅឆ្នាំ 2020 កើនពី 2.5 តោនក្នុងមួយហិកតា ឬស្មើនឹង 63 ភាគរយនៃទិន្នផលស្រូវប្រាំងនៅឆ្នាំ 2008។ ស្រូវជាដំណាំដ៏សំខាន់របស់កម្ពុជា ហើយតម្លៃបន្ថែមនៃផលិតកម្មដំណាំមានចំនួន 57.4 ភាគរយនៃ ផសស កសិកម្មរបស់កម្ពុជានៅឆ្នាំ 2020។

### ការប្រែប្រួលតម្លៃក្នុងស្រុកធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មកសិកម្ម

**ការប្រែប្រួលតម្លៃទំនិញកសិកម្មក្នុងស្រុកនៅតែជាបញ្ហាប្រឈមចំពោះវិស័យកសិកម្ម** ជាពិសេសសម្រាប់ផលិតផលកសិកម្ម (ក្រៅពីស្រូវ/អង្ករ)។ ទោះជាវិស័យកសិកម្មទទួលបានអត្ថប្រយោជន៍ពីការមានកម្លាំងពលកម្មកាន់តែច្រើន និងការវិនិយោគបន្ថែម ការប្រែប្រួលតម្លៃទំនិញកសិកម្ម ជាពិសេសផលិតផលកសិកម្មក្រៅពីស្រូវ/អង្ករសម្រាប់ទីផ្សារក្នុងស្រុក នៅតែជាឧបសគ្គដ៏ធំ ដោយសារតែចំណាយខ្ពស់លើអគ្គិសនី និងភ័ស្តុភារ។ ជាញឹកញាប់ ផលិតកម្មកសិកម្មនៅកម្ពុជាប្រឈមនឹងការផ្គត់ផ្គង់ផលិតផលទាបជាង ឬលើសតម្រូវការ ដោយសារតែកត្តាតាមរដូវកាល និងកង្វះការធ្វើពិពិធកម្មទីផ្សារ[14]។ លក្ខខណ្ឌធាតុអាកាសអាចជាបញ្ហាប្រឈមដ៏ធំបំផុតមួយ ព្រោះធាតុអាកាសអំណោយផលអាចធ្វើឱ្យមានការផ្គត់ផ្គង់លើសតម្រូវការ ចំណែកធាតុអាកាសមិនអំណោយផលអាចនាំឲ្យមានការផ្គត់ផ្គង់ទាបជាងតម្រូវការ។ ដោយសារតែកម្ពុជាមានទីផ្សារក្នុងស្រុកតូច និងការដួលរលំនៃវិស័យទេសចរណ៍ តម្លៃលក់រាយនៃផលិតផលកសិកម្មកាន់តែមានភាពប្រែប្រួល (រូប 15) និងបង្កផលប៉ះពាល់មិនល្អលើផលិតកម្មកសិកម្មទាំងមូល (ក្រៅពីស្រូវ/អង្ករ)។ អាជ្ញាធរកម្ពុជាបានខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការដោះស្រាយបញ្ហានេះតាមរយៈការបង្កើតអង្គការកសិករ ផលិតផលកសិកម្មតាម

**រូប 13 ៖ ផលិតកម្មស្រូវវស្សាមានភាពថយចុះបន្តិច**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 14 ៖ ទិន្នផលស្រូវប្រាំងប្រែប្រួល**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS=ខាងស្តាំ*

**រូប 15 ៖ តម្លៃទំនិញកសិកម្មក្នុងស្រុកប្រែប្រួល**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា និងធនាគារពិភពលោក*
*សម្គាល់ ៖ RHS=ខាងស្តាំ*

14 Sreymom និង Pirom ឆ្នាំ 2015។

ភូមិសាស្ត្រ ការពង្រីកការធ្វើកសិកម្មតាមកិច្ចសន្យា និងការផ្សារភ្ជាប់អ្នកផលិតទំនិញកសិកម្មទៅនឹងអ្នកលក់ដុំ និងអ្នកលក់រាយអាហារសំខាន់ៗនៅតាមទីប្រជុំជនធំៗ ដើម្បីគាំទ្រដល់សង្វាក់ផ្គត់ផ្គង់អាហារ (ក្នុងស្រុក)[15]។ ការសិក្សាសមិទ្ធិលទ្ធភាពស្តីពីការបង្កើតសួនកសិឧស្សាហកម្ម ត្រូវបានធ្វើឡើង។

### កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ត្រូវបានរំពឹងថានឹងជួយជំរុញផលិតកម្មកសិកម្ម

**ការរំពឹងលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ដែលអាចចូលជាធរមាននៅឆ្នាំនេះជួយជំរុញការវិនិយោគបន្ថែមទៀត និងគាំទ្រដល់ផលិតកម្មកសិកម្មជារួមសម្រាប់ការនាំចេញ** ជាពិសេសការនាំចេញទៅកាន់ទីផ្សារចិន។ ចំណុចនេះជួយកាត់បន្ថយឧបសគ្គរបស់វិស័យកសិកម្ម ដោយសារទីផ្សារក្នុងស្រុកតូច។ ចិនបានផ្តល់កូតាដល់កម្ពុជាក្នុងការនាំចូលអង្កររហូតដល់ 400,000 តោនក្នុងមួយឆ្នាំតាំងពីឆ្នាំ 2019។ ចិនគឺជាទីផ្សារនាំចេញអង្ករឈានមុខគេរបស់កម្ពុជា (សូមមើលផ្នែកខាងក្រោមសម្រាប់ខ្លឹមសារលម្អិតស្តីពីការនាំចេញអង្ករ)។ ក្រៅពីនេះ មានការបង្កើតទំនិញកសិកម្មថ្មីៗ ដូចជា ស្វាយ និងចេក។ នៅឆ្នាំ 2020 កម្ពុជារកចំណូលបាន 112 លានដុល្លារ ឬស្មើនឹងកំណើន 128 ភាគរយ ពីការនាំចេញចេកតែមួយមុខ។ ការដឹកជញ្ជូនចេកស្រស់ដោយផ្ទាល់ពីកម្ពុជាទៅកាន់ប្រទេសចិន គឺនៅខែឧសភា ឆ្នាំ 2021 បន្ទាប់ពីគយចិនបានផ្តល់វិញ្ញាបនបត្របញ្ជាក់ដល់ចម្ការស្វាយចំនួន 37 និងរោងចក្រវេចខ្ចប់ចំនួន 5 នៅថ្ងៃទី 26 ខែ មេសា ឆ្នាំ 2021។ កម្ពុជា និងចិន បានចុះហត្ថលេខាលើពិធីសារភូតគាមអនាម័យសម្រាប់ការនាំចេញស្វាយស្រស់ទៅកាន់ប្រទេសចិននៅខែ មិថុនា ឆ្នាំ 2020[16]។

### សាជីវកម្មធានាឥណទានដំបូងគេក្រោមការគ្រប់គ្រងដោយរដ្ឋ ត្រូវបានបង្កើតឡើង

**នៅខែ មីនា ឆ្នាំ 2021 សាជីវកម្មធានាឥណទានកម្ពុជា ដែលជាសាជីវកម្មធានាឥណទានដំបូងគេក្រោមការគ្រប់គ្រងដោយរដ្ឋ និងមានមូលធនដំបូងចំនួន 200 លានដុល្លារ ត្រូវបានបង្កើតឡើង[17]។** សាជីវកម្មនេះបានដាក់ចេញគម្រោងធានាការស្តារអាជីវកម្ម ដែលជាគម្រោងធានាឥណទានដំបូងគេរបស់ស្ថាប័ននេះ។ គម្រោងនេះមានគោលបំណងគាំទ្រដល់អាជីវកម្ម រួមទាំង សហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនធំៗ ដើម្បីបង្កើនលទ្ធភាពក្នុងការទទួលបានកម្ចីផ្លូវការសម្រាប់ទុនបង្វិល និងការវិនិយោគ ឬការពង្រីកអាជីវកម្ម។ កសិកម្ម រួមទាំងការកែច្នៃផលិតផលកសិកម្ម ការផលិត និងកែច្នៃអាហារ ជាវិស័យអាទិភាពមួយ។ គម្រោងនេះដើរតួនាទីជាវត្ថុបញ្ចាំ ឬវត្ថុធានាសម្រាប់កម្ចី 70-80 ភាគរយដែលអាជីវកម្មមកពីគ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួមក្នុងគម្រោងនេះ។ ដូច្នេះ វាជួយកាត់បន្ថយវត្ថុបញ្ចាំដែលអ្នកខ្ចីត្រូវមាន។ គម្រោងធានាឥណទាននេះដែលផ្តល់ជូនដោយសាជីវកម្មធានាឥណទានកម្ពុជា នឹងបំពេញបន្ថែមលើគម្រោងកម្ចីមានស្រាប់ ដែលផ្តល់ដោយធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់វិស័យកសិកម្ម។

### កំណើនតម្លៃដឹកជញ្ជូនតាមសមុទ្របានពន្យឺតការនាំចេញអង្កររបស់កម្ពុជា

**ការនាំចេញអង្កររបស់កម្ពុជាទទួលរងផលប៉ះពាល់ពីការកើនឡើងនៃតម្លៃដឹកជញ្ជូន ដោយសារការខ្វះទូកុងតឺន័រជាបណ្តោះអាសន្ន។** យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា កង្វះទូកុងតឺន័របានបង្កើនតម្លៃទូកុងតឺន័រទទេដែលមានប្រវែង 20 ហ្វូត និង 40 ហ្វូត យ៉ាងខ្លាំង នៅខែធ្នូ ឆ្នាំ 2020 និងខែ មករា ឆ្នាំ 2021។ កង្វះទូកុងតឺន័រជាបណ្តោះអាសន្នធ្វើឱ្យប៉ះពាល់ដល់ការនាំចេញអង្ករ ជាពិសេស ការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប។ ការនាំចេញទំនិញកសិកម្ម ជាពិសេសអង្ករ ដែលជាទំនិញមានទម្ងន់ធ្ងន់ និងតម្លៃថោក ធៀបនឹងផលិតផលផ្សេងទៀត ដូចជា សម្លៀកបំពាក់ និងសម្ភារអេឡិចត្រូនិក ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការកើនឡើងនៃអត្រាតម្លៃដឹកជញ្ជូនតាមសមុទ្រ។ ជាលទ្ធផល នៅត្រីមាសទីមួយក្នុងឆ្នាំ 2021 ការនាំចេញអង្ករថយចុះ 33.4 ភាគរយ ឬស្មើនឹង 153,000 តោន។ ខណៈដែលវិធានការការពារពាណិជ្ជកម្មដែលសហភាពអឺរ៉ុបដាក់មកលើអង្ករកម្ពុជានឹងបញ្ចប់នៅខែមករាឆ្នាំ2022[18]ដែលជួយសន្សំចំណាយរបស់អ្នកនាំចេញអង្ករចំនួន 125 អឺរ៉ូក្នុងមួយតោន អត្រាខ្ពស់នៃតម្លៃដឹកជញ្ជូនតាមសមុទ្រប្រហែលជានៅដដែល។ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា អត្រាតម្លៃដឹកជញ្ជូនតាមសមុទ្រ គឺចាប់ពី 150 ដុល្លារ រហូតដល់ 250 ដុល្លារក្នុងមួយតោន នៅខែឧសភា ឆ្នាំ 2021 ធៀបនឹងអត្រាចាប់ពី 40 ដុល្លារ រហូតដល់ 50 ដុល្លារក្នុងមួយតោននៅឆ្នាំ 2020។

**នៅឆ្នាំ 2020 កម្ពុជាបាននាំចេញអង្ករចំនួន 690,000 តោន (ក្នុងនោះ 80 ភាគរយគឺជាអង្ករផ្កាម្លិះ) និងរកចំណូលបាន 538 លានដុល្លារ។** ចិនជាទីផ្សារធំជាងគេ ដែលមានចំណែក 41.8 ភាគរយនៃការនាំចេញអង្ករសរុបរបស់កម្ពុជា កើនពី 35.5 ភាគរយនៅឆ្នាំ 2019។ ក្នុងរយៈពេលបីខែដំបូងក្នុងឆ្នាំ 2021 ទីផ្សារចិនបានពង្រីកបន្ថែមទៀត ដោយស្រូបយក 55.5 ភាគរយនៃការនាំចេញអង្កររបស់កម្ពុជា។ ទីផ្សារសហភាពអឺរ៉ុប (រួមទាំងចក្រភពអង់គ្លេស ន័រវ៉េស អ៊ុយក្រែន និងស៊ែប) ជាទីផ្សារធំជាងគេទីពីរ។ ដោយមិនគិតពីការដាក់វិធានការការពារដោយសហភាពអឺរ៉ុប ការនាំចេញអង្កររបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបកើនឡើងបន្តិច ឬស្មើនឹង 203,000 តោន (30 ភាគរយនៃ

15 ការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា កើនឡើងនៅឆ្នាំ 2020។ សូមមើល https://www.phnompenhpost.com/business/hope-sprouting-growers-more-farming-contracts-inked និង https://www.phnompenhpost.com/business/fifty-nine-communities-enter-agri-contracting។

16 ទំព័រ Facebook របស់ស្ថានទូតចិន។

17 គម្រោងធានាសាជីវកម្មរបស់កម្ពុជា https://www.cgcc.com.kh/។

18 សហភាពអឺរ៉ុបបានដាក់វិធានការការពារលើអង្ករនាំចូលពីកម្ពុជា។ នៅថ្ងៃទី 18 ខែ មករា ឆ្នាំ 2019 សហភាពអឺរ៉ុបបានយកពន្ធគយធម្មតាលើផលិតផលអង្កររបស់កម្ពុជា ចំនួន 175 អឺរ៉ូក្នុងមួយតោន នៅឆ្នាំទីមួយ និងបន្ថយមកត្រឹម 150 អឺរ៉ុបក្នុងមួយតោននៅឆ្នាំទីពីរ និងចំនួន 125 ដុល្លារក្នុងមួយតោននៅឆ្នាំទីបី។ សូមមើល https://trade.ec.europa.eu/doclib/press/index.cfm?id=1970។

ការនាំចេញសរុបនៅឆ្នាំ 2020)។ គិតត្រឹមបំណាច់ខែ មីនា ឆ្នាំ 2021 តម្លៃមធ្យមសម្រាប់ផលិតផលដឹកដល់កប៉ាល់នៃអង្ករម្លិះក្រអូបដែលមានគុណភាពខ្ពស់របស់កម្ពុជា (ម្លិះអង្គរ) អង្ករម្លិះស្តង់ដារ និងអង្ករសគ្រាប់វែង នៅតែមានភាពប្រសើរ ដោយសម្រាប់អង្ករម្លិះក្រអូប មានតម្លៃពី 820 ដុល្លារទៅ 1,350 ដុល្លារក្នុងមួយតោន សម្រាប់អង្ករម្លិះស្តង់ដារគឺ 730 ដុល្លារក្នុងមួយតោន និងសម្រាប់អង្ករសគ្រាប់វែងគឺពី 540 ដុល្លារទៅ 920 ដុល្លារក្នុងមួយតោន។

### ការបិទខ្ទប់ដែលមិនធ្លាប់មាន បានប៉ះពាល់ថែមទៀតលើឧស្សាហកម្មទេសចរណ៍

**ការបិទខ្ទប់ដែលមិនធ្លាប់មាននាពេលថ្មីៗនេះ បានប៉ះពាល់ថែមទៀតលើសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ដែលថ្មីៗនេះពឹងផ្អែកស្ទើរតែទាំងស្រុងលើតម្រូវការក្នុងស្រុក បន្ទាប់ពីការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរអន្តរជាតិ។** គិតត្រឹមខែ ធ្នូ ឆ្នាំ 2020 ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាកម្ពុជា ថយចុះចំនួន 80.2 ភាគរយ ធៀបនឹងឆ្នាំមុន ស្មើនឹង 1.31 លាននាក់ (រូប 16)។ នៅអំឡុងខែ មីនា-មេសា ឆ្នាំ 2021 ការរឹតត្បិតការធ្វើដំណើរក្នុងស្រុក និងការបិទខ្ទប់ ត្រូវបានអនុវត្តដោយសារការផ្ទុះឡើងជាថ្មីនៃជំងឺកូវីដ 19 ក្នុងសហគមន៍។ ប្រជាជនត្រូវបានណែនាំឱ្យស្នាក់នៅផ្ទះ។ ជាលទ្ធផល ឧស្សាហកម្មទេសចរណ៍ បដិសណ្ឋារកិច្ច លក់រាយ និងដឹកជញ្ជូន បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ព្រោះរហូតមកទល់បច្ចុប្បន្ននេះ ឧស្សាហកម្មទាំងនេះនៅតែពឹងផ្អែកស្ទើរតែទាំងស្រុងលើទេសចរណ៍ក្នុងស្រុក។ នៅឆ្នាំ 2020 ភ្ញៀវទេសចរក្នុងស្រុកជាង 1 លាននាក់បានទៅទស្សនាតំបន់ទេសចរណ៍ (តំបន់ឆ្នេរ តំបន់វប្បធម៌ និងតំបន់ទេសចរណ៍ធម្មជាតិ) នៅទូទាំងប្រទេសក្នុងថ្ងៃឈប់សម្រាកធំៗ ដូចជា បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងបុណ្យអុំទូក អកអំបុក និងបណ្តែតប្រទីប ដោយគ្មានភ្ញៀវទេសចរបរទេស (ឬមានចំនួនតិច)។

**ចំនួនភ្ញៀវទេសចរអន្តរជាតិដែលធ្វើដំណើរតាមជើងហោះហើរមកកាន់ក្រុងសៀមរាប ជាទីដែលសំបូរដោយប្រាង្គប្រាសាទអង្គរ ថយចុះចំនួន 56.6 ភាគរយ** ដោយទទួលបានភ្ញៀវទេសចរអន្តរជាតិត្រឹមតែ 0.7 លាននាក់នៅឆ្នាំ 2020។ ដោយសារតែតំបន់ប្រាង្គប្រាសាទអង្គរជាតំបន់ទេសចរណ៍ដ៏មានប្រជាប្រិយបំផុតនៅកម្ពុជា ផលប៉ះពាល់អវិជ្ជមាននេះបានប៉ះពាល់ដល់សេដ្ឋកិច្ច។ ជាលទ្ធផល ចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់ប្រាង្គប្រាសាទអង្គរ ដែលកើនដល់ 100 លានដុល្លារនៅអំឡុងពេលមុនវិបត្តិ បានថយមកត្រឹម 18.6 លានដុល្លារ ឬថយចុះ 81.2 ភាគរយធៀបនឹងឆ្នាំមុន។ ជំងឺរាតត្បាតកូវីដ 19 និងការផ្ទុះឡើងក្នុងសហគមន៍ អាចនឹងបន្តតទៅមុខទៀត។ ដូច្នេះ វិស័យសេវា ជាពិសេសឧស្សាហកម្មទេសចរណ៍ បដិសណ្ឋារកិច្ច លក់រាយ និងដឹកជញ្ជូន អាចប្រឈមនឹងការធ្លាក់ចុះយូរបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន។ ក្នុងអំឡុងពេលមុនវិបត្តិជំងឺកូវីដ 19 វិស័យទេសចរណ៍របស់កម្ពុជាគឺជាចលករកំណើនមួយដ៏សំខាន់។ យោងតាមក្រសួងទេសចរណ៍ ចំណូលពីវិស័យទេសចរណ៍ស្មើនឹង 12.1 ភាគរយនៃ ផសស ខណៈដែលវិស័យនេះផ្តល់ការងារផ្ទាល់ចំនួន 630,000 នៅឆ្នាំ 2019។

### ការថយចុះនៃការប្រើប្រាស់រងផលប៉ះពាល់បន្ថែមទៀតដោយសារការបិទខ្ទប់នាពេលថ្មីនេះ

**ទោះបីជាកម្ពុជាមានអត្រាទាបនៃករណីឆ្លងជំងឺកូវីដ 19 នៅឆ្នាំ 2021 ក្តី ក៏ការប្រើប្រាស់ក្នុងស្រុកនៅតែថយចុះ។** នៅឆ្នាំ 2020 កំណើននៃការនាំចូលទំនិញប្រើប្រាស់ និងទំនិញជាប់ធន់បន្តថយចុះ និងមានគន្លងអវិជ្ជមាន។ ការប្រើប្រាស់ក្នុងស្រុកទទួលរងផលប៉ះពាល់បន្ថែមទៀតដោយសារការកើនឡើងនៃករណីឆ្លងជំងឺកូវីដ 19 នៅខែ មេសា ឆ្នាំ 2021។ ជាលទ្ធផល ការនាំចូលចំណីអាហារថយចំនួន -45.3 ភាគរយ ក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021 ថយពី -4.9 ភាគរយនៅឆ្នាំ 2020 (រូប 17) ខណៈដែលការនាំចូលសាំងថយចុះ 12.2 ភាគរយក្នុង

**រូប 16 ៖ ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំណូលពីការចូលទស្សនាតំបន់អង្គរ ធ្លាក់ចុះ**
(ការប្រែប្រួលភាគរយនៅឆ្នាំនេះ ធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 17 ៖ ការនាំចូលទំនិញប្រើប្រាស់ងើបឡើងវិញយឺតៗ**
(ការប្រែប្រួលភាគរយនៅឆ្នាំនេះ ធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 18 ៖ អតិផរណាថយចុះបន្ថែមទៀត**
(ការរួមចំណែកដល់អតិផរណារយៈពេល 12 ខែ) (ភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

រយៈពេលបួនខែដំបូងក្នុងឆ្នាំ 2020 ថយពី 24.4 ភាគរយនៅឆ្នាំ 2020។ ការនាំចូលទំនិញជាប់ធន់ ដូចជា យានយន្តដឹកអ្នកដំណើរ និងម៉ូតូ ក៏ថយចុះផងដែរ ដោយការនាំចូលយានយន្តដឹកអ្នកដំណើរ ថយ -25.8 ភាគរយ ចំណែកការនាំចូលម៉ូតូថយ 28.7 ភាគរយ ក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021។ យោងតាមលទ្ធផលរកឃើញពីការអង្កេតលើសន្ទុះអាជីវកម្ម នៅឆ្នាំ 2020 នៅពេលមានការលើកការរឹតត្បិតការធ្វើដំណើរ និងការបិទខ្ទប់ បន្ទាប់ពីការផ្ទុះរលកទីមួយនៃជំងឺកូវីដ 19 នៅកម្ពុជា កាលពីខែ មេសាឆ្នាំ 2020 សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកបានងើបឡើងវិញ។ អាជីវកម្មបានបើកឡើងវិញនៅខែ មិថុនា ឆ្នាំ 2020 ហើយគិតត្រឹមខែ កញ្ញា ឆ្នាំ 2020 អាជីវកម្មចំនួន 89 ភាគរយបានបើកទ្វារ (សូមមើលរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ វិច្ឆិកា ឆ្នាំ 2020)។ បើទោះជាគ្មានទិន្នន័យសម្រាប់ពេលថ្មីៗនេះ យ៉ាងហោចណាស់ ផ្នែកខ្លះនៃផលចំណេញដែលត្រូវបានរាយការណ៍នៅឆ្នាំ 2020 ដោយការអង្កេតលើសន្ទុះអាជីវកម្មនេះ អាចត្រូវបានបង្វែរ បន្ទាប់ពីការអនុវត្តការបិទខ្ទប់ដែលមិនធ្លាប់មាននៅខែ មេសា ឆ្នាំ 2021។ទោះជាយ៉ាងណា ការធ្លាក់ចុះនៃការនាំចូលទំនិញប្រើប្រាស់ និងទំនិញជាប់ធន់មានភាពប្រសើរក្នុងរយៈពេលបួនខែដំបូងក្នុងឆ្នាំ 2021។ ការប្រើប្រាស់ក្នុងស្រុកអាចងើបឡើងវិញបន្តិចម្តងៗ។ ដោយសារតែចំណែកនេះមានចំនួនប្រមាណ 70 ភាគរយនៃ ផសស ការស្តារឡើងវិញនៃការប្រើប្រាស់ក្នុងស្រុកនឹងជំរុញកំណើនសេដ្ឋកិច្ច។

### អតិផរណាថយចុះបន្ថែមទៀតដោយសារតម្លៃអាហារថយចុះ

**ដោយសារតែអាហារថយចុះ អត្រាអតិផរណាគោលបានថយចុះថែមទៀតចំនួន 1.7 ភាគរយធៀបនឹងឆ្នាំមុន នៅខែ កុម្ភៈ ឆ្នាំ 2020 ថយពី 2.9 ភាគរយនៅបំណាច់ឆ្នាំ 2020។** នៅខែ កុម្ភៈ ឆ្នាំ 2021 ការថយចុះនៃសន្ទស្សន៍រងចំណីអាហារ ជាមូលហេតុនាំឱ្យថយចុះអត្រាអតិផរណាគោល ខណៈដែលសន្ទស្សន៍រងលំនៅដ្ឋាន ទឹកភ្លើង ការដឹកជញ្ជូន និងសន្ទស្សន៍រងផ្សេងទៀតបន្តថយចុះ។ នៅខែ កុម្ភៈ ឆ្នាំ 2021 តម្លៃអាហារ (លើកលែងតែសាច់ជ្រូក) បានថយចុះ ក្នុងកន្ត្រកអតិផរណាអាហារនៃសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់នៅកម្ពុជា ដែលមានចាប់ពីអង្ករ សាច់គោ សាច់មាន់ និងត្រី រហូតដល់បន្លែ និងផ្លែឈើ។ ទោះជាយ៉ាងណា តម្លៃលក់រាយនៃផលិតផលប្រេងកាត ដូចជា សាំង និងប្រេងម៉ាស៊ូត បានកើនឡើង។ នៅខែ កុម្ភៈ ឆ្នាំ 2021 ការរួមចំណែកនៃសន្ទស្សន៍រងអាហារ និងភេសជ្ជៈក្រៅពីគ្រឿងស្រវឹង ដល់អតិផរណា មានចំនួន 1.4 ភាគរយ ថយពី 2.59 ភាគរយក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ 2020 ខណៈដែលការរួមចំណែកនៃសន្ទស្សន៍រងលំនៅដ្ឋាន (និងទឹកភ្លើង) ដល់អតិផរណា កើនចំនួន 0.22 ភាគរយ កើនពី 0.16 ភាគរយ រីឯការរួមចំណែកនៃសន្ទស្សន៍រងការដឹកជញ្ជូនដល់អតិផរណា គឺ -0.05 កើនពី -0.04 (រូប 18)។

**ស្ថិរភាពអត្រាប្តូរប្រាក់បានជួយរក្សាតម្លៃលក់រាយដែលទូទាត់ជារូបិយវត្ថុក្នុងស្រុក។** តម្លៃណូមីណលនៃប្រាក់រៀលខ្មែរធៀបនឹងប្រាក់ដុល្លារអាមេរិក ស្ថិតក្នុងចន្លោះប្រែប្រួល ±2 ភាគរយ (រូប 19)។ អត្រាប្តូរប្រាក់នៅតែមានស្ថិរភាព ក្នុងអត្រា 4,072 រៀលក្នុងមួយដុល្លារអាមេរិក នៅបំណាច់ខែ ឧសភា ឆ្នាំ 2021 ធៀបនឹងអត្រា 4,070 រៀលក្នុងមួយដុល្លារអាមេរិកនៅអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ ក្រៅពីនេះ តម្លៃណូមីណលនៃប្រាក់រៀលខ្មែរធៀបនឹងប្រាក់បាតថៃ ប្រាក់ដុងវៀតណាម និងប្រាក់យន់ចិន ក៏មានស្ថិរភាពដែរ។ ចំណុចនេះបានជួយរក្សាតម្លៃផលិតផលនាំចូល រួមទាំង ផលិតផលនាំចូលពីប្រទេសជិតខាងកម្ពុជា ដែលសុទ្ធតែជាដៃគូនាំចូលសំខាន់ៗរបស់កម្ពុជា។

### កំណើនការនាំចេញប្រភេទផលិតផលថ្មីបានជួយមួយផ្នែកដល់ការរក្សាស្ថិរភាពនៃស្ថានភាពក្រៅប្រទេស

**នៅឆ្នាំ 2020 ស្ថានភាពក្រៅប្រទេសរបស់កម្ពុជាមានស្ថិរភាពមួយផ្នែកដោយសារតែការកើនឡើងនៃការនាំចេញទំនិញថ្មីៗ។** ការនាំចេញទំនិញ (រួមទាំង មាស) កើន 17.2 ពាន់លានដុល្លារ

**រូប 19 ៖ អត្រាប្តូរប្រាក់ណូមីណល មានស្ថិរភាព ក្នុងរង្វង់ ±2**
(ប្រាក់រៀលក្នុងមួយដុល្លារអាមេរិក ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)



ប្រភព ៖ អាជ្ញាធរកម្ពុជា

**រូប 20 ៖ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមានស្ថិរភាព**
(% នៃ ផសស)




ប្រភព ៖ អាជ្ញាធរកម្ពុជា
សម្គាល់ ៖ RHS=ខាងស្តាំ

**រូប 21 ៖ ទុនបម្រុងអន្តរជាតិសរុបកើនឡើង**
(ពាន់លានដុល្លារ)




ប្រភព ៖ អាជ្ញាធរកម្ពុជា
សម្គាល់ ៖ RHS=ខាងស្តាំ

ឬស្មើនឹងកំណើន 16.7 ភាគរយនៅឆ្នាំ 2020។ ការនាំចេញទាំងនេះ រួមមាន មាស ទំនិញកសិកម្ម កង់ គ្រឿងបន្លាស់អគ្គិសនី ខ្សែភ្លើង និងគ្រឿងបង្គុំ គ្រឿងបន្លាស់យានយន្ត និងការនាំចេញផ្សេងទៀត។ ការនាំចេញមាសកើនដល់ 3.1 ពាន់លានដុល្លារនៅឆ្នាំ 2020។ ការនាំចេញទំនិញ (មិនគិត មាស) ថយបន្តិចមកត្រឹម 14.5 ពាន់លានដុល្លារ ស្មើនឹងការថយចុះ 1.1 ភាគរយនៅឆ្នាំ 2020។ ដូចបានពិភាក្សាខាងលើ ការនាំចេញផលិតផលប្រពៃណីរបស់កម្ពុជា ដូចជា សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ រងផលប៉ះពាល់ដោយសារវិបត្តិតម្រូវការសកល។ ទន្ទឹមនឹងនេះ ការនាំចូលទំនិញថយចុះដោយសារការថយចុះនៃការនាំចូលទំនិញជាប់ធន់ និងសម្ភារសំណង់ ដែលបណ្ដាលមកពីការថយចុះនៃការប្រើប្រាស់ និងភាពនៅទ្រឹងនៃវិស័យសំណង់។ ជាលទ្ធផល គណនីចរន្តត្រូវបានប៉ាន់ស្មានថានឹងមានចំនួន 9.9 ភាគរយនៃ ផសស នៅឆ្នាំ 2020 ធៀបនឹង 9.7 ភាគរយនៃ ផសស នៅឆ្នាំ 2019។ ឱនភាពគណនីចរន្តត្រូវបានប៉ាន់ស្មានថានឹងទទួលបានហិរញ្ញប្បទានពេញលេញពីលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស។

**លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសដែលមានភាពធន់បានផ្តល់ហិរញ្ញប្បទានពេញលេញដល់ឱនភាពគណនីចរន្ត។** នៅឆ្នាំ 2020 លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសដែលមានចំនួន 3.4 ពាន់លានដុល្លារ ឬស្មើនឹង 13.6 ភាគរយនៃ ផសស ធៀបនឹងចំនួន 3.5 ពាន់លានដុល្លារ ឬស្មើនឹង 13.2 ភាគរយនៃ ផសស នៅឆ្នាំ 2019 បានជួយទ្រទ្រង់វិស័យខាងក្រៅ (រូប 20)។ ទោះជាយ៉ាងណា ប្រាក់បញ្ញើសរុបរបស់កម្មករថយចុះចំនួន 13.5 ភាគរយនៅឆ្នាំ 2020។ ការរក្សាបានស្ថានភាពក្រៅប្រទេសរបស់កម្ពុជា ផ្ដល់លទ្ធភាពឱ្យធនាគារកណ្តាលកៀរគរទុនបម្រុងអន្តរជាតិបានបន្ថែមទៀត។ ទុនបម្រុងអន្តរជាតិសរុបកើន 21.2 ពាន់លានដុល្លារ គិតត្រឹមបំណាច់ឆ្នាំ 2020 ឬស្មើនឹងកំណើន 13.1 ភាគរយ (ការនាំចេញរយៈពេល 10 ខែ)។ ទ្រទ្រង់ដោយលំហូរចូលមូលធនជាបន្តបន្ទាប់ ទុនបម្រុងដោះដូរបរទេស ដែលជាសមាសភាគដ៏ធំនៃទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជា កើនឡើងនៅឆ្នាំ 2020 (រូប 21)។

### គោលនយោបាយរូបិយវត្ថុបែបបន្ធូរបន្ថយនៅតែបន្ត

**ធនាគារកណ្តាលបន្តគាំទ្រដល់សន្ទនីយភាព។** ធនាគារជាតិនៃកម្ពុជាបានសម្រេចក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដែលបានធ្វើឡើងនៅថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ 2021 ដូចតទៅ ទីមួយ បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ ទីពីរ ផ្តល់សន្ទនីយភាពប្រាក់រៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាដោយផ្អែកតាមអត្រាប្តូរប្រាក់រៀល និងលក្ខខណ្ឌសន្ទនីយភាព និងទីបី រក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចត្រឹម 7 ភាគរយ ទាំងសម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក រហូតដល់បំណាច់ឆមាសទីមួយក្នុងឆ្នាំ 2021 និងយោងទៅតាមភាពចាំបាច់។ នៅខែ ឧសភា ឆ្នាំ 2021 ធនាគារកណ្តាលបានចេញវិធានការបន្ធូរបន្ថយផ្នែករូបិយវត្ថុ (លើកទីបី) ដើម្បី ទីមួយ រក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចត្រឹម 7 ភាគរយទាំងសម្រាប់ប្រាក់បញ្ញើ និងកម្ចីជាប្រាក់រៀល និងប្រាក់ដុល្លាររហូតដល់មានការជូនដំណឹងបន្ថែមទៀត និងទីពីរ អនុញ្ញាតឱ្យវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ បន្តរៀបចំកម្ចីឡើងវិញរហូតដល់បំណាច់ឆ្នាំ 2021[19]។ នៅឆ្នាំ 2020 ធនាគារកណ្តាលបានផ្អាកការអនុវត្តពេញលេញនូវទុនតម្កល់ ដើម្បីរក្សាអត្រាកំណត់បច្ចុប្បន្ននៅត្រឹម 50 ភាគរយ[20]។ នៅខែ មីនា ឆ្នាំ 2020 ធនាគារកណ្តាលបានចេញសេចក្តីណែនាំឱ្យគ្រប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ធ្វើការរៀបចំកម្ចីឡើងវិញដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ទន្ទឹមនឹងការសម្រាលបន្ទុករបស់ឥណវន្តដែលប្រឈមនឹងការថយចុះប្រាក់ចំណូលដោយសារជំងឺកូវីដ 19[21]។ នៅឆ្នាំ 2020 ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ 19 លើអ្នកខ្ចីវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុបានរៀបចំឡើងវិញនូវគណនីកម្ចីចំនួន 285,000 គណនី ស្មើនឹង 4.2 ពាន់លានដុល្លារ[22]។ វិធានការរៀបចំកម្ចីឡើងវិញ បន្តរហូតដល់ឆ្នាំ 2021[23]។

### កំណើនរូបិយវត្ថុទូលាយនៅតែរឹងមាំ ដោយសារតែកំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេស

**កំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលថយចុះយ៉ាងខ្លាំងនៅត្រីមាសទីពីរក្នុងឆ្នាំ 2020 បានកើនឡើងចាប់ពីពេលនោះមក ដែលនាំឱ្យមានកំណើនរូបិយវត្ថុទូលាយបន្តិចម្តងៗ។** កំណើនរូបិយវត្ថុទូលាយរបស់កម្ពុជាកើនចំនួន 15.2 ភាគរយធៀបនឹងឆ្នាំមុន គិតត្រឹមខែ កុម្ភៈ ឆ្នាំ 2021 កើនពី 9.7 ភាគរយធៀបនឹងឆ្នាំមុននៅខែ មេសា ឆ្នាំ 2020។ ទោះជាយ៉ាងណា កំណើននេះនៅតែទាបជាងកំណើនមុនពេលមានវិបត្តិដែលមានចំនួន 18.2 ភាគរយនៅបំណាច់ឆ្នាំ 2019។ ការស្តារឡើងវិញដំបូងនៃកំណើនរូបិយវត្ថុទូលាយរហូតដល់ដើមឆ្នាំ 2021 រួមចំណែកដោយការកើនឡើងនៃប្រាក់បញ្ញើជារូបិយវត្ថុបរទេស។ ក្នុងកំណើនរូបិយវត្ថុទូលាយចំនួន 15.2 ភាគរយគិតត្រឹមខែ កុម្ភៈ ឆ្នាំ 2020 ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយវត្ថុបរទេស (និងប្រាក់បញ្ញើផ្សេងទៀត) មានចំនួន 11.7 ភាគរយ ខណៈដែលប្រាក់បញ្ញើដែលអាចផ្ទេរបានរួមចំណែក 2.2 ដល់កំណើន

19 សូមមើលសេចក្តីប្រកាសចុះថ្ងៃទី 21 ខែ ឧសភា ឆ្នាំ 2021 ស្តីពីវិធានការបន្ធូរបន្ថយផ្នែករូបិយវត្ថុ (លើកទីបី) របស់ធនាគារជាតិនៃកម្ពុជា។

20 ទ្រនាប់ដើមទុនខនស៊ើវេសិន ត្រូវបានបង្កើតឡើងដើម្បីធានាថា ស្ថាប័ននានាបង្កើតទ្រនាប់ដើមទុនក្រោមស្ថានភាពហិរញ្ញវត្ថុធម្មតា ដែលអាចដកយកបាននៅពេលមានការខាតបង់។ សូមមើលប្រកាសចុះថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំ 2018 និងរបាយការណ៍ពាក់កណ្តាលឆ្នាំ 2020 របស់ធនគារជាតិនៃកម្ពុជា។ សូមមើល៖ https://www.nbc.org.kh/download_files/legislation/prakas_eng/3.Prakas_on_Capital_Buffer_in_BFIs_ENG.pdf។

21 សូមមើលសារាចរណែនាំចុះថ្ងៃទី 27 ខែ មីនា ឆ្នាំ 2020 ធនាគារជាតិនៃកម្ពុជា “កម្ចីដែលត្រូវបានចរចាឡើងវិញ” ឬ “កម្ចីដែលត្រូវបានរៀបចំឡើងវិញ” សំដៅលើកម្ចីដែលត្រូវបានកំណត់កាលវិភាគឡើងវិញ ឬត្រូវបានផ្តល់ហិរញ្ញប្បទានឡើងវិញ អនុលោមតាមកិច្ចព្រមព្រៀងដែលកំណត់ពីកាលវិភាគទូទាត់សងថ្មីតាមដំណាក់កាល ដោយសារស្ថានភាពហិរញ្ញវត្ថុមិនល្អ និង/ឬអសមត្ថភាពរបស់អ្នកខ្ចីក្នុងការទូទាត់សងកម្ចីទៅតាមការព្រមព្រៀងពីដំបូង។

22 ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2021

23 សេចក្តីថ្លែងការណ៍រួមរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ថ្ងៃទី 7 ខែ មេសា ឆ្នាំ 2021។

រូបិយវត្ថុទូលាយ ហើយរូបិយវត្ថុដែលកំពុងចរាចរណ៍រួមចំណែក 1.3 ភាគរយដល់កំណើនរូបិយវត្ថុទូលាយ (រូប 22)។

### កំណើនឥណទាន និងប្រាក់បញ្ញើក្នុងស្រុក មានស្ថិរភាព ដោយទទួលបានទំនុកចិត្តកាន់តែច្រើន

**កំណើនឥណទានក្នុងស្រុក ដែលថយចុះយ៉ាងឆាប់រហ័សនៅត្រីមាសទីពីរ និងត្រីមាសទីបីក្នុងឆ្នាំ 2020 មានស្ថិរភាព ដែលបង្ហាញពីការកើនឡើងនៃតម្រូវការឥណទាន ដោយសារតែកំណើនចំណាប់អារម្មណ៍លើការវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យ (សូមមើលការពិភាក្សាស្តីពីការផ្តល់ឥណទានដោយគ្រឹះស្ថានអាជីវកម្មក្នុងផ្នែកខាងក្រោម)។** តាមរយៈគោលនយោបាយសម្របសម្រួលផ្នែករូបិយវត្ថុរបស់ធនាគារកណ្តាល ការផ្តល់ឥណទានក្នុងស្រុកដល់វិស័យឯកជន បានកើនចំនួន 19.5 ភាគរយ គិតត្រឹមខែ កុម្ភៈ ឆ្នាំ 2021 ធៀបនឹងកំណើន 17.7 ភាគរយនៅបំណាច់ឆ្នាំ 2020 ដោយសារតែសកម្មភាពសេដ្ឋកិច្ចមានភាពប្រសើរឡើង (រូប 23)។ ផលធៀបឥណទាន-ផសស កើនពី 114.2 ភាគរយនៅឆ្នាំ 2019 ដល់ 142.2 ភាគរយនៅឆ្នាំ 2020។ កំណើនប្រាក់បញ្ញើដែលថយចំនួន 7.3 ភាគរយ ធៀបនឹងឆ្នាំមុននៅខែ មេសា ឆ្នាំ 2020 បានកើនដល់ 15.4 ភាគរយ គិតត្រឹមខែ កុម្ភៈ ឆ្នាំ 2021។ ដោយសារស្ថិរភាពអត្រាការប្រាក់នៃប្រាក់បញ្ញើ ការស្តារឡើងវិញនៃកំណើនឥណទាន បង្ហាញពីការកើនឡើងនៃទំនុកចិត្ត និងការស្តារសកម្មភាពសេដ្ឋកិច្ចដែលមានផលវិជ្ជមានលើសន្ទនីយភាពរបស់វិស័យសាជីវកម្ម (និងគ្រួសារ) ដែលបង្កើនសមត្ថភាពរបស់វិស័យទាំងនេះក្នុងការសន្សំប្រាក់។ លើសពីនេះទៀត ឥណទានក្នុងស្រុកដែលផ្តល់ហិរញ្ញប្បទានដល់វិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើង ដែលបង្ហាញពីចំណាប់អារម្មណ៍ថ្មីលើការវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យ។ បន្ទាប់ពីបានថយចុះមកត្រឹម 6.9 ភាគរយក្នុងរយៈពេល 2.5 ឆ្នាំ នៅខែ សីហា ឆ្នាំ 2020 ការរួមចំណែកនៃវិស័យសំណង់ និងអចលនទ្រព្យ ដល់កំណើនឥណទានក្នុងស្រុក បានកើនឡើងវិញចំនួន 9.6 ភាគរយនៅខែ មីនា ឆ្នាំ 2021 (រូប 24)។ គិតត្រឹមខែ មីនា ឆ្នាំ 2021 មានឥណទានមិនទាន់សងសរុបចំនួន 10.5 ពាន់លានដុល្លារ ដែលត្រូវបានផ្តល់ជូនវិស័យសំណង់ អចលនទ្រព្យ និងបញ្ចាំ។

**ការផ្តល់កម្ចីសម្រាប់វិស័យកសិកម្មបានកើនឡើង ដែលជាការវិវត្តដ៏ល្អមួយ ដោយសារតែចំណាប់អារម្មណ៍កាន់ខ្លាំងលើការវិនិយោគលើវិស័យកសិកម្មដែលជំរុញដោយលទ្ធភាពខ្ពស់នៃការនាំចេញទំនិញកសិកម្មក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន** (និងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការនាំចូលក្នុងអំឡុងវិបត្តិជំងឺកូវីដ 19)។ គិតត្រឹមខែ ធ្នូ ឆ្នាំ 2020 មានឥណទានមិនទាន់សងសរុបចំនួន 2.4 ពាន់លានដុល្លារដែលត្រូវបានផ្តល់ជូនវិស័យកសិកម្ម កើនពី 1.95 ពាន់លានដុល្លារនៅបំណាច់ឆ្នាំ 2019។ នៅឆ្នាំ 2020 ការរួមចំណែកនៃការផ្តល់កម្ចីដល់វិស័យកសិកម្មដល់កំណើនឥណទានកើន 1.9 ភាគរយ កើនពី 0.5 ភាគរយនៅឆ្នាំ 2019។ គិតត្រឹមខែ មីនា ឆ្នាំ 2021 ការផ្តល់កម្ចីដល់វិស័យកសិកម្មកើន 2.54 ពាន់លានដុល្លារក្នុងឥណទានមិនទាន់សង ឬស្មើនឹងកំណើន 23.1 ភាគរយធៀបនឹងឆ្នាំមុន។ លើសពីនេះទៀត វិស័យកសិកម្មបានទទួលហិរញ្ញប្បទាន 50 លានដុល្លារពីធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទដែលគ្រប់គ្រងដោយរដ្ឋនៅឆ្នាំ 2020។ ក្រោមច្បាប់ស្តីពីថវិកាឆ្នាំ 2021 វិភាជថវិកាចំនួន 82 លានដុល្លារត្រូវបានផ្តល់ជូនធនាគារនេះ។

**ការផ្តល់កម្ចីដល់ឧស្សាហកម្មបដិសណ្ឋារកិច្ចបានថយចុះ ដោយសារតែការថយចុះនៃវិស័យទេសចរណ៍ ដែលទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺកូវីដ 19។** នៅឆ្នាំ 2020 ការរួមចំណែកនៃឧស្សាហកម្មសណ្ឋាគារ និងភោជនីយដ្ឋាន ដល់កំណើនឥណទាន បានថយចំនួន 0.5 ភាគរយ ថយពី 0.9 ភាគរយ ខណៈដែលការរួមចំណែកនៃវិស័យកម្មន្តសាល កើនចំនួន 0.6 ភាគរយ កើនពី 0.2 ភាគរយក្នុងអំឡុងពេលដូចគ្នា។

**រូប 22 ៖ កំណើនរូបិយវត្ថុទូលាយ ងើបឡើងវិញ**
ការរួមចំណែកដល់កំណើនរូបិយវត្ថុទូលាយ (ភាគរយ)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**រូប 23 ៖ ឥណទាន និងបញ្ញើក្នុងស្រុក កើនឡើង**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**រូប 24 ៖ វិស័យសំណង់រួមចំណែកកាន់តែច្រើនដល់កំណើនឥណទាន**
(ភាគរយ)




ប្រភព ៖ អាជ្ញាធរកម្ពុជា

គិតត្រឹមបំណាច់ឆ្នាំ 2020 ផលធៀបកម្ចីមិនដំណើរការដែលបានរាយការណ៍ គឺ 2.7 ភាគរយសម្រាប់វិស័យធនាគារ និង 1.8 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ[24]។ ទោះជាយ៉ាងណាដោយសារដំណើរការរៀបចំកម្ចីឡើងវិញដែលផ្តល់ដោយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផលធៀបកម្ចីមិនដំណើរការខាងលើប្រហែលជាមិនបង្ហាញត្រឹមត្រូវពីកម្រិតនៃវិបត្តិបំណុលក្នុងប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុនោះទេ។

**គិតត្រឹមខែ មីនា ឆ្នាំ 2021 អត្រាការប្រាក់នៃប្រាក់កម្ចី និងប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក មានស្ថិរភាព។** អត្រាប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិកមានអត្រា 3.3 ភាគរយក្នុងមួយឆ្នាំ នៅខែ មីនា ឆ្នាំ 2021 ធៀបនឹងអត្រា 3.2 ភាគរយនៅខែ ធ្នូ ឆ្នាំ 2020។ ក្នុងអំឡុងពេលដូចគ្នានេះ អត្រាកម្ចីមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក មានចំនួន 8.9 ភាគរយក្នុងមួយឆ្នាំ នៅខែ មីនា ឆ្នាំ 2021 និង 9.1 ភាគរយក្នុងមួយឆ្នាំនៅខែ ធ្នូ ឆ្នាំ 2020។ ដោយសារតែសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់របស់កម្ពុជា ធនាគារកណ្តាលមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់បានឡើយ ជាពិសេស អត្រាការប្រាក់នៃប្រាក់កម្ចី និងប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក[25]។

### ភាពក្រីក្រត្រូវបានប៉ាន់ស្មានថាកើនឡើង បើទោះជាមានការឆ្លើយតបរបស់រដ្ឋាភិបាល

**ជំងឺកូវីដ 19 នៅតែបង្កផលប៉ះពាល់អវិជ្ជមានលើភាពក្រីក្រ ខណៈដែលអាជ្ញាធរកម្ពុជាបន្តជួយសម្រួលដល់ការប្រើប្រាស់ក្នុងគ្រួសារ និងជួយដល់ក្រុមហ៊ុនមិនឱ្យក្ស័យធន។** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលមិនធ្លាប់មានរបស់អាជ្ញាធរកម្ពុជា បាននិងកំពុងជួយទ្រទ្រង់ជីវភាពរបស់ប្រជាជនក្រីក្រ និងងាយរងគ្រោះ។ គម្រោងឧបត្ថម្ភសាច់ប្រាក់ (ថ្មី) ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះគឺជាតម្រូវការសំខាន់។ គិតត្រឹមខែ មករា ឆ្នាំ 2021 ប្រជាជនចំនួន 710,929 គ្រួសារ ឬស្មើនឹង 19.5 ភាគរយនៃចំនួនគ្រួសារសរុប បានទទួលការឧបត្ថម្ភសាច់ប្រាក់ពីរដ្ឋាភិបាល។ នៅដើមខែ មិថុនា ឆ្នាំ 2020 ជាពេលដែលចាប់ផ្តើមកម្មវិធីនេះ មានប្រជាជនតែ 560,000 គ្រួសារប៉ុណ្ណោះដែលមានលក្ខណៈសម្បត្តិចូលរួមក្នុងកម្មវិធីនេះ។ គិតត្រឹមខែ តុលា ឆ្នាំ 2020 ប្រជាជនជាង 640,000 គ្រួសារបានទទួលការឧបត្ថម្ភសាច់ប្រាក់[26]។ ទោះជាយ៉ាងណា សកម្មភាពការងារកំពុងបង្ហាញសញ្ញានៃការងើបឡើងវិញ។ យោងតាមការអង្កេតគ្រួសារ ភាគរយអ្នកតបសម្ភាសន៍ដែលមានការងារធ្វើនៅខែ ធ្នូ ឆ្នាំ 2020 បានវិលទៅរកកម្រិតចាស់នៅខែ ឧសភា និងខែ សីហា ឆ្នាំ 2020 ប៉ុន្តែនៅតែទាបជាងកម្រិតកាលពីមុនវិបត្តិជំងឺកូវីដ 19 (សូមមើលប្រអប់ 3 សម្រាប់ខ្លឹមសារលម្អិតនៃរបកគំហើញពីការអង្កេតនេះ)។ ខណៈដែលចំណែកគ្រួសារដែលរាយការណ៍ពីការថយចុះប្រាក់ចំណូលក្នុងគ្រួសារ ថយចុះតាំងពីខែ ឧសភា ឆ្នាំ 2020 ក្នុងចំណោម 2 គ្រួសារ មាន 1 គ្រួសារបន្តលើកឡើងថា ប្រាក់ចំណូលរបស់ខ្លួនថយចុះ ធៀបនឹងការអង្កេតពីមុន។ ការចូលរួមរបស់កុមារក្នុងសកម្មភាពរៀនសូត្រថយចុះ ដោយសារតែបវេសនកាល និងការបិទសាលារៀនទូទាំងប្រទេសជាលើកទីពីរនៅថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 2020 បន្ទាប់ពីការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍។ ចំនួនគ្រួសារដែលមានកុមារដល់អាយុចូលរៀន (6-17 ឆ្នាំ) ដែលចូលរួមក្នុងសកម្មភាពរៀនសូត្រ ថយពី 92 ភាគរយនៅខែ តុលា ជាកម្រិតមុនពេលមានវិបត្តិជំងឺកូវីដ 19 មកត្រឹម 57 ភាគរយនៅខែ ធ្នូ ឆ្នាំ 2020។

### ការប្រមូលចំណូល មានភាពយឺតយ៉ាវដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ 19

**ការប្រមូលចំណូល ដែលមានភាពល្អប្រសើរនៅឆ្នាំ 2020 ជាអំឡុងពេលដែលប្រមូលបានពន្ធលើប្រាក់ចំណេញច្រើនបំផុតនៅឆ្នាំ 2019 ចាប់ផ្តើមយឺតយ៉ាវ ដោយសារតែផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ 19។** នៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2021 ចំណូលរបស់រដ្ឋាភិបាលមានចំនួន 3.18 ទ្រីលលានរៀល ឬជាការថយចុះ 10.6 ភាគរយធៀបនឹងឆ្នាំមុន មួយភាគធំបណ្តាលមកពីការថយចុះនៃពន្ធលើទំនិញ និងសេវា ដោយសារការប្រើប្រាស់ថយចុះ (រូប 25)[27]។ ចំណូលពន្ធដែលរួមទាំងពន្ធលើទំនិញ និងសេវា ពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណូល និងពន្ធលើចំណេញមូលធន និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ដែលប្រមូលបាននៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2021 ស្មើនឹង 2.68 ទ្រីលលានរៀល ឬជានឹងការថយចុះ 8.7 ភាគរយ។ ស្ថានភាពនេះបណ្តាលមកពីការថយចុះពន្ធលើទំនិញ និងសេវា និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ខណៈដែលពន្ធផ្ទាល់នៅតែមានស្ថានភាពល្អប្រសើរ។ ទន្ទឹមនឹងនេះ ចំណូលមិនមែនពន្ធ បានថយចំនួន 0.69 ទ្រីលានរៀល ជាការថយចុះ 19.8 ភាគរយធៀបនឹងឆ្នាំមុន។

**ទោះបីជាមានការអន្តរាគមក្តី ក៏ចំណាយរបស់រដ្ឋាភិបាលនៅតែអាចទប់ទល់បាន** មានចំនួន 3.19 ទ្រីលលានរៀល ឬកើន 1.5 ភាគរយធៀបនឹងឆ្នាំមុន ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2021 (រូប 26)។ ចំណាយសរុបត្រូវបានជំរុញមួយភាគធំដោយចំណាយមូលធនដែលកើន 18.2 ភាគរយធៀបនឹងឆ្នាំមុនក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2021 ខណៈដែលប្រាក់ឈ្នួល និងសំណងជំងឺចិត្ត បានថយចំនួន 6.8 ភាគរយក្នុងអំឡុងពេលដូចគ្នា។ នៅឆ្នាំ 2021 ចំណែកនៃចំណាយមូលធនដែលទទួលបានមូលនិធិពីខាងក្រៅ បានថយចំនួន 19.0 ភាគរយ ធៀបនឹងចំណាយសរុប ឬស្មើនឹង 49.2 ភាគរយនៃចំណាយមូលធនសរុប មួយផ្នែកធំបណ្តាលមកពីការកើនឡើងនៃចំណាយមូលធន

24 ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2021។

25 ទោះជាយ៉ាងណា ធនាគារកណ្តាលបានដាក់ចេញអត្រាកំណត់អត្រាប្រាក់ការលើកម្ចីអតិបរមា ត្រឹម 18 ភាគរយក្នុងមួយឆ្នាំ នៅខែ មីនាឆ្នាំ 2017។ សូមមើលប្រកាសលេខ B7-017-109 PK ចុះថ្ងៃទី 13 ខែ មីនា ឆ្នាំ 2017។ សូមមើល https://www.nbc.org.kh/download_files/legislation/prakas_eng/Prakas-on-Interest-Rate-Cap-Eng.pdf។

26 បទបង្ហាញដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្ងៃទី 22 ខែ តុលា ឆ្នាំ 2022។

27 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលខែ កុម្ភៈ ឆ្នាំ 2021។

**ប្រអប់ 3 ៖**

## ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ៖ លទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ[1]

**យោងតាមការអង្កេតគ្រួសារតាមទូរស័ព្ទ ការងារមិនទាន់វិលត្រឡប់ទៅរកកម្រិតមុនពេលមានវិបត្តិនោះទេ។** កាលពីមុនការផ្ទុះឡើងនៃជំងឺកូវីដ 19 អ្នកតបសម្ភាសន៍ 82 ភាគរយមានការងារធ្វើ ប៉ុន្តែបន្ទាប់ពីការផ្ទុះឡើងនៃជំងឺនេះ អ្នកតបសម្ភាសន៍ 71 ភាគរយមានការងារធ្វើនៅខែ ឧសភា ឆ្នាំ 2020 និងមានអត្រាដដែលរហូតដល់ខែ តុលា ជាពេលដែលមានការថយចុះការងារបន្ថែមទៀតមកត្រឹម 65 ភាគរយ។ អត្រាការងារកើន 72 ភាគរយនៅខែ ធ្នូ ឆ្នាំ 2020។

**ជំងឺរាតត្បាតកូវីដ 19 នៅតែបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើអាជីវកម្មក្រៅពីកសិដ្ឋាន ដោយតម្រូវការអ្នកប្រើប្រាស់ថយចុះ ដែលធ្វើឱ្យខាតបង់ប្រាក់ចំណូលអាជីវកម្ម** (រូប B 3.1)។ នៅខែ ធ្នូ ឆ្នាំ 2020 គ្រួសារជាងពាក់កណ្តាលដែលធ្វើអាជីវកម្មក្រៅពីកសិដ្ឋាន (58 ភាគរយ) លើកឡើងថា "មិនទទួលបានប្រាក់ចំណូល" ឬ "ទទួលបានប្រាក់ចំណូលតិចតួច" ធៀបនឹងខែមុន។ ទោះបីជាមានការថយចុះយ៉ាងខ្លាំងនៃចំណែកគ្រួសារធ្វើអាជីវកម្មក្រៅពីកសិដ្ឋានដែលលើកឡើងថា "ទទួលបានប្រាក់ចំណូលតិចតួច" ឬ "មិនទទួលបានប្រាក់ចំណូល" នៅខែ ឧសភា ឆ្នាំ 2020 (81 ភាគរយ) ក្តី ក៏គ្មានការថយចុះបន្ថែមទៀតឡើយចាប់តាំងពីខែ តុលា ឆ្នាំ 2020 (54 ភាគរយ)។

**ទោះជាចំណែកគ្រួសារដែលលើកឡើងពីការថយចុះប្រាក់ចំណូលគ្រួសារ ថយចុះតាំងពីខែ ឧសភា ឆ្នាំ 2020 ក្នុងចំណោម 2 គ្រួសារ មាន 1 គ្រួសារនៅតែលើកឡើងថា ប្រាក់ចំណូលគ្រួសាររបស់ពួកគេថយចុះធៀបនឹងការអង្កេតលើកមុន។** ការថយចុះយឺតៗនៃប្រាក់ចំណូលពីកម្លាំងពលកម្ម និងការឧបត្ថម្ភសាច់ប្រាក់ដោយរដ្ឋាភិបាលជូនដល់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 ហាក់បានជួយកាត់បន្ថយការខាតបង់មួយចំនួន។

**ចាប់តាំងពីការដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទូទាំងប្រទេសក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 នៅខែ មិថុនា ឆ្នាំ 2020 មានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនគ្រួសារក្រីក្រ (IDPoor) ដែលបានទទួលជំនួយសង្គមពីរដ្ឋាភិបាល ដែលភាគច្រើនមានទម្រង់ជាការឧបត្ថម្ភសាច់ប្រាក់។** គិតត្រឹមខែ ធ្នូ ឆ្នាំ 2020 គ្រួសារក្រីក្រ (IDPoor) ដែលមានលក្ខណៈសម្បត្តិចំនួន 93 ភាគរយ បានទទួលការឧបត្ថម្ភសាច់ប្រាក់ ហើយគ្រួសារភាគច្រើនក្នុងចំណោមគ្រួសារទាំងនេះបានទទួលការទូទាត់ច្រើនដង។ចំណាយភាគច្រើនរបស់អ្នកទទួលផលពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងវិបត្តិជំងឺកូវីដ19គឺសម្រាប់ការទិញម្ហូបអាហារ។

**អសន្តិសុខស្បៀងមិនមានការប្រែប្រួលនៅចន្លោះខែ តុលា និងខែ ធ្នូ ឆ្នាំ 2020។** ក្នុងចំណោមសំណាកនៃការសិក្សាលើការរស់នៅរបស់ជីវភាព+ (LSMS+) ប្រេវ៉ាឡង់នៃអសន្តិសុខស្បៀងកម្រិតស្រាល ឬធ្ងន់ធ្ងរ គឺ 17 ភាគរយនៅខែ ធ្នូ ដែលស្មើទាំង ប្រជាជនចំនួន 0.5 ដែលរងផលប៉ះពាល់ដោយសារអសន្តិសុខស្បៀងធ្ងន់ធ្ងរ បើធៀបនឹងអសន្តិសុខស្បៀងកម្រិតស្រាល ឬធ្ងន់ធ្ងរចំនួន 17 ភាគរយ និងអសន្តិសុខស្បៀងធ្ងន់ធ្ងរចំនួន 0.7 ភាគរយនៅខែ តុលា។ ក្នុងចំណោមគ្រួសារក្រីក្រ មានការថយចុះដែលមិនមានសារសំខាន់ផ្នែកស្ថិតិ (ទំនុកចិត្ត 95 ភាគរយ) លើប្រេវ៉ាឡង់នៃអសន្តិសុខស្បៀងកម្រិតស្រាល ឬធ្ងន់ធ្ងរ ដោយថយពី 39 ភាគរយនៅខែ តុលា មកត្រឹម 34 ភាគរយ នៅខែ ធ្នូ។

**ការចូលរួមរបស់កុមារក្នុងសកម្មភាពរៀនសូត្រ បានថយចុះ ដោយសារបវសនកាល និងការបិទសាលារៀនទូទាំងប្រទេសជាលើកទីពីរ នៅថ្ងៃទី 30 ខែ វិច្ឆិកាឆ្នាំ2020បន្ទាប់ពីការផ្ទុះជំងឺកូវីដ19ក្នុងសហគមន៍**(រូបB3.2)។ចំនួនគ្រួសារមានកូនដល់អាយុចូលរៀន(6-17ឆ្នាំ)ដែលចូលរួមក្នុងសកម្មភាពរៀនសូត្របានថយពី 92 ភាគរយនៅខែ តុលា ជាកម្រិតមុនពេលមានវិបត្តិជំងឺកូវីដ 19 មកត្រឹម 57 ភាគរយនៅខែ ធ្នូ ឆ្នាំ 2020។ ខុសពីការបិទសាលារៀនទូទាំងប្រទេសនៅលើកដំបូង ដែលមានការណែនាំឱ្យប្តូរទៅជាការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ខណៈដែលឆ្នាំសិក្សាបន្តទៅមុខ ការបិទសាលារៀនលើកទីពីរ បានលុបចោលរយៈពេលសិក្សាដែលនៅសល់ក្នុងឆ្នាំសិក្សា 2019-2020 សម្រាប់សាលារដ្ឋ និងបានផ្តល់ការណែនាំដោយផ្ទាល់ឱ្យសាលាឯកជនផ្អាករយៈពេល 2 សប្តាហ៍ ដោយអនុវត្តការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអំឡុងពេលនេះ។

**រូប B3.1៖ ការប្រែប្រួលប្រាក់ចំណូល បែងចែកតាមប្រភព ចាប់ពីខែ វិច្ឆិកា ឆ្នាំ 2019** (ភាគរយ)




*ប្រភព ៖* ការអង្កេតគ្រួសារតាមទូរស័ព្ទ នៅកម្ពុជា

**រូប B3.2៖ ការចូលរួមរបស់កុមារនៅក្នុងការអប់រំ ឬសកម្មភាពរៀនសូត្រ ក្នុងរយៈពេល 7 ថ្ងៃកន្លងមក** (ភាគរយ)




*ប្រភព ៖* ការអង្កេតគ្រួសារតាមទូរស័ព្ទ នៅកម្ពុជា

*សម្គាល់ ៖* R=ជុំទី...

សម្គាល់ ៖ 1.Karamba et. Al (2021) ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃជំងឺកូវីដ 19 លើគ្រួសារនៅកម្ពុជា ៖ លទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ ជុំទី 4 (ថ្ងៃទី 17 ខែ ធ្នូ ឆ្នាំ 2020-ថ្ងៃទី 12 ខែ មករា ឆ្នាំ 2021) ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ឬតំណភ្ជាប់នៃការពិនិត្យតាមដានជានទាំងស្រុងលើផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារនៅកម្ពុជា។

ដែលទទួលបានហិរញ្ញប្បទានក្នុងស្រុក។ នេះជាលើកដំបូងដែលមូលធនទទួលបានហិរញ្ញប្បទានក្នុងស្រុក កើនលើសមូលធនដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ។ ប្រាក់ឈ្នួលក្នុងវិស័យសាធារណៈនៅតែអាចទប់ទល់បាន។ អាជ្ញាធរកម្ពុជាសម្រេចបាន ឬសម្រេចលើសចំណុចដៅក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមាប្រចាំខែដល់មន្ត្រីរាជការយ៉ាងតិច 1 លានរៀល។ លើសពីនេះទៀត ការឆ្លើយតបទៅនឹងជំងឺរាតត្បាតតម្រូវឱ្យមានការបង្កើនចំណាយសាធារណៈយ៉ាងច្រើន ដែលបានកាត់បន្ថយគម្លាតសារពើពន្ធរបស់អាជ្ញាធរកម្ពុជាសម្រាប់ការបង្កើនប្រាក់ឈ្នួលរបស់មន្ត្រីរាជការបន្ថែមទៀត។ ដោយសារកម្មវិធីអន្តរាគមន៍ជាបន្តបន្ទាប់របស់រដ្ឋាភិបាល ចំណាយសរុបលើអត្ថប្រយោជន៍សង្គម និងឧបត្ថម្ភធន បានកើន 17.4 ភាគរយ ធៀបនឹងឆ្នាំមុនក្នុងរយៈពេល 2 ខែដំបូងក្នុងឆ្នាំ 2021។

**អាជ្ញាធរកម្ពុជាបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់រហូតដល់ខែ មីនា ឆ្នាំ 2021 បន្ទាប់ពីបានដាក់ និងពង្រីកកម្មវិធីនេះយ៉ាងឆាប់រហ័សនៅខែ មិថុនា ឆ្នាំ 2020[28]។** គិតត្រឹមខែ មករា ឆ្នាំ 2021 កម្មវិធីឧបត្ថម្ភសាច់ប្រាក់បានផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះចំនួន 710,929 គ្រួសារ (2.8 លាននាក់) ដែលក្នុងនោះប្រជាជនចំនួន 6,421 គ្រួសាររស់នៅទីក្រុងភ្នំពេញ ប្រជាជន 32,693 គ្រួសារមកពីតំបន់ប្រជុំជនផ្សេងទៀត និងប្រជាជន 671,815 គ្រួសារមកពីតំបន់ជនបទ។ នៅឆ្នាំ 2020 កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះមានកញ្ចប់ថវិកា 300 លានដុល្លារ។ នៅឆ្នាំ 2021 កញ្ចប់ថវិកានៃកម្មវិធីមានចំនួន 200 លានដុល្លារ។ កម្ពុជាអាចពង្រីក និងពង្រឹងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលទើបតែចាប់ផ្តើមឡើងនេះ បានយ៉ាងឆាប់រហ័សដែលកាលពីមុនវិបត្តិជំងឺកូវីដ 19 មិនសូវមានកម្មវិធីរបៀបនេះឡើយ។ សេចក្តីសម្រេចរបស់អាជ្ញាធរកម្ពុជាក្នុងការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ក្នុងទម្រង់ជាការឧបត្ថម្ភសាច់ប្រាក់ជូនដល់គ្រួសារដែលមានករណីស្លាប់ និងឆ្លងជំងឺដែលពាក់ព័ន្ធនឹងជំងឺកូវីដ 19 ក៏ដូចជា ពលរដ្ឋក្រីក្រក្នុងតំបន់បិទខ្ទប់ ត្រូវបានដាក់ចេញនៅខែ ឧសភា ឆ្នាំ 2021 និងចូលជាធរមាននៅខែ មិថុនា ឆ្នាំ 2020[29]។

**មានមេរៀនជាច្រើនពីការដាក់ពង្រាយ ការពង្រីក និងការពង្រឹងកម្មវិធីជំនួយសង្គមរបស់អាជ្ញាធរកម្ពុជាយ៉ាងឆាប់រហ័ស** ជាពិសេសប្រព័ន្ធឧបត្ថម្ភសាច់ប្រាក់ (សូមមើលអត្ថបទផ្តោតពិសេស ស្តីពីការផ្តល់អត្ថប្រយោជន៍សង្គមពីរដ្ឋាភិបាលជូនប្រជាពលរដ្ឋ)។ អត្ថបទផ្តោតពិសេសនេះបង្ហាញពីរបកគំហើញសំខាន់ៗ ពីការសិក្សាលើការទូទាត់អត្ថប្រយោជន៍សង្គម ក្រោមគម្រោង រដ្ឋាភិបាលទៅប្រជាពលរដ្ឋ (G2P) ដែលវាយតម្លៃពីការបង្កើតប្រព័ន្ធទូទាត់សម្រាប់កម្មវិធីជំនួយឧបត្ថម្ភ និងកំណត់មេរៀនពីការទូទាត់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ សម្រាប់កម្មវិធីជំនួយសង្គមទាំងនៅពេលបច្ចុប្បន្ន ពេលអនាគត និងលើសពីនេះ។

### កញ្ចប់ថវិកាអន្តរាគមន៍របស់រដ្ឋាភិបាលមានចំនួន 719 លានដុល្លារ

**កញ្ចប់ថវិកាឆ្នាំ 2021 សម្រាប់អន្តរាគមន៍របស់រដ្ឋាភិបាលមានចំនួន 719 លានដុល្លារ (ធៀបនឹង 823 លានដុល្លារនៅឆ្នាំ 2020)** ក្នុងនោះ កម្មវិធីឧបត្ថម្ភធនប្រាក់ឈ្នួលក្រោមកញ្ចប់ថវិកា 59 លានដុល្លារ ត្រូវបានបែងចែកដើម្បីផ្តល់ឧបត្ថម្ភធនប្រាក់ឈ្នួលមួយផ្នែក ចំនួន 40 ដុល្លារក្នុងមួយខែ រួមនឹងការបណ្តុះបណ្តាលជំនាញបច្ចេកទេស/ជំនាញទន់សម្រាប់កម្មករ ដែលត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកក្នុងឧស្សាហកម្មកាត់ដេរ និងទេសចរណ៍។ គម្រោងផ្តល់ការងារដោយផ្តល់ប្រាក់កម្រៃក្រោមកញ្ចប់ថវិកា 160 លានដុល្លារ បានផ្តល់ការងារនៅទីជនបទតាមរយៈការសាងសង់ ការកែលម្អ និងការថែទាំផ្លូវជនបទ ប្រព័ន្ធបង្ហូរទឹក និងធារាសាស្ត្រខ្នាតតូច។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្រោមទំហំទឹកប្រាក់ 200 លានដុល្លារបានឧបត្ថម្ភសាច់ប្រាក់ប្រចាំខែដល់ជនក្រីក្រ និងងាយរងគ្រោះ ដែលត្រូវបានចុះបញ្ជី

**រូប 25 ៖ ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលថយចុះ**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS= ខាងស្តាំ*

**រូប 26 ៖ ចំណាយរបស់រដ្ឋាភិបាល មានភាពយឺតយ៉ាវ**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS= ខាងស្តាំ*

**រូប 27 ៖ អត្ថប្រយោជន៍សង្គម និងជំនួយឥតសំណង កើនឡើង**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

28 សេចក្តីប្រកាសស្តីពីលទ្ធផលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ចុះថ្ងៃទី 3 ខែ មីនា ឆ្នាំ 2021។
29 សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ចុះថ្ងៃទី 13 ខែ ឧសភា ឆ្នាំ 2021។

ក្នុងមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាល (IDPoor)។ មានមូលនិធិបម្រុង 30 លានដុល្លារសម្រាប់ការទប់ស្កាត់ និងព្យាបាល ក្នុងករណីមានការផ្ទុះជំងឺកូវីដ 19 សម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទប់ស្កាត់ និងពិនិត្យរកជំងឺកូវីដ 19 និងគ្របដណ្តប់លើចំណាយពាក់ព័ន្ធនឹងការព្យាបាលជំងឺកូវីដ 19 សម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ការផ្តល់ហិរញ្ញប្បទានចាំបាច់ដល់វិស័យសហគ្រាសធុនតូច និងមធ្យម ត្រូវបានផ្តល់ជូនតាមរយៈគម្រោងផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម ចំនួន 270 លានដុល្លារ ដែលជាមូលនិធិបម្រុង។

### ឱនភាពជារួមនៅតែទទួលហិរញ្ញប្បទានពីប្រាក់សន្សំចរន្ត និងកម្ចីខាងក្រៅ

**សម្ពាធចំណាយជាបន្តបន្ទាប់ធ្វើឱ្យចំណាយសាធារណៈកើនឡើង ខណៈដែលការប្រមូលចំណូលថយចុះ ដែលនាំឲ្យមានកំណើនឱនភាពសារពើពន្ធជារួម។** ទោះជាយ៉ាងណា ឱនភាពសារពើពន្ធត្រូវបានរំពឹងថានឹងទទួលបានហិរញ្ញប្បទានទាំងស្រុងពីប្រាក់សន្សំចរន្តរបស់រដ្ឋាភិបាល (ដោយមិនប្រើប្រាស់ហិរញ្ញប្បទានពីធនាគារក្នុងស្រុក) និងកម្ចីខាងក្រៅ។ ឱនភាពសារពើពន្ធជារួមនៅឆ្នាំ 2020 ត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងកម្រិតទាបចំនួន 2.7 ភាគរយនៃ ផសស នៅឆ្នាំ 2020 (រូប 28)។ ទោះបីជាមានការកើនឡើងនៃចំណាយដែលមិនធ្លាប់មានពាក់ព័ន្ធនឹងជំងឺកូវីដ 19 ដែលត្រូវបានប៉ាន់ស្មានថាមានចំនួន 4 ភាគរយនៃ ផសស ក្តី ក៏មានការប្រឹងប្រែងក្នុងការគ្រប់គ្រងចំណាយតាមរយៈការកាត់បន្ថយចំណាយលើទំនិញ និងសេវា និងចំណាយមិនអាទិភាពផ្សេងទៀត។ ដូច្នេះ ចំណាយសរុបត្រូវបានប៉ាន់ស្មានថាកើនចំនួន 26.8 ភាគរយនៃ ផសស នៅឆ្នាំ 2020 កើនពីចំនួន 25.5 ភាគរយនៃ ផសស នៅឆ្នាំ 2019។ ក្រៅពីនេះ ផលប៉ះពាល់នៃជំងឺកូវីដ 19 លើចំណូលក្នុងស្រុកត្រូវបានសម្រាលដោយការបង្កើនពន្ធលើប្រាក់ចំណេញនៅឆ្នាំ 2019 ដែលត្រូវបានប្រមូលនៅខែ មេសា ឆ្នាំ 2020។

**នៅឆ្នាំ 2021 ចំណូល និងជំនួយឥតសំណងសរុបត្រូវបានរំពឹងថានឹងថយចំនួន 22.7 ភាគរយនៃ ផសស** ថយពី 24.1 ភាគរយនៃ ផសស នៅឆ្នាំ 2020 (និងថយពី 27.0 ភាគរយនៃ ផសស នៅឆ្នាំ 2019)។ ទោះបីជារដ្ឋាភិបាលអន្តរាគមន៍ជាបន្តបន្ទាប់ដោយមានកញ្ចប់ថវិកាស្មើនឹង 2.6 ភាគរយនៃ ផសស ក្តី ក៏ចំណាយសរុបក៏ត្រូវបានព្យាករណ៍ថាថយចំនួន 26.0 ភាគរយនៃ ផសស នៅឆ្នាំ 2021 ធៀបនឹងចំនួន 26.8 ភាគរយនៃ ផសស នៅឆ្នាំ 2020 ដោយសារតែការថយចុះនៃចំណាយលើទំនិញ និងសេវា។ ក្រោមវិធានការសនិទានកម្មចំណាយសាធារណៈ ថ្មីៗនេះ ចំណាយលើទំនិញ និងសេវាត្រូវបានកាត់បន្ថយ ហើយត្រូវបានព្យាករណ៍ថានឹងថយចំនួន 3.1 ភាគរយនៃ ផសស នៅឆ្នាំ 2021 ថយពី 6.5 ភាគរយនៃ ផសស នៅឆ្នាំ 2020[30]។ ដូច្នេះ ឱនភាពសារពើពន្ធជារួមត្រូវបានព្យាករណ៍ថាកើនចំនួន 3.3 ភាគរយនៃ ផសស នៅឆ្នាំ 2021 ធៀបនឹងកំណើន 2.7 ភាគរយនៃ ផសស នៅឆ្នាំ 2020។

**នៅឆ្នាំ 2021 ឱនភាពសារពើពន្ធត្រូវបានរំពឹងថានៅតែទទួលបានហិរញ្ញប្បទានទាំងស្រុងពីកម្ចីខាងក្រៅចំនួន 4.2 ភាគរយនៃ ផសស និងទទួលបានហិរញ្ញប្បទានក្នុងស្រុក ចេញពីការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល ស្មើនឹង 0.3 ភាគរយនៃ ផសស** ខណៈដែលការកាត់រំលស់បំណុលមានចំនួន 1.2 ភាគរយនៃ ផសស (រូប 29)។ ដើម្បីផ្តល់ហិរញ្ញប្បទានដែលបំពេញគម្លាតរវាងការប្រមូលចំណូល និងលក្ខខណ្ឌហិរញ្ញប្បទាន អាជ្ញាធរកម្ពុជាបន្តប្រើប្រាស់ប្រាក់សន្សំចរន្តរបស់ខ្លួន ដែលជាការដកយកប្រាក់បញ្ញើរបស់រដ្ឋាភិបាលពីក្នុងប្រព័ន្ធធនាគារ។ ខណៈដែលប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅតែមានភាពល្អប្រសើរ (ស្មើនឹង 24.1 ភាគរយនៃ ផសស ឬ 24.9 ទ្រីលានរៀល) នៅបំណាច់ឆ្នាំ 2020 ប្រាក់បញ្ញើរបស់រដ្ឋាភិបាលបានថយចុះយ៉ាង

**រូប 28 ៖ ឱនភាពសារពើពន្ធជារួមរបស់រដ្ឋាភិបាល កើនឡើង**
(% នៃ ផសស)




*ប្រភព ៖* ច្បាប់ស្តីពីការទូទាត់ថវិកា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់ ៖* e=ការប៉ាន់ស្មាន, p=ការព្យាករណ៍

**រូប 29 ៖ កម្ចីបរទេសផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធ**
(% នៃ ផសស)




*ប្រភព ៖* ច្បាប់ស្តីពីការទូទាត់ថវិកា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់ ៖* e=ការប៉ាន់ស្មាន, p=ការព្យាករណ៍

**រូប 30 ៖ ប្រាក់សន្សំរបស់រដ្ឋាភិបាលនៅតែមានស្ថានភាពល្អប្រសើរ**
(ពាន់លានរៀល)




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*សម្គាល់ ៖* RHS=ខាងស្តាំ

30 សារាចរណែនាំចុះថ្ងៃទី 4 ខែ ឧសភា ឆ្នាំ 2021 ស្តីពីសនិទានកម្មចំណាយ និងការពង្រឹងប្រសិទ្ធផលសម្រាប់ថវិកាឆ្នាំ 2021 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ខ្លាំង។ ប្រាក់បញ្ញើបានកើនចំនួន 4.6 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅឆ្នាំ 2020 ថយពី 47.2 ភាគរយនៅឆ្នាំ 2019 (រូប 30) ដោយសារតែភាពយឺតយ៉ាវនៃការប្រមូលចំណូល និងការថយចុះនៃចំនួនប្រាក់សន្សំរបស់រដ្ឋាភិបាល។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាលបានថយចុះនៅអំឡុងឆ្នាំ 2009-2011 ជាអំឡុងពេលដែលចំណាយសាធារណៈកើន ស្មើនឹង 23.0 ភាគរយនៃ ផសស នៅឆ្នាំ 2011 កើនពី 16.1 ភាគរយនៃ ផសស នៅឆ្នាំ 2008 (សូមមើល ឧបសម្ព័ន្ធ) ដោយសារអាជ្ញាធរកម្ពុជាបានដាក់ចេញវិធានការជំរុញសារពើពន្ធដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-2009 (ក៏ដូចជាការបង្កើនចំណាយផ្សេងទៀតដែលបណ្តាលមកពីជម្លោះតាមព្រំដែនរវាងកម្ពុជា និងថៃ និងកត្តាផ្សេងទៀត)។

**កម្ពុជាអាចបង្កើនការប្រមូលចំណូលរបស់ខ្លួន ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ដោយសារតែជោគជ័យក្នុងការកៀរគរប្រាក់ចំណូល ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ជាលទ្ធផល អាជ្ញាធរកម្ពុជាបានបង្កើតគម្លាតសារពើពន្ធដ៏ធំក្នុងទម្រង់ជាប្រាក់សន្សំរបស់រដ្ឋាភិបាល ទន្ទឹមនឹងបន្តរក្សាបាននូវការគ្រប់គ្រងសារពើពន្ធយ៉ាងប្រុងប្រយ័ត្ន និងស្ថិរភាពដំណើរការម៉ាក្រូសេដ្ឋកិច្ច។

### កំណើនមូលធនដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 បានបង្កើនចំណាយមូលធនសរុប

**ចាប់តាំងពីឆ្នាំ 2019 មក មានការប្រឹងប្រែងយ៉ាងច្រើនក្នុងការបង្កើនការវិនិយោគមូលធនសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ទន្ទឹមនឹងការពន្លឿនការគ្រប់គ្រងការវិនិយោគសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងបំណុល។** កាលពីពីរបីឆ្នាំមុន កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើមូលនិធិខាងក្រៅ ដែលរួមមានកម្ចី និងជំនួយឥតសំណងដែលផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (ឥណទាយកផ្លូវការ) ដើម្បីផ្តល់មូលនិធិដល់ការវិនិយោគមូលធនរបស់កម្ពុជា ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ ទោះជាយ៉ាងណា មានការបង្កើនមូលធនរបស់កម្ពុជាដែលទទួលបានហិរញ្ញប្បទានក្នុងស្រុក តាំងពីឆ្នាំ 2019 (រូប 31)។ នៅខែ កញ្ញា ឆ្នាំ 2020 រដ្ឋាភិបាលបានអនុម័តវិភាជថវិកាចំនួន 150 លានដុល្លារ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវ 38 ខ្សែនៅខេត្តសៀមរាប ដែលត្រូវបញ្ចប់រួចរាល់នៅបំណាច់ឆ្នាំ 2021[31]។ គម្រោងវិនិយោគសាធារណៈស្រដៀងគ្នាដែលមានទឹកប្រាក់ 300 លានដុល្លារ ដើម្បីកសាងផ្លូវ 34 ខ្សែ មានប្រវែងសរុប 82.5 គីឡូម៉ែត្រ ត្រូវបានអនុម័តនៅឆ្នាំ 2019 ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅខេត្តព្រះសីហនុ។ គម្រោងនេះបានបញ្ចប់[32]។ នៅឆ្នាំ 2021 មូលនិធិដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកត្រូវបានរំពឹងថានឹងកើនលើស (ឬស្មើនឹង) មូលនិធិដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ ជាលើកដំបូង។ ដូច្នេះ ការវិនិយោគសាធារណៈរបស់កម្ពុជាមានទំហំធំជាងគេក្នុងតំបន់ (រូប 32 )។ មានការប្រឹងប្រែងយ៉ាងច្រើនក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ។ យុទ្ធសាស្រ្តស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានដាក់ចេញនៅខែ តុលា ឆ្នាំ 2019។ ការអនុវត្តផែនការសកម្មភាពលម្អិតសម្រាប់យុទ្ធសាស្រ្តនេះចាប់ផ្តើមឡើងនៅខែ មីនា ឆ្នាំ 2020។ ក្រុមការងារបច្ចេកទេសសម្រាប់ការរៀបចំសេចក្តីណែនាំលម្អិតស្តីពីវដ្តគម្រោង និងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍គម្រោងសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ បានដំណើរការតាំងពីខែ មិថុនា ឆ្នាំ 2020។

**រូប 31 ៖ ការវិនិយោគសាធារណៈ កើនឡើង**
(% នៃ ផសស)




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*សម្គាល់ ៖* e=ការប៉ាន់ស្មាន, p=ការព្យាករណ៍

**រូប 32 ៖ ការវិនិយោគសរុបរបស់កម្ពុជាលើទ្រព្យសកម្មក្រៅពីហិរញ្ញវត្ថុ មានទំហំធំ[1]**
(% នៃ ផសស ឆ្នាំ 2019)




*ប្រភព ៖* សូចនាករអភិវឌ្ឍន៍ពិភពលោក និងអាជ្ញាធរកម្ពុជា
*សម្គាល់ ៖* 1 កម្ពុជាឆ្នាំ 2020 ប្រទេសផ្សេងទៀតគឺនៅឆ្នាំ 2016

**រូប 33 ៖ ការវិនិយោគលើមូលធន កើនឡើង**
(% នៃ ផសស)




*ប្រភព ៖* អាជ្ញាធរកម្ពុជា
*សម្គាល់ ៖* e=ការប៉ាន់ស្មាន

31 សូមមើលលិខិតចុះថ្ងៃទី 4 ខែ កញ្ញា ឆ្នាំ 2020 ពីអភិបាលក្រុងសៀមរាបផ្ញើជូនលោកនាយករដ្ឋមន្ត្រី។
32 សូមមើលសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី 17 ខែ កក្កដា ឆ្នាំ 2020 ដោយគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

មានការរៀបចំក្នុងការបង្កើតមូលបត្ររដ្ឋាភិបាល (សម្រាប់ការពិភាក្សាលម្អិត សូមមើលផ្នែកស្តីពីទីផ្សារបំណុលក្នុងស្រុក)។

**ការវិនិយោគលើទ្រព្យសរុបរបស់កម្ពុជាកើនឡើងយ៉ាងឆាប់រហ័ស បន្ទាប់ពីសេដ្ឋកិច្ចបានងើបចេញពីវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ 2009** (រូប 33)។ ការវិនិយោគលើទ្រព្យសរុបកើន 24.6 ភាគរយនៃ ផសស នៅឆ្នាំ 2020 កើនពី 16.2 ភាគរយនៃ ផសស នៅឆ្នាំ 2010 ដោយសារកំណើនសេដ្ឋកិច្ច។ ចំណែកនៃការវិនិយោគឯកជនក្នុងការវិនិយោគសរុបកើន 64.6 ភាគរយ កើនពី 32.8 ភាគរយនៅឆ្នាំ 2011 ដែលបង្ហាញថា វិនិយោគិននៅតែមានទំនុកចិត្ត។ ទោះជាការវិនិយោគសាធារណៈដែលជួយសេដ្ឋកិច្ច មានតួនាទីយ៉ាងសំខាន់ក្នុងការស្តារសេដ្ឋកិច្ច ការវិនិយោគឯកជនក៏ជាគន្លឹះសំខាន់សម្រាប់ការស្តារវិស័យឯកជនផងដែរ។ កំណើននៃការវិនិយោគលើទ្រព្យសរុប ជួយគាំទ្រការស្តារសេដ្ឋកិច្ច និងធានានូវកំណើនសេដ្ឋកិច្ច។

### បំណុលសាធារណៈរបស់កម្ពុជាបានកើនឡើង ប៉ុន្តែហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប

**នៅឆ្នាំ 2020 អាជ្ញាធរកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីសម្បទានចំនួន 2.02 ពាន់លានដុល្លារ (74 ភាគរយនៃកម្រិតកំណត់សម្រាប់បំណុល) ជាមួយដៃគូអភិវឌ្ឍន៍[33]** ធៀបនឹងកម្ចី 1,288.27 លានដុល្លារដែលបានចុះហត្ថលេខានៅឆ្នាំ 2019។ ដោយសារផលប៉ះពាល់នៃជំងឺកូវីដ 19 នៅតែបន្តមានគម្លាតរវាងការប្រមូលចំណូល និងលក្ខខណ្ឌហិរញ្ញប្បទានកាន់តែរីកធំ។ ដើម្បីផ្តល់ហិរញ្ញប្បទានមួយផ្នែកដល់គម្លាតដ៏ធំនេះ បំណុលសាធារណៈរបស់កម្ពុជាបានកើនឡើង។ បំណុលសាធារណៈរបស់កម្ពុជា ដែលសុទ្ធតែជាបំណុលខាងក្រៅ កើនឡើងជាលំដាប់។ ផលធៀបរវាងបំណុល និង ផសស របស់កម្ពុជាស្មើនឹង 34.2 ភាគរយនៃ ផសស (បំណុលមិនទាន់សង 8.8 ពាន់លានដុល្លារ) នៅឆ្នាំ 2020 ហើយត្រូវបានព្យាករណ៍ថានឹងកើន 35.2 ភាគរយនៃ ផសស (9.6 ពាន់លានដុល្លារ) នៅឆ្នាំ 2021 (រូប 34)។

**ទោះជាយ៉ាងណា ហានិភ័យនៃវិបត្តិបំណុលនៅមានកម្រិតទាប សំខាន់ដោយសារតែគោលការណ៍ខ្ចីរបស់អាជ្ញាធរកម្ពុជា គឺបំណុលខាងក្រៅក្នុងលក្ខខណ្ឌសម្បទាន។** ការវិភាគលើនិរន្តរភាពបំណុល ដែលធ្វើឡើងដោយអាជ្ញាធរកម្ពុជានៅឆ្នាំ 2020 បង្ហាញថា ហានិភ័យនៃវិបត្តិបំណុលរបស់កម្ពុជានៅមានកម្រិតទាប ប៉ុន្តែ មិនទាន់មានការវិភាគលើនិរន្តរភាពបំណុលរួមដោយធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិសម្រាប់ឆ្នាំ 2020 នៅឡើយទេ។ សមាសភាគជំនួយឥតសំណងជាមធ្យមភាគនៅមានកម្រិតខ្ពស់ (43.2 ភាគរយនៅឆ្នាំ 2018, 51.6 ភាគរយនៅឆ្នាំ 2019 និង 46.5 ភាគរយនៅឆ្នាំ 2020)។ នៅឆ្នាំ 2020 កម្ចីខាងក្រៅត្រូវបានធ្វើសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលមានចំនួន 62.6 ភាគរយ ខណៈដែលកម្ចីផ្សេងទៀតចំនួន 37.4 ភាគរយត្រូវបានប្រើសម្រាប់វិស័យអាទិភាពផ្សេងទៀត។

**ចិនជាឥណទាយកផ្លូវការធំជាងគេរបស់កម្ពុជា ដែលមានបំណុលមិនទាន់សងសរុបចំនួន 3.9 ពាន់លានដុល្លារ ឬស្មើនឹង 44.2 ភាគរយនៃបំណុលសរុបរបស់កម្ពុជា។** ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ កម្ពុជាពឹងផ្អែកកាន់តែខ្លាំងលើប្រទេសចិនជាអ្នកផ្តល់កម្ចីដល់វិស័យសាធារណៈ និងលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស។ ខុសពីកម្ពុជា វៀតណាមបានធ្វើពិពិធកម្មប្រភពហិរញ្ញវត្ថុរបស់ខ្លួន។ ឥណទាយកធំជាងគេរបស់វៀតណាម គឺ ធនាគារពិភពលោក ដែលមានចំនួន 31.9 ភាគរយនៃបំណុលខាងក្រៅសរុបសម្រាប់វិស័យសាធារណៈរបស់រដ្ឋាភិបាល ឬស្មើនឹង 15.2 ពាន់លានដុល្លារ (រូប 35)។ ឥណទាយកដ៏សំខាន់មួយទៀតគឺជប៉ុន

**រូប 34 ៖ បំណុលសាធារណៈ កើនឡើង**
(ពាន់លានដុល្លារ)




*ប្រភព ៖* ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈ កម្ពុជា
*សម្គាល់ ៖* p=ការព្យាករណ៍, RHS=ខាងស្តាំ

**រូប 35 ៖ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើចិនជាឥណទាយកផ្លូវការ**
(ចំណែកជា % ឆ្នាំ 2019)




*ប្រភព ៖* ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈ កម្ពុជា និង Haver Analytics

**រូប 36 ៖ ខុសពីប្រទេសជិតខាង កម្ពុជាគ្មានបំណុលសាធារណៈក្នុងស្រុកនោះទេ**
(% នៃ ផសស ឆ្នាំ 2019)




*ប្រភព ៖* MFMod, ក្រុមធនាគារពិភពលោក

33 ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈ កម្ពុជា លេខ 11 ខែ មីនា ឆ្នាំ 2021។

ដែលមានចំនួន 30.4 ភាគរយនៃបំណុលខាងក្រៅសរុបរបស់រដ្ឋាភិបាល ឬស្មើនឹង 14.5 ពាន់លានដុល្លារ។ បន្ទាប់មក គឺធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានចំនួន 17.4 ភាគរយ។

**នៅឆ្នាំ 2020 បំណុលជាប្រាក់ដុល្លារអាមេរិកមានចំនួនច្រើនជាងគេ ស្មើនឹង 43.5 ភាគរយនៃបំណុលសរុប។** បន្ទាប់មកគឺបំណុលជាសិទ្ធិដកប្រាក់ពិសេស (SDR) ដែលមានចំនួន 24.6 ភាគរយ។ ទោះបីជាចិនជាឥណទាយកធំជាងគេរបស់កម្ពុជាក្តី ក៏បំណុលខាងក្រៅជាប្រាក់យន់ចិនសម្រាប់វិស័យសាធារណៈរបស់កម្ពុជាមានចំនួនតែ 15.7 ភាគរយប៉ុណ្ណោះនៃបំណុលសរុបប៉ុណ្ណោះ។

### កាលពីឆ្នាំមុន ធនាគារអភិវឌ្ឍន៍អាស៊ីជាភាគីផ្តល់កម្ចីច្រើនជាងគេ

**ការផ្តល់កម្ចីពីឥណទាយកសំខាន់ៗមួយចំនួនតូច ដែលរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី ជប៉ុន ចិន និងធនាគារពិភពលោក បានបង្កើនការផ្តល់កម្ចីសម្រាប់វិស័យសាធារណៈរបស់កម្ពុជានៅឆ្នាំ 2020។** បំណុលសរុប កើនឡើងនៅឆ្នាំ 2020 ស្មើនឹងជាង 1.2 ពាន់លានដុល្លារ ឬកំណើន 40.3 ភាគរយធៀបនឹងឆ្នាំមុន (តារាង 1)។ ខុសពីរយៈពេលជាច្រើនឆ្នាំកន្លងមក នៅពេលដែលការរួមចំណែកច្រើនបំផុតដល់កំណើននៃការផ្តល់កម្ចីទទួលបានភាគច្រើនពីឥណទាយកទ្វេភាគី ដូចជា ចិន និងបារាំង នៅឆ្នាំ 2020 ការរួមចំណែកនៃការផ្តល់កម្ចីដោយធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួនច្រើនជាងគេរហូតដល់ 30.4 ភាគរយនៃកំណើន 40.3 ភាគរយក្នុងការផ្តល់កម្ចីសរុប។ ការផ្តល់កម្ចីដោយធនាគារអភិវឌ្ឍន៍អាស៊ីកើនដល់ 421.9 លានដុល្លារនៅឆ្នាំ 2020 កើនពី 159.11 លានដុល្លារនៅឆ្នាំ 2019។ ការរួមចំណែកនៃបំណុលពីជប៉ុនមានចំនួន 7.6 ភាគរយ (149.8 លានដុល្លារ) នៃកំណើនសរុប។ នៅសល់ពីនេះគឺការរួមចំណែករបស់ចិន (4.0 ភាគរយ) និងការរួមចំណែករបស់ធនាគារពិភពលោក (3.5 ភាគរយ)។

### ខុសពីប្រទេសជិតខាង បំណុលសាធារណៈរបស់កម្ពុជាជាបំណុលខាងក្រៅទាំងស្រុង

**បំណុលសាធារណៈរបស់កម្ពុជាគឺជាបំណុលខាងក្រៅ ដោយសារតែបំណុលសាធារណៈក្នុងស្រុកដែលមិនទាន់សងចំនួន 1.57 លានដុល្លារត្រូវបានសងរួចនៅខែ កុម្ភៈ ឆ្នាំ 2020[34]។** ដូចបានពិភាក្សាខាងលើ បំណុលសាធារណៈទាំងអស់របស់កម្ពុជាគឺជារូបិយវត្ថុបរទេស។ ដូច្នេះ កម្ពុជាមានហានិភ័យដោយសារការប្រែប្រួលអត្រាប្តូរប្រាក់ ខណៈដែលសេដ្ឋកិច្ចកម្ពុជាមានដុល្លារូបនីយកម្មខ្ពស់។ ប្រទេសជិតខាងកម្ពុជា ដូចជា វៀតណាម និងថៃ បានងាកទៅរកកម្ចីក្នុងស្រុក។ បំណុលសាធារណៈក្នុងស្រុករបស់ថៃមានចំនួន 82.9 ភាគរយនៃបំណុលសាធារណៈមិនទាន់សងសរុប ចំណែកបំណុលសាធារណៈរបស់វៀតណាមមានចំនួន 36.8 ភាគរយនៃបំណុលសាធារណៈមិនទាន់សងសរុប (រូប 36)។

**កម្ពុជាស្ថិតក្នុងដំណើរការនៃការបង្កើតទីផ្សារបំណុលក្នុងស្រុក។** ច្បាប់ថ្មីស្តីពីមូលបត្ររដ្ឋត្រូវបានអនុម័តនៅខែ ធ្នូ ឆ្នាំ 2020 ដែលត្រួសត្រាយផ្លូវសម្រាប់ការចេញមូលបត្រដំបូងរបស់រដ្ឋាភិបាលនៅពេលដ៏ខ្លីខាងមុខតាមរយៈការបង្កើតទីផ្សារបំណុលក្នុងស្រុក។ ច្បាប់ស្តីពីមូលបត្ររដ្ឋ (ឆ្នាំ 2020) ចែងពីក្របខណ្ឌច្បាប់ និងគតិយុត្តិរួមសម្រាប់ការចេញ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋាភិបាល ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធផល និងប្រសិទ្ធភាព ដែលគាំទ្រការគ្រប់គ្រងបំណុលសាធារណៈ និងនិរន្តរភាពបំណុល។ ច្បាប់នេះមានគោលបំណងពង្រឹងការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋាភិបាល ដោយឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ច្បាប់នេះចែងថា ការចេញមូលបត្ររដ្ឋត្រូវមានចែងក្នុងច្បាប់ស្តីពីថវិកា និងស្ថិតក្រោមសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋ

**តារាង 1 ៖ បំណុល (លានដុល្លារ) និងការរួមចំណែកដល់កំណើននៃការទូទាត់បំណុល** (ភាគរយ)

| | 2014 | | 2015 | | 2016 | | 2017 | | 2018 | | 2019 | | 2020 | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | % | | % | | % | | % | | % | | % | | % |
| សរុប | 648.4 | 6.3 | 595.3 | -8.2 | 543.0 | -8.8 | 722.2 | 33.0 | 598.3 | -17.2 | 864.7 | 44.5 | 1,213.3 | 40.3 |
| ចិន | 432.2 | 5.4 | 367.3 | -10.0 | 328.2 | -6.6 | 392.9 | 11.9 | 231.9 | -22.3 | 322.1 | 15.1 | 356.5 | 4.0 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 71.6 | -9.2 | 97.5 | 4.0 | 143.3 | 7.7 | 137.0 | -1.2 | 100.7 | -5.0 | 159.1 | 9.8 | 421.9 | 30.4 |
| ធនាគារពិភពលោក | 34.2 | 3.6 | 2.1 | -4.9 | 7.0 | 0.8 | 15.7 | 1.6 | 23.6 | 1.1 | 61.7 | 6.4 | 92.0 | 3.5 |
| កូរ៉េខាងត្បូង | 36.9 | 0.9 | 32.1 | -0.7 | 19.7 | -2.1 | 38.5 | 3.5 | 33.9 | -0.6 | 44.7 | 1.8 | 67.0 | 2.6 |
| ជប៉ុន | 21.9 | -0.3 | 27.5 | 0.9 | 23.6 | -0.7 | 48.9 | 4.7 | 72.8 | 3.3 | 83.8 | 1.8 | 149.8 | 7.6 |
| បារាំង | 27.3 | 4.5 | 38.3 | 1.7 | 0.0 | -6.4 | 72.5 | 13.4 | 47.0 | -3.5 | 147.3 | 16.8 | 47.1 | -11.6 |
| ប្រទេសផ្សេងទៀត | 24.1 | 1.3 | 30.2 | 0.9 | 21.0 | -1.5 | 16.4 | -0.8 | 88.1 | 9.9 | 45.8 | -7.1 | 78.8 | 3.8 |

*ប្រភព ៖* ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

34 ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈកម្ពុជា (ខែ មីនា ឆ្នាំ 2021) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពេញលក្ខខណ្ឌតម្រូវហិរញ្ញប្បទាន។ កម្ពុជាសម្រេចបានឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ដូច្នេះ កម្ចីសម្បទានបានថយចុះជាលំដាប់។ ការបង្កើតទីផ្សារបំណុលក្នុងស្រុកនឹងជួយធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្តិចម្តងៗដោយងាកទៅរកបំណុលសាធារណៈក្នុងស្រុក ទន្ទឹមនឹងលើកកម្ពស់ប្រាក់សន្សំក្នុងស្រុក។ ទីផ្សារនេះនឹងជួយធ្វើបដិដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចកម្ពុជា ប្រសិនបើបំណុលក្នុងស្រុកដែលបានផ្តល់ គិតជារូបិយវត្ថុក្នុងស្រុក។

## ទស្សនវិស័យ

**ទស្សនវិស័យកំណើនរបស់កម្ពុជានៅតែមិនច្បាស់លាស់ខ្លាំង** ដោយសណ្ដាន និងល្បឿនពិតនៃការងើបឡើងវិញ នៅតែស្រពិចស្រពិល ហើយភាគច្រើនពឹងផ្អែកលើការវិវត្តនៃវីរុសក្លូណា និងល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺនេះ។ ដូច្នេះ យើងសូមលើកយកសេណារីយ៉ូពីរមកបង្ហាញ។ ទីមួយ គឺសេណារីយ៉ូគោលដែលផ្អែកលើការសន្មតមានសុទិដ្ឋិនិយមចំពោះជំងឺនេះ និងការចាក់វ៉ាក់សាំងបង្ការ។ ទីពីរ គឺសេណារីយ៉ូទាបដែលសន្មតពីហានិភ័យអវិជ្ជមានច្រើន។

**តារាង 2 ៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច** (សេណារីយ៉ូគោល)

| | 2020e | 2021p | 2022p | 2023p |
|---|---|---|---|---|
| គណនីជាតិ និងតម្លៃ | | | | |
| ផសស គិតត្រឹមតម្លៃទីផ្សារថេរ (% ប្រែប្រួល) | -3.1 | 4.0 | 5.2 | 6.0 |
| កសិកម្ម | 0.4 | 1.1 | 1.0 | 1.3 |
| ឧស្សាហកម្ម | -1.4 | 6.7 | 7.4 | 8.5 |
| សេវា | -6.2 | 2.6 | 4.8 | 5.4 |
| អតិផរណា តម្លៃអ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ មធ្យមភាគតាមពេល) | 2.9 | 3.0 | 3.0 | 3.0 |
| រដ្ឋាភិបាលជារួម (% ផសស) | | | | |
| ប្រាក់ចំណូល និងជំនួយឥតសំណង | 24.1 | 22.7 | 23.1 | 23.8 |
| ចំណាយ និងការផ្តល់កម្ចីសរុប | 26.8 | 26.0 | 27.1 | 27.0 |
| សមតុល្យរួម (រួមទាំងជំនួយឥតសំណង) | -2.7 | -3.3 | -4.0 | -3.2 |
| ហិរញ្ញប្បទានពីបរទេស | 4.8 | 4.2 | 4.1 | 4.1 |
| ហិរញ្ញប្បទានក្នុងស្រុកសរុប (ពីប្រាក់សន្សំចរន្ត) | -1.0 | 0.3 | 1.1 | 0.3 |
| ការរំលស់ | -1.0 | -1.2 | -1.2 | -1.2 |
| រូបិយវត្ថុ និងឥណទាន | | | | |
| រូបិយវត្ថុទូលាយ (% ប្រែប្រួល) | 15.3 | 20.0 | 21.4 | 21.0 |
| ការផ្តល់ឥណទានដល់វិស័យឯកជន (% ប្រែប្រួល) | 17.7 | 23.2 | 25.8 | 28.1 |
| វិស័យខាងក្រៅ (លានដុល្លារ លុះត្រាតែបញ្ជាក់ផ្សេងពីនេះ) | | | | |
| ការនាំចេញ (ទំនិញ និងសេវា) | 15,853 | 18,844 | 20,361 | 22,857 |
| ការនាំចូល (ទំនិញ និងសេវា) | 16,221 | 19,981 | 21,616 | 23,963 |
| ការវិនិយោគផ្ទាល់ពីបរទេស ៖ លំហូរចូលសរុប | 3,485 | 3,750 | 4,160 | 4,249 |
| ទុនបម្រុងផ្លូវការសរុប | 21,228 | 23,140 | 25,026 | 27,272 |
| (ចំនួនខែនៃការនាំចូល) | 10.4 | 9.5 | 9.3 | 9.0 |
| គណនីចរន្ត (% ផសស) | -9.9 | -9.8 | -10.2 | -9.7 |
| អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារអាមេរិក ជាមធ្យម) | 4,077 | 4,070 | 4,050 | 4,050 |
| បំណុលសាធារណៈសរុប (% ផសស) | 34.6 | 35.2 | 36.9 | 36.4 |
| *ចំណាំ ៖* | | | | |
| *ផសស ណូមីណាល, លានដុល្លារ* | 25,484 | 27,215 | 29,749 | 32,524 |

*ប្រភព ៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់ ៖* e = ការប៉ាន់ស្មាន; p = ការព្យាករណ៍

**ក្រោមសេណារីយ៉ូគោល សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនចំនួន 4 ភាគរយនៅឆ្នាំ 2021** ដោយទទួលបានការគាំទ្រដោយការងើបឡើងវិញបណ្តើរៗនៃតម្រូវការក្នុងស្រុក រួមនឹងការចាក់វ៉ាក់សាំងបង្ការ និងភាពប្រសើរនៃតម្រូវការខាងក្រៅ និងលំហូរចូលមូលធន (សូមមើល តារាង 3 ស្តីពីការសន្មតក្រោមសេណារីយ៉ូគោល និងសេណារីយ៉ូទាបក្នុងផ្នែកខាងក្រោម)។ ការព្យាករនេះសន្មតថា ទំនុកចិត្តទីផ្សារត្រូវបានស្តារឡើងវិញ ខណៈដែលការផ្ទុះឡើងនៃជំងឺកូវីដ 19 ក្នុងសហគមន៍នាពេលថ្មីៗនេះ ដែលចាប់ផ្តើមនៅខែ កុម្ភៈ ឆ្នាំ 2021 នៅតែអាចគ្រប់គ្រងបាន ដែលធ្វើឲ្យមានការបន្ធូរបន្ថយវិធានការបិទខ្ទប់ដែលបានរៀបចំឡើង ដោយមិនបង្កផលប៉ះពាល់ខ្លាំងក្នុងរយៈពេលមធ្យម និងរយៈពេលវែងលើវិស័យសាជីវកម្ម ឬវិស័យធនាគារ។ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសកំពុងវិលទៅរកប្រក្រតីភាព។ ក្រោមសេណារីយ៉ូគោលនេះ គេរំពឹងថា អាជ្ញាធរកម្ពុជានឹងចាត់វិធានការជាជំហានៗក្នុងការទាក់ទាញការវិនិយោគបន្ថែម និងជំរុញពាណិជ្ជកម្ម តាមរយៈការគ្រោងដាក់ចេញច្បាប់ស្តីពីការវិនិយោគ (ថ្មី) នៅឆមាសទីពីរក្នុងឆ្នាំ 2021 ដោយមានការគាំទ្រពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលត្រូវបានចុះហត្ថលេខានាពេលថ្មីៗនេះ។ ក្រោមផែនការស្តារសេដ្ឋកិច្ចរបស់ខ្លួន កម្ពុជាខិតខំជំរុញភាពប្រកួតប្រជែងតាមរយៈកំណែទម្រង់បរិយាកាសវិនិយោគ និងការទាញប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល។ អាជ្ញាធរកម្ពុជាបន្តអនុវត្តគោលនយោបាយសារពើពន្ធដែលជួយដល់សេដ្ឋកិច្ច ដោយបន្តអនុវត្តកម្មវិធីគាំពារសង្គម ទន្ទឹមនឹងការជំរុញការវិនិយោគសាធារណៈ។ សម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កើនឡើង និងទំនងជាបន្តកើនឡើង ហើយអាជ្ញាធរកម្ពុជានឹងពិចារណាលើជម្រើសនានាសម្រាប់ការស្តារសារពើពន្ធ នៅពេលសេដ្ឋកិច្ចងើបឡើងវិញ។

**ក្រោមសេណារីយ៉ូទាប សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនចំនួន 1.0 ភាគរយនៅឆ្នាំ 2021។** សេណារីយ៉ូទាបបំផុតនេះសន្មតថា ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកនឹងកាន់តែលំបាក ដោយសារតែការបិទខ្ទប់ជាច្រើនលើកច្រើនសា និងការរឹតត្បិតលើការធ្វើដំណើរ ដោយសារតែការប្រឹងប្រែងរារាំងការផ្ទុះជំងឺកូវីដ 19 ទទួលបរាជ័យ ហើយស្ថានភាពនេះធ្វើឱ្យសេដ្ឋកិច្ចមិនអាចស្តារឡើងវិញបាន ដោយមិនគិតពីភាពប្រសើរឡើងនៃស្ថានភាពក្រៅប្រទេស។ ការប្រឹងប្រែងរារាំងធ្វើឱ្យខាតបង់ធនធានសាធារណៈ ខណៈដែលការអនុវត្តកម្មវិធីចាក់ថ្នាំបង្ការត្រូវបានសន្មតថាមានល្បឿនយឺត។ ជាលទ្ធផល ទំនុកចិត្តទីផ្សារបានថយចុះ នាំឲ្យមានការថយចុះយ៉ាងខ្លាំងនូវលំហូរការវិនិយោគផ្ទាល់ពីបរទេស ខណៈដែលវិស័យកម្មន្តសាលសំខាន់ៗដែលផ្តោតលើការនាំចេញ ដូចជា សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ត្រូវបានរាំងស្ទះដោយការបិទខ្ទប់ជាច្រើនលើកច្រើនសា និងទទួលរងផលប៉ះពាល់ពីការដកចេញដោយផ្នែកនៃការអនុគ្រោះពន្ធ EBA និងការផុតកំណត់ជាបណ្តោះអាសន្ននៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP។ ឱនភាពសារពើពន្ធបានកើនឡើង ព្រោះតែចំណាយកើនឡើង ខណៈដែលប្រាក់ចំណូលក្នុងស្រុកថយចុះ ដោយសារតែសកម្មភាពសេដ្ឋកិច្ចអូសបន្លាយ និងមិនមានភាពសកម្ម។ ក្រោមសម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កម្ចីខាងក្រៅ និងប្រាក់សន្សំចរន្តរបស់រដ្ឋាភិបាល បន្តថយចុះ ដែលត្រូវការពេលវេលាកាន់តែច្រើនដើម្បីឱ្យរដ្ឋាភិបាលអាចស្តារសារពើពន្ធបាន។

**បន្ទាប់ពីវិបត្តិជំងឺកូវីដ 19 ផុតរលត់ សេដ្ឋកិច្ចកម្ពុជានឹងមានគន្លងថ្មី (ធម្មតាតាមគន្លងថ្មី) ដោយកើនឡើងបន្តិចក្នុងរយៈពេលខ្លី។** សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើភ្ញៀវទេសចរ។ ទោះជាមានការងើបឡើងវិញនៃវិស័យទេសចរណ៍ក្នុងស្រុកក្រោយពីការបន្ធូរបន្ថយការបិទខ្ទប់ វិស័យទេសចរណ៍សកលត្រូវបានរំពឹងថានៅតែមានកម្រិតទាបជាងកម្រិតមុនវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2023។ ការស្តារឡើងវិញនៃសេដ្ឋកិច្ចសកល ដែលមួយផ្នែកទទួលបានការគាំទ្រដោយការជំរុញសេដ្ឋកិច្ចយ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក នឹងស្តារពាណិជ្ជកម្មទំនិញ និងអាចផ្តល់សន្ទុះខាងក្រៅដល់កំណើនជាមធ្យមចំនួន 1 ភាគរយ ប៉ុន្តែ វិស័យទេសចរណ៍សកលត្រូវបានរំពឹងថានៅតែមានកម្រិតទាបជាកម្រិតមុនវិបត្តិជំងឺកូវីដ 19 រហូតដល់ឆ្នាំ 2023 ដែលនឹងអូសបន្លាយការស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់បណ្តាប្រទេសដែលពឹងផ្អែកលើវិស័យទេសចរណ៍។ ការផ្លាស់ប្តូររចនាសម្ព័ន្ធ ដែលជំរុញដោយការធ្វើពិពិធកម្មគម្រោងការវិនិយោគផ្ទាល់ពីបរទេស ដែលពីមុនមកប្រមូលផ្តុំភាគច្រើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ ទៅជាការនាំចេញទំនិញក្រៅពីសម្លៀកបំពាក់ និងទំនិញកសិកម្ម ហាក់កើតមាន ដោយកែសម្រួលទៅតាមការប្រែប្រួលនៃស្ថានភាពតម្រូវការក្រៅប្រទេស និងសេដ្ឋកិច្ចក្នុងស្រុក។

## បញ្ហាប្រឈម និងហានិភ័យ

**មានកំណើនហានិភ័យចំពោះទស្សនៈវិស័យកំណើនរបស់កម្ពុជា ដោយសារតែរលកថ្មីនៃការផ្ទុះការឆ្លងជំងឺកូវីដ 19 ចេះតែបន្ត។** ថ្មីៗនេះ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកត្រូវបានរាំងស្ទះដោយការដាក់ចេញជាថ្មីនូវការបិទខ្ទប់នៅចុងខែ មេសា ឆ្នាំ 2021។ ការបិទខ្ទប់តំបន់ប្រជុំជនធំជាងគេពីរនៅកម្ពុជា (ទីក្រុងភ្នំពេញ និងក្រុងតាខ្មៅ ក្នុងខេត្តកណ្តាល ដែលជាទីក្រុងមានប្រជាជនច្រើនជាងគេបន្ទាប់ពីទីក្រុងភ្នំពេញ) គឺជាការចាំបាច់ និងបានសង្គ្រោះអាយុជីវិតជាច្រើន ទោះបីជាអាចធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចក៏ដោយ។ អត្រាឆ្លងខ្ពស់នាពេលបច្ចុប្បន្នក៏គំរាមកំហែងដល់ប្រព័ន្ធសុខាភិបាលសាធារណៈផងដែរ។ រោងចក្រ និងអាជីវកម្មទទួលរងផលប៉ះពាល់ ខណៈដែលតម្រូវការក្នុងស្រុក ជាពិសេសតម្រូវការផលិតផលសេវា ដូចជាការធ្វើដំណើរក្នុងស្រុក ទេសចរណ៍ និងសេវាបដិសណ្ឋារកិច្ច រងការប៉ះពាល់ជាថ្មី ដោយសារការរឹតត្បិតការធ្វើដំណើរ ការបញ្ចៀសការធ្វើដំណើរ និងការថយចុះប្រាក់ចំណូល។ ស្ថានភាពនេះនឹងធ្វើឱ្យមានកំណើនយឺត រហូតដល់ការចាក់វ៉ាក់សាំងបង្ការបានច្រើន។

**គំរូកំណើនរបស់កម្ពុជា ដែលជាមូលដ្ឋាននាំចេញតូចចង្អៀត និងមានបណ្តុំផលិតផល និងទីផ្សារមួយចំនួនតូច មានភាពទន់ខ្សោយក្នុងរយៈពេលជាច្រើនឆ្នាំតាំងពីមុនការប៉ះទង្គិចដោយវិបត្តិជំងឺកូវីដ 19។** ទោះជាកម្ពុជាមានឧស្សាហកម្មកាត់ដេរដែលរឹងមាំ ផ្តល់ការងារដល់កម្មករជាច្រើន និងផ្តោតលើការនាំចេញវិស័យកម្មន្តសាល នៅតែជាប្រតិបត្តិការ "កាត់ដេរធម្មតា" ដែលជាផ្នែកមានតម្លៃបន្ថែមតិចបំផុតនៃសង្វាក់តម្លៃទាំងមូល ក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ។ ភាពប្រកួតប្រជែងក្រៅប្រទេសរបស់កម្ពុជាបានថយចុះ មួយផ្នែកដោយសារតែការតម្លើងប្រាក់ឈ្នួលយ៉ាងលឿន ដែលកាន់តែយ៉ាប់ដោយសារតែសេដ្ឋកិច្ចដុល្លារូបនីយកម្ម និងបញ្ហាប្រឈមក្នុងការធ្វើធុរកិច្ច និងកំណែទម្រង់បរិយាកាសវិនិយោគ។ ទោះជាយ៉ាងណាក៏ដោយ ភាពទន់ខ្សោយ

**តារាង 3 ៖ ការសន្មតក្រោមសេណារីយ៉ូគោល និងសេណារីយ៉ូទាប**

| ការសន្មត | សេណារីយ៉ូគោល | | សេណារីយ៉ូទាប | |
|---|---|---|---|---|
| រយៈពេល ចិរវេលា និងកម្រិតនៃការបិទខ្ទប់ | រយៈពេល ចិរវេលា និងកម្រិតនៃការបិទខ្ទប់ | | ការបិទខ្ទប់ធ្វើឡើងញឹកញាប់ អូសបន្លាយ ទូទាំងប្រទេស និងអាចពង្រីកដល់ត្រីមាសទី 3 ក្នុងឆ្នាំ 2021។ | |
| ល្បឿននៃការចាក់វ៉ាក់សាំងបង្ការ | មានភាពល្អប្រសើរ ដោយចាក់បាន 13.6 ភាគរយ ដែលជាតួលេខខ្ពស់ជាងគេនៅអាស៊ានបន្ទាប់ពីសិង្ហបុរី (គិតត្រឹមបំណាច់ខែ មេសា ឆ្នាំ 2021)។ | | ការចាក់វ៉ាក់សាំងបង្ការប្រឈមនឹងបញ្ហាធនធានមនុស្សក្នុងវិស័យសុខាភិបាលសាធារណៈ។ ដូច្នេះ កម្ពុជាមិនសម្រេចបានភាពស៊ាំសហគមន៍ ឡើយ រហូតដល់ចុងឆ្នាំ 2022។ | |
| ការឆ្លើយតបរបស់រដ្ឋាភិបាល | ការឆ្លើយតបរបស់ រដ្ឋាភិបាល | | ដូចសេណារីយ៉ូគោល | |
| ល្បឿននៃការស្តារឡើងវិញជាសកល និងការវិលត្រឡប់ មកវិញនៃភ្ញៀវទេសចរអន្តរជាតិ | ការស្តារឡើងវិញយ៉ាងឆាប់រហ័សនៅសហរដ្ឋអាមេរិក អឺរ៉ុប និងចិន ដែលសុទ្ធសឹងជាដៃគូពាណិជ្ជកម្មធំៗរបស់កម្ពុជា | | ដូចសេណារីយ៉ូគោល | |
| រយៈពេល | ស្ថានភាពសេដ្ឋកិច្ចការចាក់វ៉ាក់សាំងសម្រេចបានតាមចំណុចដៅ ដែលនាំឲ្យមានការស្តារទំនុកចិត្តទីផ្សារ ខណៈដែលលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនៅតែបន្តកើតមានដោយសារតែភាពទាក់ទាញនៃច្បាប់វិនិយោគថ្មី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់) និងការរើទីតាំងរោងចក្រដោយសារតែភាពតានតឹងផ្នែកនយោបាយនៅមីយ៉ាន់ម៉ា មិនទាន់បញ្ចប់។ មានផលប៉ះពាល់អវិជ្ជមានតិចតួចលើសាជីវកម្ម ព្រោះការនាំចេញទំនិញ (រួមទាំងការនាំចេញផលិតផលកសិកម្ម) មានសន្ទុះឡើងវិញ ដោយសារភាពប្រសើរឡើងនៃស្ថានភាពតម្រូវការខាងក្រៅ។ ការប្រឹងប្រែងក្រោមផែនការស្តារសេដ្ឋកិច្ច កំពុងធ្វើឡើងដើម្បីបង្កើនភាពប្រកួតប្រជែងតាមរយៈកំណែទម្រង់បរិយាកាសវិនិយោគ និងការទាញប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល។ ទោះបីជាសម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កើនឡើងយ៉ាងណាក្តី ក៏អាជ្ញាធរកម្ពុជានៅតែអាចអាចស្តារសារពើពន្ធបាន នៅពេលដែលមានការស្តារសេដ្ឋកិច្ចឡើងវិញក្នុងរយៈពេលខ្លី។ | | ទំនុកចិត្តទីផ្សារថយចុះ ដែលនាំឱ្យថយចុះខ្លាំងនៃលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស ខណៈដែលវិស័យកម្មន្តសាលសំខាន់ៗដែលផ្តោតលើការនាំចេញ ដូចជាសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ត្រូវបានរាំងស្ទះដោយការបិទខ្ទប់ និងទទួលរងផលប៉ះពាល់ពីការដកចេញដោយផ្នែកនៃការអនុគ្រោះពន្ធ EBA និងការផុតកំណត់ជាបណ្តោះអាសន្ននៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP បើទោះជាមានភាពប្រសើរឡើងនៃស្ថានភាពតម្រូវការខាងក្រៅក្តី។ ជាលទ្ធផល ផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដែលនាំឱ្យមានបញ្ហាសន្ទនីយភាព ក្លាយទៅជាបញ្ហាសោធនភាព ដែលប៉ះពាល់ដល់វិស័យសាជីវកម្ម។ ឱនភាពសារពើពន្ធត្រូវបានរំពឹងថាកើនឡើងទ្វេដង ព្រោះចំណាយកើនឡើង ខណៈដែលប្រាក់ចំណូលក្នុងស្រុកថយចុះដោយសារតែសកម្មភាពសេដ្ឋកិច្ចអូសបន្លាយ និងមិនមានភាពសកម្ម។ សម្ពាធបំណុលសាធារណៈ និងសម្ពាធថវិកា កើនឡើង ដែលតម្រូវឱ្យមានកម្ចីខាងក្រៅ និងការដកយកប្រាក់សន្សំចរន្តរបស់រដ្ឋាភិបាលកាន់តែច្រើន។ | |
| ការព្យាករម៉ាក្រូសេដ្ឋកិច្ច | 2021 | 2022 | 2021 | 2022 |
| **កំណើនពិត** (ភាគរយ) | 4.0 | 5.2 | 1.0 | 4.5 |
| **ឱនភាពសារពើពន្ធ** (ភាគរយនៃ ផសស) | -2.7 | -3.3 | -5.0 | -6.5 |
| **បំណុល** (ភាគរយនៃ ផសស) | 35.2 | 36.9 | 36.5 | 38.0 |

នេះត្រូវបានបិតបាំងដោយកំណើននៃលំហូរចូលមូលធននៅអំឡុងមុនមានវិបត្តិជំងឺកូវីដ 19 ដើម្បីផ្តល់ហិរញ្ញប្បទានភាគច្រើនដល់វិស័យសំណង់ និងអចលនទ្រព្យ។ ដោយសារតែការដួលរលំនៃវិស័យទេសចរណ៍ និងវិស័យសំណង់ដែលនៅទ្រឹង ជំងឺកូវីដ 19 បានបង្ហាញចេញនូវភាពទន់ខ្សោយផ្នែករចនាសម្ព័ន្ធរបស់កម្ពុជានេះ។

**ទន្ទឹមនឹងភាពទន់ខ្សោយក្នុងស្រុក ទស្សនវិស័យសកលមិនច្បាស់លាស់ នៅតែជាហានិភ័យដ៏ធំចំពោះការស្តារសេដ្ឋកិច្ចកម្ពុជា។** ភាពយឺតយ៉ាវនៃការចែកចាយវ៉ាក់សាំងទូទាំងសកលលោក អាចនាំឱ្យជំងឺកូវីដ 19 កើតមានយូរ ខណៈដែលការផ្ទុះជំងឺនេះធ្វើឲ្យមានការបិទខ្ទប់កាន់តែច្រើន។ ការនាំចេញទំនិញរបស់កម្ពុជាអាចរងផលប៉ះពាល់បន្ថែមទៀតដោយសារការដកចេញដោយផ្នែកនៃការអនុគ្រោះពន្ធ EBA និងការផុតកំណត់ជាបណ្តោះអាសន្ននៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP។ លើសពីនេះទៀត កម្ពុជាកាន់តែពឹងផ្អែកលើប្រទេសចិនលើផ្នែកពាណិជ្ជកម្ម ការវិនិយោគ និងជំនួយអភិវឌ្ឍន៍ផ្លូវការ។ កំណើនឥណទានក្នុងវិស័យធនាគារ ជាពិសេស ការផ្តល់ឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យ នៅតែជាហានិភ័យដ៏ធំចំពោះស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។

**បន្ទាប់ពីការផ្ទុះការឆ្លងជំងឺកូវីដ 19 ក្នុងសហគមន៍ ដែលចាប់ផ្តើមនៅថ្ងៃទី 20 ខែ កុម្ភៈ ឆ្នាំ 2021 កម្ពុជាមានករណីជំងឺកូវីដ 19 និងករណីស្លាប់ ដែលបានរាយការណ៍ កើនឡើងយ៉ាងឆាប់រហ័ស។** គិតត្រឹមថ្ងៃទី 31 ខែ ឧសភា ឆ្នាំ 2021 កម្ពុជាមានករណីឆ្លងសរុបចំនួន 30,094 នាក់ និងស្លាប់ 214 នាក់។ ជំងឺកូវីដ 19 អាចធ្វើឲ្យសមិទ្ធផលនៃការអភិវឌ្ឍយ៉ាងខ្លាំងក្នុងរយៈពេលជាច្រើនឆ្នាំនៅកម្ពុជាដើរថយក្រោយវិញ។ នៅពេលគ្មានវិធានការសម្រាលផលប៉ះពាល់សំខាន់ៗ ជំងឺកូវីដ 19 អាចធ្វើឲ្យមាននិកម្មភាពយ៉ាងច្រើន និងកំណើនភាពក្រីក្រ។ ស្ថានភាពនៃភាពក្រីក្រដោយផ្អែកលើការព្យាករម៉ាក្រូសេដ្ឋកិច្ច បង្ហាញថា ការធ្លាក់ចុះខ្លាំងនៃសេដ្ឋកិច្ចនឹងបង្កើនអត្រាភាពក្រីក្រចន្លោះពី 5.4 ភាគរយ ទៅ 6.0 ភាគរយ ឬស្មើនឹងប្រជាជនក្រីក្របន្ថែមចំនួន 859,000-950,000 នាក់ ហើយអាចធ្វើឲ្យវឌ្ឍនភាពរយៈពេល 6 ឆ្នាំលើភាពក្រីក្រដើរថយក្រោយ។ ក្នុងនេះ គ្រួសារដែលពឹងផ្អែកលើប្រាក់ឈ្នួលក្នុងវិស័យក្រៅពីកសិកម្ម ជាពិសេស កម្មករសំណង់ នឹងរងផលប៉ះពាល់ខ្លាំងជាងគេដោយសារការផ្ទុះឆ្លងជំងឺនេះ។

## ជម្រើសគោលនយោបាយ

**នៅចំពោះមុខ ចាំបាច់ត្រូវពន្លឿនការអនុវត្តកម្មវិធីចាក់វ៉ាក់សាំងបង្ការ ទន្ទឹមនឹងការបន្តរាំងខ្ទប់ការកើនឡើងនៃករណីឆ្លង និងករណីស្លាប់ ដោយប្រសិទ្ធភាព។** ដោយសារតែការផ្ទុះឡើងនៃជំងឺនេះនៅតែអូសបន្លាយទូទាំងប្រទេស អត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងបង្ការដើម្បីកាត់បន្ថយការកើនឡើងនៃចំនួនករណីសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងការស្លាប់ នៅខណៈដែលមានការបន្ធូរបន្ថយសម្ពាធលើប្រព័ន្ធសុខាភិបាលដែលកំពុងជួបការលំបាក នឹងមានលើសពីគុណវិបត្តិនៃការចំណាយផ្សេងៗ។ ការអន្តរាគមក្រៅពីឱសថអាចមានតួនាទីបំពេញបន្ថែមដល់ការរាំងខ្ទប់ជំងឺនេះ។ ក្នុងចំណោមប្រជាជនកម្ពុជាជាង 15 លាននាក់ មានប្រជាជនជាង 10.1 លាននាក់ដែលមានអាយុពី 18 ឆ្នាំឡើងទៅ ហើយប្រហែលជាត្រូវចាក់វ៉ាក់សាំង។ ដូច្នេះ កម្ពុជាត្រូវការវ៉ាក់សាំងបង្ការជំងឺកូវីដ 19 ជាង 20 លានដូស សម្រាប់ប្រជាជនក្នុងក្រុមអាយុនេះ។ ផ្អែកតាមផែនការយុទ្ធសាស្រ្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 កម្ពុជារំពឹងថានឹងទទួលបានវ៉ាក់សាំងចំនួន 13.5 លានដូស ឬស្មើនឹង 66 ភាគរយនៃចំនួនវ៉ាក់សាំងដែលត្រូវការចាំបាច់សម្រាប់ក្រុមអាយុនេះ គិតត្រឹមខែ កញ្ញា ឆ្នាំ 2021។ ផែនការនេះមានគោលដៅចាក់វ៉ាក់សាំងពេញលេញដល់ប្រជាជន 5 លាននាក់ដែលស្ថិតក្នុងក្រុមអាទិភាពដំបូង ចាប់ពីខែ ឧសភា រហូតដល់ខែ វិច្ឆិកា ឆ្នាំ 2021 (7 ខែ) ដែលស្មើនឹងវ៉ាក់សាំងបង្ការជំងឺកូវីដ 19 ចំនួន 10 លានដូស។ គិតត្រឹមបំណាច់ខែ មេសា ឆ្នាំ 2021 រដ្ឋាភិបាលបានបញ្ចេញវ៉ាក់សាំងចំនួន 2.4 លានដូស។ ដូច្នេះ ផែនការនេះគួរសម្រេចបានការចាក់វ៉ាក់សាំងចំនួន 1.1 លានដូស/ខែ ចាប់ពីខែ ឧសភា ដល់ខែ វិច្ឆិកា ឆ្នាំ 2021 ដើម្បីបញ្ចប់ការចាក់វ៉ាក់សាំងដែលនៅសល់ចំនួន 7.6 លានដូសទៀត។ ផែនការមេសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ 19 ដែលត្រូវបានចេញផ្សាយនៅខែ មីនា ឆ្នាំ 2021 ដោយក្រសួងសុខាភិបាល មានគោលដៅចាក់វ៉ាក់សាំងបង្ការដល់ប្រជាជនឱ្យបាន 10 លាននាក់ត្រឹមពាក់កណ្តាលឆ្នាំ 2022។

**ដោយសារកម្ពុជាមានលំហសារពើពន្ធធំបង្គួរ ការជំរុញបន្ថែមលើកម្មវិធីជួយជនក្រីក្រ និងការវិនិយោគសាធារណៈដែលជំរុញកំណើន រួមទាំងគម្រោងផ្តល់ពលកម្មដោយទទួលប្រាក់កម្រៃពិតជាសំខាន់ណាស់សម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ ។** លើចំណុចនេះ ថវិកាឆ្នាំ 2021 បានជំរុញការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានក្នុងស្រុក ដែលកើនឡើងជាលើកដំបូងលើសពីការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមក្នុងការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ ជាពិសេស ដើម្បីសម្របសម្រួលការផ្លាស់ប្តូររចនាសម្ព័ន្ធ ព្រោះវិស័យសំណង់គ្មានកំណើន ហើយបច្ចុប្បន្ន មានការវិនិយោគកាន់តែច្រើនលើផលិតកម្មសម្រាប់នាំចេញ ទន្ទឹមនឹងមានកំណើនទំនុកចិត្តដោយមានការដាក់ចេញនូវច្បាប់ស្តីពីការវិនិយោគ (ថ្មី) ដែលទាញប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់។ ដោយសារសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្ពស់ គោលនយោបាយសារពើពន្ធនឹងនៅតែជាឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចតែមួយគត់ដើម្បីគាំទ្រដល់ការសម្រាលវិបត្តិ ការស្តារឡើងវិញ និងកំណើន។ ការសម្រាលវិបត្តិនៅតែជាអ្វីដែលត្រូវការចាំបាច់ ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ ការស្តារឡើងវិញតម្រូវឲ្យមានការកែលម្អបរិយាកាសវិនិយោគ និងការលើកទឹកចិត្ត

ដើម្បីជំរុញការវិនិយោគ និងបង្កើនការនាំចេញ ព្រោះវិបត្តិជំងឺកូវីដ 19 អាចធ្វើឱ្យសេដ្ឋកិច្ចជាប់គាំងក្នុងស្ថានភាពខ្វះការងារធ្វើ។ កំណើនតម្រូវឲ្យមានការវិនិយោគសាធារណៈបន្ថែមទៀតដើម្បីបង្កើនគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធរឹង (រូបវ័ន្ត) និងហេដ្ឋារចនាសម្ព័ន្ធទន់ (បទបញ្ញត្តិ) សំដៅកាត់បន្ថយចំណាយលើការដឹកជញ្ជូន និងភ័ស្តុភារ និងបង្កើនភាពប្រកួតប្រជែងក្រៅប្រទេស។

**ជាការសំខាន់ត្រូវបន្តពិនិត្យតាមដានយ៉ាងល្អិតល្អន់លើភាពងាយរងគ្រោះ ដែលកើតឡើងពីកំណើនរយៈពេលយូរនៃវិស័យអចលនទ្រព្យ និងកំណើននៃការផ្តល់ឥណទានដល់វិស័យសំណង់នៅមុនពេលមានវិបត្តិជំងឺកូវីដ 19។** ផលធៀបនៃកម្ចីនិងប្រាក់បញ្ញើ មានចំនួន 120 ភាគរយនៅឆ្នាំ 2020 កើនពី 78.7 ភាគរយក្នុងរយៈពេលមួយទសវត្សរ៍មុន។ នេះជាចំណុចដ៏សំខាន់ ព្រោះការផ្ទុះឡើងនៃជំងឺកូវីដ 19 ក្នុងសហគមន៍នាពេលថ្មីៗនេះនៅតែអូសបន្លាយ ហើយចំនួនរោងចក្រ និងសហគ្រាស ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ចេះតែកើនឡើងជាលំដាប់។ ព្រឹត្តិការណ៍ទាំងនេះនឹងបន្តកាត់បន្ថយសមត្ថភាពរបស់អាជីវកម្ម និងគ្រួសារ ក្នុងការសងប្រាក់ ដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុទាំងមូលរងសម្ពាធកាន់តែខ្លាំង។ ថ្មីៗនេះ អាជ្ញាធរកម្ពុជាបានអំពាវនាវឱ្យអ្នកអភិវឌ្ឍន៍លំនៅដ្ឋានទទួលយកការស្នើពន្យារពេលក្នុងការបង់ប្រាក់រំលស់។ ទំហំទឹកប្រាក់សរុបនៃប្រាក់កម្ចី និងគណនីរបស់អ្នកខ្ចីដែលរងការប៉ះពាល់ ដែលត្រូវរៀបចំឡើងវិញនឹងកើនឡើងបន្ថែមទៀតនៅឆ្នាំនេះ ដោយកើនពីចំនួនគណនីសរុបនៅឆ្នាំមុន 285,000 គណនី ស្មើនឹងទឹកប្រាក់សរុបចំនួន 4.2 ពាន់លានដុល្លារ ឬស្មើនឹង 11.2 ភាគរយនៃឥណទានមិនទាន់សងសរុប ដែលបូកសរុបទាំងវិស័យធនាគារ និងវិស័យម៉ាក្រូហិរញ្ញវត្ថុ។ ក្នុងចំនួនទឹកប្រាក់ 4.2 ពាន់លានដុល្លារ ទឹកប្រាក់ចំនួន 1.73 ពាន់លានដុល្លារ ឬស្មើនឹង 41.5 ភាគរយត្រូវបានផ្តល់ជូនអ្នកខ្ចីដែលរងការប៉ះពាល់ក្នុងវិស័យសំណង់ ទេសចរណ៍ និងដឹកជញ្ជូន (និងភ័ស្តុភារ) រួមគ្នា។ ដោយសារតែវិស័យទាំងនេះនៅតែរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការបន្តផ្ទុះឆ្លងជំងឺកូវីដ 19 ក្នុងសហគមន៍ នឹងមានតម្រូវការកាន់តែច្រើនក្នុងការរៀបចំប្រាក់កម្ចីឡើងវិញសម្រាប់វិស័យទាំងនេះ។ កម្ចីមិនដំណើរការត្រូវបានរំពឹងថានឹងកើនឡើងពីអត្រាទាបនាពេលបច្ចុប្បន្ន 2.7 ភាគរយសម្រាប់វិស័យធនាគារ និង 1.8 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនៅឆ្នាំ 2020។ ធនាគារកណ្តាលត្រូវបន្តត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើហានិភ័យផ្នែកហិរញ្ញវត្ថុ ដោយផ្តោតសំខាន់លើលក្ខខណ្ឌសន្ទនីយភាព មូលធន និងគុណភាពនៃឥណទាន រួមនឹងវិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដូចបានពិភាក្សានៅផ្នែកស្តីពីរូបិយវត្ថុខាងលើ។


ក្រសួងរៀបចំដែនដី នគរូបនីយកម្ម
Ministry of Land Management Urban Planning and



អត្ថបទផ្តោតពិសេស

# ការផ្តល់អត្ថប្រយោជន៍សង្គមពីរដ្ឋាភិបាល ជូនប្រជាពលរដ្ឋ (G2P)

# អត្ថបទផ្តោតពិសេស៖ ការផ្តល់អត្ថប្រយោជន៍សង្គមពី រដ្ឋាភិបាលជូនប្រជាពលរដ្ឋ (G2P)[35]

## សេចក្តីផ្តើម

ដូចបានលើកឡើងនៅក្នុងផ្នែកស្តីពីម៉ាក្រូសេដ្ឋកិច្ចខាងលើ ប្រទេសកម្ពុជាបានពង្រីកវិសាលភាព និងអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់ខ្លួនកាន់តែស៊ីជម្រៅក្នុងរយៈពេលមួយខ្លី បើទោះជាកម្មវិធីនេះទើបតែដាក់ឱ្យអនុវត្តមុនពេលមានវិបត្តិកូវីដ 19 បន្តិចក្តី។ ដោយសារតែកម្មវិធីជំនួយសង្គមដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន កន្លងមក ប្រទេសកម្ពុជាអាចជួយការពារប្រជាជនរាប់លាននាក់មិនឱ្យធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យសមិទ្ធផលដែលសម្រេចបានទាំងលំបាកក្នុងការកាត់បន្ថយភាពក្រីក្រដើរថយក្រោយវិញ។

ដើម្បីប្រមូលមេរៀនដែលបានពីការដាក់ឱ្យអនុវត្តយ៉ាងឆាប់រហ័ស ការពង្រីកកម្មវិធី និងការអនុវត្តកាន់តែស៊ីជម្រៅនៃកម្មវិធីជំនួយសង្គមរបស់កម្ពុជា ជាពិសេសកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ធនាគារពិភពលោកកំពុងធ្វើការសិក្សាមួយលើការផ្តល់អត្ថប្រយោជន៍នានាពីរដ្ឋាភិបាលជូនប្រជាជន (G2P) នៃកម្មវិធីផ្តល់អត្ថប្រយោជន៍សង្គមរបស់កម្ពុជា។ របកគំហើញសំខាន់ៗនៃការសិក្សាដែលលើកយកមកធ្វើការពិភាក្សាខាងក្រោម ផ្តល់នូវព័ត៌មានលម្អិតអំពីការផ្តល់ប្រាក់ឧបត្ថម្ភ (G2P) ដែលកំពុងអនុវត្តនៅក្នុងកម្មវិធីជំនួយសង្គមបច្ចុប្បន្ន និងនាពេលអនាគត ក៏ដូចជា នៅក្នុងកម្មវិធីដទៃទៀត។

## ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការរាតត្បាតជាសកលនៃជំងឺកូវីដ 19

**កម្មវិធីជាតិជំនួយសង្គមរបស់កម្ពុជា កំពុងស្ថិតនៅដំណាក់កាលទើបចាប់ផ្តើមនៅឡើយនៅពេលដែលការរាតត្បាតជាសកលនៃជំងឺកូវីដ 19 ចាប់ផ្តើមកកើតឡើង។** គិតរហូតមកដល់ឆ្នាំ 2018 កម្ពុជាបានចំណាយថវិកាប្រមាណ 0.05 ភាគរយ នៃ ផ.ស.ស របស់ខ្លួនលើជំនួយសង្គម ដោយកម្រិតចំណាយនេះជាអត្រាមួយ ក្នុងចំណោមអត្រាទាបជាងគេនៅក្នុងពិភពលោក។ កម្ពុជាបានប្រកាសចាប់ផ្តើមអនុវត្តកម្មវិធីជំនួយសង្គមទី 1 របស់ខ្លួន ដែលមានឈ្មោះថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារ ដោយប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor)។ កម្មវិធីដែលត្រូវបានប្រកាសកាលពីខែ មិថុនា ឆ្នាំ 2019 នេះ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ តាមរយៈអនុក្រឹត្យ និងត្រូវបានអនុវត្តពីខែ មករា ឆ្នាំ 2020 មក។ គិតត្រឹមខែ កុម្ភៈ ឆ្នាំ 2020 នៅពេលដែលការរាតត្បាតជាសកលចាប់ផ្តើមកើតឡើង កម្មវិធីនេះបានផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកទទួលផលប្រមាណ 80 000 នាក់ ឬស្មើនឹង 0.5 ភាគរយ នៃចំនួនប្រជាជនសរុប។

**ជាការឆ្លើយតបចំពោះបញ្ហាប្រឈមដែលបង្កឡើងដោយសារជំងឺកូវីដ 19 រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកញ្ចប់ឆ្លើយតប និងសង្គ្រោះសេដ្ឋកិច្ច ដែលមានទ្រង់ទ្រាយធំ។** ការឆ្លើយតបនេះមានគោលបំណងផ្តោតលើផលប៉ះពាល់ ដែលវិបត្តិនេះមានមកលើវិស័យសុខាភិបាល សង្គម និងសេដ្ឋកិច្ច។ រួមនឹងវិធានការដទៃទៀត រដ្ឋាភិបាលបានដាក់ឲ្យអនុវត្តកម្មវិធីគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ព្រមទាំងវិធានការសេដ្ឋកិច្ច ដូចជា ការផ្តល់ឧបត្ថម្ភធនសម្រាប់ជួយរ៉ាប់រងចំណាយលើប្រាក់ឈ្នួល និងការលើកលែងពន្ធសម្រាប់អាជីវកម្មនៅក្នុងវិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ កម្មវិធីសាច់ប្រាក់ពលកម្ម ដើម្បីបង្កើតឱកាសការងារនៅតាមតំបន់ជនបទ កម្មវិធីផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម និងការផ្តល់កម្ចីការប្រាក់ទាបដល់អាជីវកម្ម ដែលជួបការលំបាក តាមរយៈធនាគារ សហគ្រាសខ្នាតតូច និងមធ្យម ដែលទើបបង្កើតថ្មី និងធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ។

**កម្មវិធីជំនួយសង្គមត្រូវបានពង្រីកវិសាលភាពធំទូលាយ ដើម្បីគ្របដណ្តប់លើគ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មក្រីក្រដែលមានស្រាប់ សំដៅផ្តល់ប្រាក់ឧបត្ថម្ភសង្គ្រោះជីវភាពរស់នៅរបស់គ្រួសារក្រីក្រដែលបានចុះឈ្មោះនៅក្នុងប្រព័ន្ធនេះ។** ដោយប្រើប្រាស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារតូចជាគំរូសម្រាប់ផ្តល់ជំនួយសង្គ្រោះបន្ទាន់ (សូមមើលប្រអប់ S.1) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ គឺជាសមាសភាគធំជាងគេនៃកញ្ចប់គាំទ្ររបស់រដ្ឋាភិបាល។ ប្រកាសដាក់ឱ្យអនុវត្តនៅក្នុងខែ មិថុនា ឆ្នាំ 2020 កម្មវិធីនេះបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន 230.5 លានដុល្លារ គិតត្រឹមខែ កុម្ភៈ ឆ្នាំ2021[36]។ គេរំពឹងថា កម្មវិធីនេះនឹងបន្តអនុវត្តរហូតដល់ខែ មិថុនា ឆ្នាំ 2021 និងផ្តល់ប្រាក់ឧបត្ថម្ភយ៉ាងហោចណាស់ 30 លានដុល្លារក្នុងមួយខែ។ កម្មវិធីនេះបានគ្របដណ្តប់លើប្រជាពលរដ្ឋជាង 688 000 គ្រួសារ (ស្មើនឹង 2.7 លាននាក់) ឬស្មើនឹង 17 ភាគរយ នៃចំនួនប្រជាជនសរុបដែលជាការកើនឡើងយ៉ាងខ្លាំងធៀបនឹងការផ្តល់ជំនួយសង្គមនៅមុនពេលមានជំងឺកូវីដ 19 បើគិតទាំងចំនួនប្រជាពលរដ្ឋដែលគ្របដណ្តប់ និងវិសាលភាពភូមិសាស្ត្រ។

---

35 អត្ថបទផ្តោតពិសេសនេះត្រូវបានរៀបចំឡើងដោយ Marco Nicoli។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ Maheshwor Shrestha, Robert J. Palacios, និង Biagio Bssone ដែលបានផ្តល់ការរួមចំណែក និងសំណូមពរ។

36 បើទោះជាដំបូងឡើយត្រូវបានដាក់ឱ្យអនុវត្តជាកម្មវិធីដែលមានរយៈពេល 2 ខែ កាលពីខែ មិថុនា ឆ្នាំ 2020 ក្តី កម្មវិធីនេះត្រូវបានពង្រីកវិសាលភាពជាច្រើនលើកច្រើនសា។ បច្ចុប្បន្ននេះ គេរំពឹងថា ការឧបត្ថម្ភសាច់ប្រាក់សង្គ្រោះ នឹងបន្តរហូតដល់ខែ មិថុនា ឆ្នាំ 2021 និងអាចពង្រីកវិសាលភាពបន្ថែមទៀតទៅតាមកាលៈទេសៈជាក់ស្តែង។

**ប្រអប់ S1 ៖**

### ការឆ្លើយតបផ្នែកគាំពារសង្គមរបស់កម្ពុជាចំពោះវិបត្តិជំងឺកូវីដ 19

ជាការត្រៀមទប់ទល់នឹងផលប៉ះពាល់សេដ្ឋកិច្ច ដែលបង្កឡើងដោយសារជំងឺកូវីដ 19 រាជរដ្ឋាភិបាលកម្ពុជាបានអន្តរាគមន៍យ៉ាងឆាប់រហ័ស ដើម្បីផ្គត់ផ្គង់ថវិកា និងពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ។ នៅមុនពេលមានវិបត្តិកូវីដ 19 គិតត្រឹមដើមឆ្នាំ 2020 ប្រជាពលរដ្ឋចំនួន 506 000 គ្រួសារ (ស្មើនឹងប្រមាណ 15 ភាគរយ នៃចំនួនប្រជាជនសរុប) ត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ តាមរយៈប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលហៅថា កម្មវិធី IDPoor ដែលអាចឱ្យគ្រួសារទាំងនេះទទួលបានសេវាសង្គមជាច្រើន។ បង្កើតឡើងក្នុងក្រសួងផែនការ ចាប់តាំងពីឆ្នាំ 2005 មក ប្រព័ន្ធ IDPoor ប្រើប្រាស់អភិក្រមដែលមានការចូលរួមនៅសហគមន៍ រួមនឹងប័ណ្ណពិន្ទុភាពក្រីក្រ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារដែលរស់នៅក្នុងភាពក្រីក្រ។ គិតត្រឹមឆ្នាំ 2019 មានខេត្តមួយភាគបីបានអនុវត្តដំណើរការ ក្រោមការដឹកនាំដោយសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រជារៀងរាល់ឆ្នាំ មានន័យថា តំបន់ប្រជុំជន និងតំបន់ក្រីក្រទាំងអស់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីនេះនៅក្នុង រយៈពេល ៣ឆ្នាំ។ ចាប់តាំងពីឆ្នាំ 2011 មក រាល់សេវាសម្រាប់ប្រជាពលរដ្ឋក្រីក្រទាំងអស់ ត្រូវបានច្បាប់តម្រូវឱ្យប្រើប្រាស់ប្រព័ន្ធ IDPoor ដើម្បីជ្រើសរើសមុខសញ្ញាទទួលផល។ បច្ចុប្បន្នេះ គ្រួសារដែលមានប័ណ្ណសមធម៌ ដែលជាប័ណ្ណសម្គាល់គ្រួសារក្រីក្រអាចប្រើប្រាស់កម្មវិធីជាច្រើន ដូចជា ការទទួលបានសេវាថែទាំសុខភាពដោយមិនគិតថ្លៃក្រោមក្របខណ្ឌនៃមូលនិធិសមធម៌សុខាភិបាល ជំនួយហិរញ្ញវត្ថុ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារតូច (អាយុពី 0-2 ឆ្នាំ) (ដែលហៅកាត់ថា CTP-PWYC) ព្រមទាំងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សបឋមសិក្សា និងមធ្យមសិក្សា។

ការឆ្លើយតបនៃសេវាគាំពារសង្គមចំពោះវិបត្តិកូវីដ 19 ត្រូវបានធ្វើឡើងដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារតូច។ អ្នកដែលកាន់ប័ណ្ណសមធម៌គ្រួសារក្រីក្រ អាចចុះឈ្មោះជាមួយនឹងអាជ្ញាធរឃុំ និងបានទទួលប្រាក់ឧបត្ថម្ភពីអ្នកផ្តល់សេវាបើកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (សូមមើលប្រអប់ S.3)។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវបានអនុវត្តដោយស្ថាប័នសំខាន់ៗចំនួនពីរ គឺ ក្រសួងផែនការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ។ ក្រសួងផែនការទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណអ្នកទទួលផល ដោយប្រើប្រាស់ប្រព័ន្ធ IDPoor និងផ្តល់ទិន្នន័យអំពីគ្រួសារគ្រប់លក្ខខណ្ឌជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាអ្នកគ្រប់គ្រងការចុះឈ្មោះ ការគណនាប្រាក់ឧបត្ថម្ភ និងដំណើរការបើកផ្តល់។

ដោយសារតែមានការប្តេជ្ញាចិត្តខ្ពស់ពីអាជ្ញាធរមូលដ្ឋាន កម្មវិធី IDPoor បានប្តូរទៅជាប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមតម្រូវការ (OD-IDPoor) ដើម្បីធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រក្រោមការដឹកនាំពីអាជ្ញាធរឃុំ។ ដំណើរការនេះនាំឱ្យមានការចុះឈ្មោះប្រជាពលរដ្ឋជាង 560 000 គ្រួសារចាប់គិតពីខែ មិថុនា ឆ្នាំ 2020 មក ហើយចំនួននេះនៅបន្តមានការកើនឡើង។ គិតត្រឹមខែមីនា ឆ្នាំ 2021 ប្រជាពលរដ្ឋជាង 710 000គ្រួសារ (ស្មើនឹង 2.8 លាននាក់) បានបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភនេះ។

*ប្រភព៖* Policy in Focus, The International Policy Centre for Inclusive Growth, Volume 19, Issue No. 1, March 2021.

**កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសង្គ្រោះផ្តល់សាច់ប្រាក់ ទៅតាមទីតាំង កម្រិតនៃភាពក្រីក្រ លក្ខណៈប្រជាសាស្ត្ររបស់គ្រួសារ និងភាពងាយរងគ្រោះរបស់ពួកគេ។** កម្រិតនៃអត្ថប្រយោជន៍អាស្រ័យទៅតាមប្រភេទ តំបន់ (ជនបទ ឬប្រជុំជន) កម្រិតនៃភាពក្រីក្រ (ក្រ 1 ដែលសំដៅលើទីទាល់ក្រ ឬ ក្រ 2 សំដៅក្រ) និងចំនួនសមាជិកនៅក្នុងគ្រួសារ។ លើសពីនេះទៀត មានការផ្តល់សាច់ប្រាក់បន្ថែមដល់ក្រុមងាយរងគ្រោះដូចជាជនមានពិការភាពចាស់ជរាអាយុលើសពី60ឆ្នាំកុមារអាយុក្រោម5ឆ្នាំនិងអ្នករស់នៅជាមួយនឹងមេរោគអេដស៍ និងជំងឺអេដស៍។ ព័ត៌មានពាក់ព័ន្ធនឹងការកំណត់ពីចំនួនសាច់ប្រាក់ដែលត្រូវបានផ្តល់ជូន ត្រូវបានប្រមូលបញ្ចូលទៅក្នុងកម្មវិធី IDPoor និងបង្ហាញចេញជាប្រព័ន្ធទិន្នន័យ។ ជាមធ្យមគ្រួសារនីមួយៗទទួលបានប្រាក់ប្រមាណជា 45 ដុល្លារក្នុងមួយខែ។

**ការពង្រីកការអនុវត្តកម្មវិធីយ៉ាងឆាប់រហ័សបែបនេះ គឺជាការលំបាក ប៉ុន្តែក៏បានទទួលជោគជ័យផងដែរ។** ការពង្រីកការអនុវត្តកម្មវិធីយ៉ាងរហ័សបែបនេះ គឺជាការងារលំបាក ប៉ុន្តែបានទទួលជោគជ័យ។ រដ្ឋាភិបាល (តាមរយៈក្រសួងពាក់ព័ន្ធ) បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ដើម្បីធានាឱ្យមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តកម្មវិធីនេះ និងរៀបចំផែនការអនុវត្តគ្រប់ជ្រុងជ្រោយ ដូចជា ការកំណត់អត្តសញ្ញាណ ការចុះឈ្មោះ ការភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រព័ន្ធទូទាត់ចល័ត និងការកសាងសមត្ថភាពអនុវត្តកម្មវិធីរបស់មន្ត្រីឃុំ យ៉ាងហោចណាស់ចំនួន 30 000 នាក់ ដើម្បីធានាឱ្យមានការអនុវត្តកម្មវិធីជំនួយសង្គមនេះឱ្យបានឆាប់រហ័ស[37]។ នេះគឺជាលើកទី 1 ហើយ ដែលប្រព័ន្ធគាំពារសង្គមអាចគ្របដណ្តប់លើប្រជាពលរដ្ឋក្នុងភាគរយដ៏ធំបែបនេះ (ត្រូវបានកំណត់ដោយកម្មវិធី IDPoor) និងសម្រេចបានសមិទ្ធផលជាច្រើននៅក្នុងរយៈពេលដ៏ខ្លី តាមរយៈយន្តការបើកផ្តល់ចំពោះកិច្ចដ៏មានប្រសិទ្ធភាព (សូមមើលផ្នែកបន្ទាប់)។ ជាការពិត ទិន្នន័យនៃការអង្កេតបង្ហាញថា ការឧបត្ថម្ភសាច់ប្រាក់នេះបានគ្របដណ្តប់ដល់គ្រួសារគ្រប់លក្ខខណ្ឌជាង 95 ភាគរយ (ពោលគឺ គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ)[38]។

---

37 លិខិតស្តីពីគោលនយោបាយអភិវឌ្ឍន៍របស់ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ថ្ងៃទី 16 ខែមិថុនា ឆ្នាំ 2020។

38 ការអង្កេតតាមទូរស័ព្ទដោយឯករាជ្យរបស់ធនាគារពិភពលោក ក៏បានរកឃើញកម្រិតប្រហាក់ប្រហែលគ្នានៃការទទួលបានការឧបត្ថម្ភនេះ ក្នុងចំណោមអ្នកត្រូវទទួលផល (ធនាគារពិភពលោក ឆ្នាំ 2021 ចេញនាពេលឆាប់ៗខាងមុខ)។

**ជាលទ្ធផលកម្មវិធីឧបត្ថម្ភសាច់ប្រាក់សង្គ្រោះនេះ បានផ្តល់ផលជាវិជ្ជមានជាទ្រង់ទ្រាយធំដល់អ្នកទទួលផល។** ការវិភាគដែលធ្វើឡើងក្នុងពេលខាងមុខ ដោយធនាគារពិភពលោក រកឃើញថា ការឧបត្ថម្ភសាច់ប្រាក់សង្គ្រោះនេះ បានទទួលបានការវាយតម្លៃខ្ពស់ពីអ្នកទទួលផល។ អ្នកទទួលផល 78 ភាគរយ ចាត់ទុកប្រាក់ឧបត្ថម្ភនេះថាមានសារៈសំខាន់បំផុត ឬមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះសុខុមាលភាពរបស់ពួកគេ។ អ្នកទទួលផលក្នុងភាគរយស្រដៀងគ្នានេះ បានរាយការណ៍ថា ប្រាក់ឧបត្ថម្ភនេះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះសុខុមាលភាពរបស់ពួកគេ។ លើសពីនេះ គ្រួសារដែលបានទទួលប្រាក់ឧបត្ថម្ភក្នុងចំនួនច្រើន ក៏ទំនងជាមានជីវភាពរស់កាន់តែប្រសើរផងដែរ (រូប S.1) ហើយច្រើនតែលើកឡើងពីភាពប្រសើរនៃសុខុមាលភាពរបស់គ្រួសារពួកគេ បើធៀបនឹងមុនពេលដែលមានការរាតត្បាតកើតឡើង (ខែ មករា ឆ្នាំ 2020) ឬនៅមុនរយៈពេលដែលមានការអនុវត្តកម្មវិធីឧបត្ថម្ភសង្គ្រោះនេះ (ខែ មិថុនា ឆ្នាំ 2020)។ ពួកគេក៏មិនសូវជារាយការណ៍ពីបញ្ហាខ្វះខាតស្បៀង និងសុទិដ្ឋិនិយមច្រើនអំពីសុខុមាលភាពរបស់ពួកគេនៅក្នុងខែខាងមុខនេះ។

## កម្មវិធីជំនួយសង្គម ៖ យន្តការបើកប្រាក់

**យន្តការបើកផ្តល់នៃកម្មវិធីនេះប្រើប្រាស់សេវារបស់ក្រុមហ៊ុនវីង ដែលអ្នកផ្តល់សេវាបើកប្រាក់ចល័តនាំមុខគេនៅកម្ពុជា ដែលមានបណ្តាញជាទីភ្នាក់ងារបើកប្រាក់ជាង 9000 កន្លែងនៅទូទាំងប្រទេស។** អ្នកទទួលផលដែលបានបំពេញតាមលក្ខខណ្ឌ (មេគ្រួសារ) ត្រូវចុះឈ្មោះចូលរួមនៅក្នុងកម្មវិធីនេះ ដោយត្រូវបង្ហាញប័ណ្ណគ្រួសាររបស់ពួកគេទៅកាន់សមាជិកក្រុមប្រឹក្សាឃុំ (ជាអ្នកពិនិត្យផ្ទៀតផ្ទាត់អត្តសញ្ញាណរបស់គ្រួសារ) និងបើកគណនីរបស់ពួកគេ។ គណនីនេះមិនមែនជាគណនីប្រាក់ចល័តពេញលេញនោះឡើយ។ វាមិនតម្រូវឱ្យមានការដាក់លេខទូរស័ព្ទឡើយ ហើយអាចប្រើប្រាស់បានតែសម្រាប់តែកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះប៉ុណ្ណោះ។ បន្ទាប់មកអ្នកទទួលផលត្រូវទៅទីភ្នាក់ងារវីង និងសុំលេខសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួន ដែលអាចឱ្យពួកគេទៅបើកប្រាក់ពីភ្នាក់ងារវីងជារៀងរាល់ខែ ដោយត្រូវបង្ហាញប័ណ្ណគ្រួសារក្រីក្ររបស់ពួកគេ។ ក្រុមហ៊ុនវីងបានផ្តល់ការអនុញ្ញាតឱ្យប្រព័ន្ធទិន្នន័យ IDPoor អាចភ្ជាប់ទំនាក់ទំនងជាមួយខ្លួនដោយស្វ័យប្រវត្តិ តាមរយៈ API ដូច្នេះ ចំនួនទឹកប្រាក់នីមួយៗអាចភ្ជាប់ជាមួយនឹងលេខសម្គាល់គ្រួសារក្រីក្ររបស់ម្ចាស់គណនី និងបានទទួលប្រាក់ពីរដ្ឋាភិបាលសម្រាប់រ៉ាប់រងចំណាយ និងសេវាបើកប្រាក់ដោយអ្នកទទួលផល (រូប S.2)។

**កម្មវិធីនេះភាគច្រើនបានទទួលជោគជ័យក្នុងការផ្តល់ប្រាក់យ៉ាងមានប្រសិទ្ធភាពដល់អ្នកទទួលផល។** យន្តការបើកប្រាក់ត្រូវបានរៀបចំឡើងក្នុងគោលបំណងតែមួយគត់ គឺ ផ្តល់ប្រាក់ឧបត្ថម្ភឱ្យបានលឿនដល់អ្នកទទួលផល ព្រោះថា សាច់ប្រាក់គឺជាជម្រើសលឿនបំផុតនៅកម្ពុជា។ បច្ចេកវិទ្យាបានជួយដល់ដំណាក់កាលត្រៀមបើកសាច់ប្រាក់ ក្នុងបរិបទដែលមានការរឹតត្បិតលើការធ្វើដំណើរការ និងការរក្សាគម្លាតសុវត្ថិភាព។

**រូប S1៖ សុខុមាលភាពរបស់គ្រួសារមានការកើនឡើង នៅពេលដែលចំនួនប្រាក់ឧបត្ថម្ភសង្គ្រោះដែលពួកគេបានទទួលកាន់តែមានចំនួនច្រើនឡើង**




ចំនួនសរុបនៃចំនួនប្រាក់ឧបត្ថម្ភសង្គ្រោះដែលបានទទួល (ជាដុល្លារអាមេរិក)

*ប្រភព:* ធនាគារពិភពលោក (ឆ្នាំ 2021 ចេញនាពេលឆាប់ៗខាងមុខ)

**ដំណើរការនៃការបើកផ្ដល់បានប្រព្រឹត្តិទៅដោយរលូន បើទោះស្ថិតនៅក្នុងកាលៈទេសៈពិបាកក៏ដោយ។** មានការជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួននៃការអនុវត្ត ជាពិសេស នៅដំណាក់កាលដំបូងៗ ប៉ុន្តែ បញ្ហាប្រឈមទាំងនេះដូចជាបង្កផលប៉ះពាល់ដល់ករណីឧបត្ថម្ភសាច់ប្រាក់ភាគតិចតែប៉ុណ្ណោះ។ បញ្ហាប្រឈមដែលត្រូវបានរាយការណ៍ញឹកញាប់ជាងគេ រួមមាន បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្ត (អ៊ីនធឺណិតពុំមានស្ថិរភាព បញ្ហាពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹងឱ្យបានទាន់ពេលវេលា សមត្ថភាពពិនិត្យតាមដាននៅមានកម្រិត) បញ្ហានៅតាមសាលាឃុំ (មន្ត្រីឃុំមួយចំនួនមានសមត្ថភាពនៅមានកម្រិត ឬការជំនួសមន្ត្រីដែលបានទទួលការបណ្ដុះបណ្ដាលមិនបានធ្វើទាន់ពេលវេលា ពុំមានការបង្កើតការយល់ដឹងឱ្យបានគ្រប់គ្រាន់ និងការប្រព្រឹត្តិខុសច្បាប់ម្ដងម្កាល) ក៏ដូចជា បញ្ហានៅកម្រិតគ្រួសារ (ខ្វះការយល់ដឹងអំពីកម្មវិធី បាត់ប័ណ្ណ ប័ណ្ណត្រូវបានគេលួច ឬខូច ភ្លេចលេខ PIN ការចែកប័ណ្ណប្រើរួមគ្នាដោយពុំមានការអនុញ្ញាត ការពិបាកក្នុងការដកប្រាក់ ដោយអ្នកមិនមែនជាមេគ្រួសារ)។

**អ្នកទទួលផលក្នុងភាគរយមួយដ៏ខ្ពស់ ចាំបាច់ត្រូវធ្វើដំណើរចម្ងាយឆ្ងាយ ដើម្បីទៅបើកប្រាក់ឧបត្ថម្ភ ជាពិសេសនៅតាមតំបន់ភ្នំ។** ដោយសារតែចាំបាច់ត្រូវបើកសាច់ប្រាក់ផ្ទាល់ មានន័យថា អ្នកទទួលផលត្រូវទៅឃុំសិន ដើម្បីធ្វើការចុះឈ្មោះ និងត្រូវទៅភ្នាក់ងារវីងដែលនៅជិតបំផុត ដើម្បីដកសាច់ប្រាក់ម្ដងៗ។

**នេះអាចជាការខាតបង់ដ៏ធំមួយសម្រាប់គ្រួសារ នៅពេលដែលគេគិតបញ្ចូលការចំណាយលើការធ្វើដំណើរ ពេលវេលាដែលបានចំណាយ និងការបាត់បង់ឱកាស/ប្រាក់ចំណូលដែលអាចមាន។** ជាមធ្យមអ្នកទទួលផលត្រូវធ្វើដំណើរ 18 នាទី ដើម្បីទៅបើកសាច់ប្រាក់ ប៉ុន្តែ នៅតំបន់មួយចំនួន ពួកគេត្រូវធ្វើដំណើររហូតដល់ 25 នាទី (សូមមើលរូប S3)។ អ្នកទទួលផល 4 ភាគរយ ត្រូវធ្វើដំណើរជាង 45 នាទី ប៉ុន្តែតួលេខនេះកើនឡើងដល់ 12 ភាគរយ នៅក្នុងតំបន់មួយចំនួន (សូមមើលរូប S4)។ ការវិភាគបឋមដែលធ្វើឡើងដោយធនាគារពិភពលោក បង្ហាញថា គ្រួសារទទួលផលជាង 15 ភាគរយ ប្រហែលជារស់នៅឆ្ងាយជាងភ្នាក់ងារដែលនៅជិតបំផុតជាង 10 គីឡូម៉ែត្រ និងជាង 3 ភាគរយ រស់នៅឆ្ងាយជាង 30 គីឡូម៉ែត្រពីភ្នាក់ងារដែលនៅជិតបំផុត។

**រូប S2៖ ដំណើរការចុះឈ្មោះដើម្បីទទួលបានប្រាក់ឧបត្ថម្ភ និងដំណើរការបើកប្រាក់ឧបត្ថម្ភ**




**រូប S3៖ រយៈពេលធ្វើដំណើរជាមធ្យម**




**រូប S4៖ ភាគរយគ្រួសារដែលធ្វើដំណើរជាមធ្យមជាង 45 នាទី**




*ប្រភព៖* ការស្ទាបស្ទង់មតិដោយប្រើប្រាស់ទូរស័ព្ទដៃ បែប High-Frequency អំពីស្ថានភាពជំងឺកូវីដ-19 នៅកម្ពុជា ធនាគារពិភពលោក សហភាពអឺរ៉ុប និងជំនួយអូស្ត្រាលី ឆ្នាំ 2020-2021។

**ខណៈពេលដែលយន្តការទូទាត់ ដែលត្រូវបានអនុវត្ត បានបង្ហាញពីប្រសិទ្ធភាពក្នុងការផ្តល់នូវដំណោះស្រាយភ្លាមៗចំពោះស្ថានភាពអាសន្ន ក៏មានបញ្ហាមួយចំនួនដែលរារាំងមិនឱ្យយន្តការនេះអាចត្រូវបានប្រើប្រាស់ជាកម្មវិធីសម្រាប់ការអភិវឌ្ឍនាពេលអនាគត។** បញ្ហាទាំងនេះអាចសង្ខេបជាបីចំណុចដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាដូចតទៅ (i) ប្រើប្រាស់សាច់ប្រាក់ជំនួសឱ្យការទូទាត់តាមប្រព័ន្ធឌីជីថល (ii) ការពឹងផ្អែកលើអ្នកផ្តល់សេវាតែមួយ និង (iii) ការខកខានក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ។

**បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជានៅមានកម្រិតទាបខ្លាំងនៅឡើយ។** ដូចបង្ហាញក្នុងរូប S5 ចំនួនអ្នកដែលមានគណនីជាកម្មសិទ្ធិផ្ទាល់ខ្លួននៅកម្ពុជា ស្ថិតនៅក្នុងចំណោមប្រទេសដែលមានកម្រិតទាបបំផុតនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ បច្ចុប្បន្ននេះ មានពលរដ្ឋកម្ពុជាត្រឹមតែ 21.7 ភាគរយ តែប៉ុណ្ណោះ ដែលមានគណនីប្រើប្រាស់ បើធៀបនឹងអត្រាជាមធ្យម 70.6 ភាគរយ នៅក្នុងតំបន់នេះ។ នៅពេលធ្វើការប្រៀបធៀបជាមួយនឹងប្រទេសចំណូលមធ្យមកម្រិតទាបផ្សេងទៀត ប្រទេសកម្ពុជាស្ថិតនៅក្រោយគេឆ្ងាយ បើធៀបនឹងមធ្យមភាគ 57.8 ភាគរយ សម្រាប់ក្រុមប្រទេសទាំងនេះ។ ខណៈពេលដែលការប្រើប្រាស់គណនីនៅមានកម្រិតទាប ក៏មានការកើនឡើងគួរកត់សម្គាល់ផងដែរ នៅក្នុងរយៈពេល 6 ឆ្នាំចុងក្រោយនេះ ដោយជំនួសម្ចាស់គណនីកើនឡើងពី 3.7 ភាគរយ ក្នុងឆ្នាំ 2011 ដល់ 21.7 ភាគរយ ដែលជាកម្រិតនាពេលបច្ចុប្បន្ននេះ[39]។ រូប S6 និង S7 បញ្ជាក់ពីរបកគំហើញនេះ និងបង្ហាញពីការប្រើប្រាស់ការទូទាត់តាមប្រព័ន្ធឌីជីថលដែលនៅមានកម្រិតទាបខ្លាំងនៅកម្ពុជា។

**ការអង្កេតដែលធ្វើឡើងចុងក្រោយគេលើគ្រួសារដែលកាន់ប័ណ្ណក្រីក្រ បញ្ជាក់ថា គ្រួសារភាគច្រើននៅមិនទាន់បានប្រើប្រាស់សេវាធនាគារនៅឡើយ និងសុខចិត្តជ្រើសរើសយកជម្រើសទូទាត់ជាសាច់ប្រាក់ ជាជាងការប្រើប្រាស់ឧបករណ៍ទូទាត់ដទៃទៀត (សូមមើលរូប S8 និង S9)។** ដោយសារតែលទ្ធភាពប្រើប្រាស់សេវាប្រាក់អេឡិចត្រូនិកនៅមានកម្រិត ឬពុំមានតែម្តង ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រ រដ្ឋាភិបាលត្រូវត្រៀមជាសាច់ប្រាក់ជាក់ស្តែងសម្រាប់អ្នកដែលពុំមានមធ្យោបាយផ្សេង ដើម្បីទទួលសាច់ប្រាក់ទាំងនេះ។

**សមាសភាគនៅខាងផ្នែកតម្រូវការរួមចំណែកធ្វើឱ្យបរិយាបន្នហិរញ្ញវត្ថុ និងការចាប់អារម្មណ៍លើការទូទាត់តាមប្រព័ន្ធឌីជីថលនៅកម្ពុជាមានកម្រិតទាប។** ការយល់ដឹងអំពីហិរញ្ញវត្ថុនៅមានកម្រិតទាប ជាពិសេសក្នុងចំណោមប្រជាជនដែលមានចំណូលទាប។ ក្នុងការអង្កេតដែលធ្វើឡើងកាលពីពេលថ្មីៗនេះ[40] ភាគរយអ្នកឆ្លើយតបដែលបានឆ្លើយសំណួរអំពីចំណេះដឹងហិរញ្ញវត្ថុ ត្រូវចំនួន 5 ក្នុងចំណោមសំណួរសរុបចំនួន 7 ដោយចាត់ទុកថាជាកម្រិតឆ្លើយត្រូវទាបបំផុត មាន 17 ភាគរយ (បើធៀបនឹង 26.6 ភាគរយ នៅក្នុងប្រទេសវៀតណាម ដែលជាប្រទេសទទួលបានពិន្ទុទាបមួយទៀត)។ ការបំពេញតម្រូវការហិរញ្ញវត្ថុជាមូលដ្ឋានត្រូវបានធ្វើឡើង តាមរយៈ

**រូប S5៖ ភាគរយមនុស្សពេញវ័យដែលមានគណនីផ្លូវការ**




**រូប S6៖ ភាគរយប្រជាជនដែលមានគណនីជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ឬអ្នកផ្តល់សេវាបើកប្រាក់ចល័ត**




**រូប S7៖ ភាគរយមនុស្សពេញវ័យដែលបានធ្វើការទូទាត់តាមប្រព័ន្ធឌីជីថល**




*ប្រភព៖* ប្រព័ន្ធទិន្នន័យ Global Findex Database របស់ធនាគារពិភពលោក ឆ្នាំ 2017

39 ធនាគារពិភពលោក Bank Findex; https://globalfindex.worldbank.org/sites/globalfindex/files/countrybook/Cambodia.pdf.

40 Morgan និង Trinh ឆ្នាំ 2017។

សាច់ប្រាក់ និងសេវាដែលប្រើប្រាស់សាច់ប្រាក់ ដូចជា ការទូទាត់ផ្ទាល់នៅបញ្ជរជាដើម។ សូម្បីតែនៅតាមតំបន់ប្រជុំជន ដែលការធ្វើពាណិជ្ជកម្មតាមអនឡាញមានការកើនឡើង ហើយសេវាហិរញ្ញវត្ថុឌីជីថល កាន់តែងាយស្រួលប្រើប្រាស់ ការទូទាត់ជាសាច់ប្រាក់ក្រោយការដឹកទំនិញដល់ នៅតែជាជម្រើសអាទិភាពជាងជម្រើសទូទាត់តាមប្រព័ន្ធឌីជីថល។

**រូប S8៖ តើអ្នកមានគណនីសម្រាប់ទូទាត់ដែរឬទេ?** (ភាគរយ)




**រូប S9៖** តើអ្នកប្រើមធ្យោបាយអ្វីក្រៅពីសាច់ប្រាក់ដើម្បីធ្វើការទូទាត់ដែរឬទេ?




ទិន្នន័យពីជុំទី ៤

*ប្រភព៖*ការស្ទង់មតិដោយប្រើប្រាស់ទូរស័ព្ទដៃ បែប High-Frequency អំពីស្ថានភាពជំងឺកូវីដ 19 នៅកម្ពុជា ធនាគារពិភពលោក សហភាពអឺរ៉ុប និងជំនួយអូស្ត្រាលី ឆ្នាំ 2020-2021 ។

**ប្រអប់ S2 ៖**

## ប្រព័ន្ធទូទាត់សម្រាប់អតិថិជនទូទៅនៅកម្ពុជា

**ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់ការទូទាត់ដល់អតិថិជនទូទៅនៅកម្ពុជា កំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ប៉ុន្តែមិនទាន់មានការកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់ស្ថានភាពជារួមនោះឡើយ ព្រោះថាមានការផ្តួចផ្តើមជាច្រើនដែលត្រូវបានអនុវត្ត ហើយការផ្តួចផ្តើមមួយចំនួនក៏ត្រួតគ្នាទៅទៀត។** ការអនុវត្តប្រព័ន្ធជាតិសម្រាប់ទូទាត់ ដែលប្រតិបត្តិការដោយធនាគារជាតិនៃកម្ពុជា គឺជាកត្តាមួយក្នុងចំណោមកត្តាជំរុញសំខាន់ៗដែលនាំឱ្យមានកំណើននៃការប្រើប្រាស់ការផ្ទេរឥណទានឆ្លងធនាគារនៅកម្ពុជា។ កាលពីឆ្នាំ 2016 ធនាគារជាតិនៃកម្ពុជាសហការជាមួយនឹងធនាគារពាណិជ្ជកម្ម និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលយកប្រាក់បញ្ញើ បានបង្កើតប្រព័ន្ធ (FAST) ដែលជាប្រព័ន្ធទូទាត់សម្រាប់ការផ្ទេរឥណទានដែលមានតម្លៃទាប និងការផ្តល់សេវាផ្ទេរប្រាក់គ្រប់ពេល ជាប្រាក់រៀល និងធានាយ៉ាងណាឱ្យអ្នកទទួលប្រាក់បញ្ញើ អាចទទួលបានប្រាក់ស្ទើរតែភ្លាមៗ ក្រោយពេលដែលអ្នកផ្ញើប្រាក់បានផ្ញើរួច។ ប្រព័ន្ធនេះបើកទូលាយឱ្យមានការចូលរួមពីធនាគារ គ្រឹះស្ថានផ្តល់សេវាទូទាត់ និងគ្រឹះស្ថានតូចៗ ដែលទទួលយកប្រាក់បញ្ញើ។ ប្រព័ន្ធនេះនៅមានចំនួនប្រតិបត្តិការ និងតម្លៃប្រតិបត្តិការកម្រិតទាបនៅឡើយ ហើយមិនមែនធនាគារទាំងអស់សុទ្ធតែប្រើប្រាស់សេវានេះសកម្មនោះឡើយ ដោយសារតែបញ្ហាពាក់ព័ន្ធនឹងចំណាយការវិនិយោគ។

**ធនាគារជាតិនៃកម្ពុជាកំពុងប្រកាសដាក់ឱ្យប្រើប្រាស់សាកល្បងនូវប្រព័ន្ធទូទាត់សេវាអតិថិជនទូទៅ (RPS) ដោយសហការជាមួយនឹងធនាគារ និងគ្រឹះស្ថាន MDI មួយចំនួន។** ប្រព័ន្ធទូទាត់នេះមានយន្តការទូទាត់សម្រាប់អតិថិជនទូទៅចំនួនបី (ការផ្ទេរភ្លាមៗ ប្រព័ន្ធទូទាត់ចល័ត និងប្រព័ន្ធទូទាត់ដោយប្រើប្រាស់ QR Code) និងប្រព័ន្ធទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ គោលបំណងសំខាន់នៃប្រព័ន្ធទូទាត់នេះគឺដើម្បីជំរុញនវានុវត្តន៍នៅក្នុងវិស័យទូទាត់ សម្រាប់អតិថិជនទូទៅ ធ្វើឱ្យប្រតិបត្តិការរវាងធនាគារ និងធនាគារ កាន់តែមានភាពប្រសើរ ពន្លឿនប្រសិទ្ធភាពប្រតិបត្តិការ បង្កើនសុវត្ថិភាពក្នុងការផ្ទេរប្រាក់ និងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ។

**ធនាគារជាតិនៃកម្ពុជាកំពុងជំរុញឱ្យភាពអាចប្រតិបត្តិការបញ្ចូលគ្នារវាងការទូទាត់ ដោយប័ណ្ណឥណពន្ធនៅក្នុងស្រុក តាមរយៈការបង្កើតនូវប្រព័ន្ធ Switch រួមនៅកម្ពុជា (CSS)។** ប្រព័ន្ធ CSS ដែលមានបំណងអនុញ្ញាតឱ្យមានការទូទាត់រួម សម្រាប់គ្រប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ដើម្បីបង្កើនភាពងាយស្រួល និងកាត់បន្ថយចំណាយសម្រាប់អតិថិជន និងសមាជិកនៃប្រព័ន្ធ Switch នេះ។ ប្រព័ន្ធ CSS ក៏មានបំណងគាំទ្រដល់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការប្រើប្រាស់ឧបករណ៍ទូទាត់បែបនវានុវត្តន៍ ក៏ដូចជា បង្កើនចំនួនមនុស្ស ដែលអាចប្រើប្រាស់សេវាហិរញ្ញវត្ថុបាន។

**ចុងក្រោយ ធនាគារជាតិនៃកម្ពុជាកំពុងអនុវត្តសាកល្បងនូវប្រព័ន្ធបាគង** ជាថ្នាលបច្ចេកវិទ្យាកាបូបប្រាក់ (wallet-based platform) ដែលប្រើប្រាស់បណ្តាញបច្ចេកវិទ្យា permissioned distributed-ledger technology-DLT។ បច្ចុប្បន្ននេះ ប្រព័ន្ធបាគងត្រូវបានរៀបចំសម្រាប់ការអនុវត្តប្រតិបត្តិការតូចៗដែលមានតម្លៃទាប។

**ក្នុងពេលជាមួយគ្នា កត្តាជាច្រើននៅខាងផ្នែកផ្គត់ផ្គង់ហាក់ដូចជាបង្កការបន្ទុចបង្អាក់ ជាជាងជំរុញកំណើនឱ្យមានការកើនឡើង។** ឧទាហរណ៍ ការទទួលយកការទូទាត់តាមប្រព័ន្ធឌីជីថលនៅមានកម្រិតនៅឡើយ ហើយមានការលើកទឹកចិត្តតិចតួចឱ្យអាជីវករទទួលយកការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់។ ប្រព័ន្ធកូដឆ្លើយតបរហ័ស (QR Code) ដែលត្រូវបានប្រើប្រាស់កាន់តែទូទៅនៅក្នុងតំបន់នេះ ព្រោះជាវិធីដែលចំណាយទាប ដើម្បីបង្កើនកម្រិតនៃការទទួលយកយ៉ាងឆាប់រហ័ស ក៏កំពុងត្រូវបានអនុវត្តនៅកម្ពុជាផងដែរ ប៉ុន្តែ អ្វីដែលជាការបារម្ភគឺការប្រើប្រាស់ប្រព័ន្ធនេះនៅមានភាពបែកខ្ញែកពីគ្នា និងកង្វះលទ្ធភាពអាចប្រើប្រាស់បញ្ចូលគ្នាបាន។ ការកំណត់តម្លៃសម្រាប់សេវាមួយចំនួន អាចថ្លៃពេក ជាពិសេសសម្រាប់ប្រតិបត្តិការដែលអស់ថ្លៃទាប[41]។ បើទោះជា ចាំបាច់ត្រូវមានការប្រមូលទិន្នន័យបន្ថែម និងវិភាគលើទិន្នន័យទាំងនេះ ដើម្បីធ្វើការបញ្ជាក់លើចំណុចនេះក៏ដោយ នវានុវត្តន៍ក្នុងផ្នែកខ្លះនៃទីផ្សារ ដូចជាការប្រមូលផ្តុំការទូទាត់ ច្រកសម្រាប់ធ្វើការទូទាត់ និងសេវានៅផ្នែកខាងក្រោយ (Back-end) ផ្សេងទៀត ក៏នៅមានកម្រិតផងដែរ។

**ហេដ្ឋារចនាសម្ព័ន្ធសម្រាប់អនុវត្តប្រព័ន្ធទូទាត់នៅកម្ពុជា ត្រូវបានអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជានៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែ ប្រព័ន្ធនេះនៅមានភាពបែកខ្ញែកពីគ្នា និងមិនអាចគាំទ្រដល់ការផ្តល់អត្ថប្រយោជន៍សង្គមឱ្យមានប្រសិទ្ធភាពបាន។** ដូចរៀបរាប់នៅក្នុងប្រអប់ S2 ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្ត និងដំណើរការប្រព័ន្ធទូទាត់ជាមួយនឹងអតិថិជនទូទៅជាច្រើន។ ប៉ុន្តែ ភាពបែកខ្ញែកនៃហេដ្ឋារចនាសម្ព័ន្ធនេះ ធ្វើឱ្យកម្ពុជាពុំមានប្រព័ន្ធមួយដែលមានភាពរឹងមាំ និងមានការចូលរួមប្រើប្រាស់ច្រើនគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់បែងចែកអត្ថប្រយោជន៍របស់រដ្ឋាភិបាល ឬផ្តល់ការទូទាត់ផ្សេងទៀតរបស់រដ្ឋាភិបាលនៅក្នុងប្រទេស។

**នៅក្នុងបរិបទនេះ ជម្រើសតែមួយគត់ដែលមានសម្រាប់បើកផ្តល់ប្រាក់ឱ្យបានលឿន និងប្រកបដោយប្រសិទ្ធភាពសម្រាប់អ្នកដែលជួបការខ្វះខាតគឺត្រូវប្រើប្រាស់បណ្តាញភ្នាក់ងារដែលមានស្រាប់ សម្រាប់បើកផ្តល់សាច់ប្រាក់។** ក្រុមហ៊ុនវីង គឺជាក្រុមហ៊ុនដែលមានវិសាលភាពគ្របដណ្តប់ទូលំទូលាយជាងគេនៅក្នុងប្រទេសនេះ ហើយក្រុមហ៊ុននេះអាចទទួលយកកិច្ចការបន្ថែម ដូចជា បង្កើតភ្នាក់ងារថ្មីៗនៅតាមទីកន្លែងណា ដែលមិនទាន់មានការផ្តល់សេវាឱ្យបានល្អនោះឡើយ។ ទោះជាយ៉ាងនេះក្តី បើទោះជាក្រុមហ៊ុនវីង គឺជាអ្នកផ្តល់សេវាទូទាត់តាមប្រព័ន្ធឌីជីថលក៏ដោយ សក្តានុពលនវានុវត្តន៍របស់ក្រុមហ៊ុននេះ មិនអាចយកមកប្រើប្រាស់ក្រៅតែពីប្រតិបត្តិការបើកសាច់ប្រាក់នោះឡើយ[42]។ លើសពីនេះ ទៅថ្ងៃមុខ បើការពឹងផ្អែកលើអ្នកផ្តល់សេវាតែមួយគត់សម្រាប់បើកផ្តល់អត្ថប្រយោជន៍ផ្នែកសង្គម និងការទូទាត់ផ្សេងទៀតរបស់រដ្ឋាភិបាល មានហានិភ័យធ្វើឱ្យអ្នកផ្តល់សេវាតែមួយនេះកាន់តែគ្របលើទីផ្សារ។

**ប្រអប់ S3 ៖**

## ទីផ្សារសម្រាប់សេវាទូទាត់សម្រាប់អតិថិជនទូទៅនៅកម្ពុជា

**នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឧស្សាហកម្មបច្ចេកវិទ្យាបម្រើដល់ការទូទាត់ (“Fintech”) និងហិរញ្ញវត្ថុ មានការរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជា។** ដោយមានការគាំទ្រពីបទបញ្ញាថ្មីៗរបស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមិនមែនធនាគារ បានដាក់ឱ្យប្រើប្រាស់នូវជម្រើសទូទាត់ និងជម្រើសផ្ទេរប្រាក់ជាច្រើនប្រភេទ សម្រាប់ទាំងបុគ្គល ទាំងអាជីវកម្ម។ គិតត្រឹមចុងឆ្នាំ 2018 គ្រឹះស្ថានផ្តល់សេវាទូទាត់ ចំនួន 16 បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាទូទាត់ ដូចជា សេវាផ្ទេរចូល និងផ្ទេរចេញ ការទូទាត់វិក្កយបត្រ ការទូទាត់សម្រាប់អតិថិជនទូទៅ ការទូទាត់តាមប្រព័ន្ធអនឡាញ និងការផ្ទេរប្រាក់ឆ្លងដែនជាដើម។ ក្រុមហ៊ុនដែលមានឈ្មោះបោះសំឡេងមួយចំនួននៅលើទីផ្សារ មានដូចជា Wing, True Money, Asia Wei Luy, PayGo, និង PiPay។

**ការប្រកួតប្រជែងក្នុងចំណោមក្រុមហ៊ុន ទូទាត់សេវាអតិថិជនទូទៅ ទាំងនេះ ហាក់បីដូចជាមានសន្ទុះខ្លាំងក្លា និងពុំមានរបាំងអ្វីគួរឱ្យកត់សម្គាល់ ដែលរារាំងដល់ការចូលមកក្នុងទីផ្សារនេះពីអ្នកផ្តល់សេវាថ្មីៗនោះឡើយ។** ជាមួយនឹងធនាគារចំនួន 41 គ្រឹះស្ថានផ្តល់សេវាទូទាត់ចំនួន 16 និងធនាគារឯកទេសចំនួន 4 នេះ គឺជាចំនួនអ្នកផ្តល់សេវាដ៏ល្អនៅក្នុងទីផ្សារ ដែលផ្តល់ផលិតផលទូទាត់តាមប្រព័ន្ធឌីជីថលជាច្រើនប្រភេទ។ ធនាគារជាច្រើនបានដាក់ឱ្យប្រើប្រាស់ ឬកំពុងស្ថិតនៅក្នុងដំណើរការដាក់ឱ្យប្រើប្រាស់នូវសេវាធនាគារចល័ត និងតាមប្រព័ន្ធអនឡាញ សម្រាប់អតិថិជនទូទៅផង និងអតិថិជនដែលជាអាជីវកម្មផង[43]។

---

41 ការចំណាយលើប្រតិបត្តិការដែលមានតម្លៃទាបខ្លាំង សម្រាប់ករណីដែលមានការប្រើប្រាស់សេវាច្រើនដង អាចមានតម្លៃថ្លៃរហូតដល់ស្មើនឹង 38 ភាគរយនៃតម្លៃប្រតិបត្តិការ។ នេះគឺជាតម្លៃខ្ពស់ខ្លាំង និងធ្វើឱ្យបុគ្គលដែលមានចំណូលទាប មិនផ្ញើប្រាក់ក្នុងចំនួនតិចតួច តាមរយៈច្រកឌីជីថលនោះ (World Bank ឆ្នាំ 2019)។

42 គួរកត់សម្គាល់ថា ប្រតិបត្តិការភាគច្រើនដែលធ្វើឡើង តាមរយៈបណ្តាញវីង ក្រៅតែពីការឧបត្ថម្ភសាច់ប្រាក់សម្រាប់កម្មវិធីជំនួយសង្គម នៅមានការដកប្រាក់នៅនឹងបញ្ជរផងដែរ។ ការរាតត្បាតជាសកលនៃជំងឺកូវីដ-19 ហាក់បីដូចជាបានពន្លឿនកំណើននៃប្រតិបត្តិការតាមប្រព័ន្ធ ឌីជីថលទាំងស្រុង ប៉ុន្តែ លើសពីនេះ នៅមានបញ្ហាប្រឈមដែលនៅសេសសល់ជាច្រើនទៀត (ការយល់ដឹង និងការជឿទុកចិត្តរបស់អតិថិជន ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាត និងករណីដែលមានការប្រើប្រាស់គ្រប់គ្រាន់។ល។)

43 ធនាគារជាតិនៃកម្ពុជា ការវាយតម្លៃលើស្ថិរភាពហិរញ្ញវត្ថុ https://www.nbc.org.kh/download_files/publication/annual_rep_eng/FSR-for-publication-final-22Apr2019.pdf

ជាសេចក្តីសន្និដ្ឋាន ដំណោះស្រាយដែលត្រូវបានអនុវត្ត បើទោះជាងាយស្រួលអនុវត្ត ដោយសារ តែកាលៈទេសៈ មិនមែនជាអ្វីដែលល្អបំផុតសម្រាប់ទំនើបកម្មនោះឡើយ ព្រោះថា វាពុំបានរួមចំណែកឱ្យមានបរិយាបន្នហិរញ្ញវត្ថុ ពុំបានផ្តល់ជាជម្រើសដល់អ្នកទទួលផល និងអាចធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងនៅក្នុងទីផ្សារផ្តល់សេវាទូទាត់។

**គេអាចប្រមូលចងក្រងមេរៀនជាច្រើន ចេញពីបទពិសោធន៍នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សង្គ្រោះក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ 19 ដើម្បីបន្តធ្វើកំណែទម្រង់វិស័យកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល ខណៈពេលដែលក្រុមប្រឹក្សាជាតិគាំពារសង្គម កំពុងស្ថិតនៅក្នុងដំណើរការអនុវត្តរួចទៅហើយ។ មេរៀនទាំងនេះ រួមមាន៖**

- កម្មវិធីដែលយន្តការបើកផ្តល់ ផ្តោតសំខាន់លើតួនាទីរបស់មេគ្រួសារ ដែលជាសមាជិកសង្គម ដែលបានត្រៀមខ្លួនតិចតួចជាងគេក្នុងការទទួលយក និងប្រើប្រាស់ឧបករណ៍ឌីជីថល មិនអាចបង្កើតនូវបរិយាកាសអំណោយផលសម្រាប់ឌីជីថលភាវូបនីយកម្មឡើយ។ ចាំបាច់ត្រូវមានការធ្វើសកម្មភាពជាច្រើនបន្ថែមទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានដល់ប្រជាជនដែលមាន វ័យក្មេងជាងគេ អំពីការអភិវឌ្ឍកម្មវិធីនាពេលអនាគត។
- ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងធំៗត្រូវធ្វើឡើងនៅថ្នាក់ជាតិ ដើម្បីជំរុញឱ្យមានការផ្តល់សេវាទូទាត់តាមប្រព័ន្ធឌីជីថល និងកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ ដូចជា តាមរយៈគំនិតផ្តួចផ្តើមអប់រំ និងបង្កើនការយល់ដឹងអំពីរបៀបប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធឌីជីថល របៀបប្រើប្រាស់គណនីការបូបប្រាក់ចល័ត តាមរយៈទូរស័ព្ទដៃ និងរបៀបដែលច្រកទូទាត់តាមប្រព័ន្ធឌីជីថលអាចផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការរបស់ខ្លួនបាន ចាប់ពីការផ្ទេរប្រាក់ រហូតដល់ការទទួលបានប្រាក់បៀវត្សរ៍ និងជំនួយសង្គមតាមប្រព័ន្ធអ៊ីនអេឡិចត្រូនិកពីរដ្ឋាភិបាល។
- ក្នុងពេលជាមួយគ្នា ក៏ចាំបាច់ត្រូវមានការកែលំអហេដ្ឋារចនាសម្ព័ន្ធទូទាត់ដែលមានស្រាប់ និងត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនេះឱ្យកាន់តែមានប្រសិទ្ធភាព (ដូចជា ក្នុងករណីប្រទេសថៃ[44] និងហ្ស៊ីដង់ សូមមើលប្រអប់ S4 អាចជាឯកសារយោងដ៏មានប្រយោជន៍សម្រាប់ចំណុចនេះ)។ វិធានការទាំងនេះ និងវិធានការដទៃទៀត ដែលត្រូវបានលើកយកមកធ្វើការពិភាក្សានៅក្នុងផ្នែកបន្ទាប់ គួរយកមកធ្វើការពិចារណាជាលក្ខណៈយុទ្ធសាស្ត្រ ជាវិធីមិនត្រឹមតែបន្តពង្រឹងភាពធន់របស់សេដ្ឋកិច្ច និងសង្គមចំពោះវិបត្តិប៉ុណ្ណោះទេ ថែមទាំងអាចជួយធ្វើទំនើបកម្មសេវាបើកផ្តល់កម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល ក្នុងសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស ដូចជា កម្ពុជា ជាដើម និងអាចយកមកអនុវត្តកាន់តែទូទៅ ដើម្បីជួយសម្រួលឱ្យប្រជាពលរដ្ឋគ្រប់រូប អាចប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមតាមប្រព័ន្ធឌីជីថលបាន។

**ប្រអប់ S4 ៖**

### ករណីសិក្សារបស់ប្រទេសហ្ស៊ីដង់៖ ការបិទខ្ទប់មិនមែនជាការបិទទាំងស្រុងឡើយ

នៅក្នុងប្រទេសហ្ស៊ីដង់ រដ្ឋាភិបាល និងស្ថាប័នសំខាន់ៗមួយចំនួនរបស់ខ្លួន បានចាប់យកឱកាសនេះ ដើម្បីឱ្យប្រជាពលរដ្ឋដែលត្រូវបានផាត់ចេញសេវាហិរញ្ញវត្ថុ អាចចូលរួមនៅក្នុងកម្មវិធីហិរញ្ញវត្ថុឌីជីថល បង្កើនបរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងការទទួលយក និងផ្សព្វផ្សាយសេវាកម្មប្រព័ន្ធឌីជីថល ពេលដែលមានការរាតត្បាតជាសកលនៅថ្ងៃដំបូងៗ រដ្ឋាភិបាលបានប្រកាសប្រើប្រាស់ច្រកទូទាត់តាមប្រព័ន្ធឌីជីថល ជំនួសឱ្យសាច់ប្រាក់ ដោយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ និងនិយោជកប្រើប្រាស់កាបូបប្រាក់ចល័ត ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ។ ក្រសួងការងារបានអំពាវនាវឱ្យនិយោជកបើកបៀវត្សរ៍តាមប្រព័ន្ធឌីជីថលដែលកាលពីមុនពេលមានការរាតត្បាតជាសកលត្រូវបានធ្វើឡើងដោយប្រើប្រាស់សាច់ប្រាក់។

អ្វីដែលធ្វើឱ្យការផ្លាស់ប្តូរឆ្ពោះទៅរកហិរញ្ញវត្ថុតាមប្រព័ន្ធឌីជីថលមានភាពរលូន គឺការមានហេដ្ឋារចនាសម្ព័ន្ធទូទាត់តាមប្រព័ន្ធឌីជីថលដ៏រឹងមាំនៅក្នុងប្រទេសនេះ។ ស្ថាប័នជាតិសំខាន់ៗចំនួនពីរ គឺ មូលនិធិដែលផ្តល់ជំនួយជាតិ និងសាជីវកម្មសន្តិសុខសង្គម បានប្រកាសថា រាល់ប្រាក់ជាមួយនឹងការទូទាត់គឺវានឹងត្រូវធ្វើឡើង តាមរយៈធនាគារ ឬកាបូបប្រាក់ចល័តតែប៉ុណ្ណោះ។ សេវាហិរញ្ញវត្ថុឌីជីថលនិយាយជាទូទៅ និងនិយាយដោយឡែក សេវាកាបូបប្រាក់ចល័តចាប់ផ្តើមមានវត្តមានលើសលប់នៅក្នុងទីផ្សារនៅពាក់កណ្តាល ខែ មីនា ឆ្នាំ 2020 ជាពិសេស ដោយសារតែភ័យខ្លាចឆ្លងជំងឺ តាមរយៈក្រដាសប្រាក់ដែលមានប្រឡាក់ប្រឡូសនឹងមេរោគ។

ប្រទេសហ្ស៊ីដង់បានជ្រើសរើសយកសេវាទូទាត់តាមទូរស័ព្ទចល័ត។ ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋជាច្រើន បានដាក់ឱ្យប្រើប្រាស់នូវសេវាទូទាត់ចល័តដល់អ្នកទទួលផល ដើម្បីជំនួសការទូទាត់ជាសាច់ប្រាក់ដែលធ្លាប់តែធ្វើកន្លងមក។ កាបូបប្រាក់ចល័ត ដែលកំពុងដំណើរការនៅក្នុងប្រទេសនេះ កើនឡើងទ្វេដងនៅក្នុងរយៈពេល 4 ខែ រហូតដល់មានអ្នកប្រើប្រាស់ជាង 1 លាននាក់។

*ប្រភព៖* JOPACC ឆ្នាំ 2020

---

44 ឧទាហរណ៍នៃកម្មវិធីផ្តល់សំណងប្រាក់ចំណូល សម្រាប់អ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ “មិនទុកអ្នកណាម្នាក់ចោល” អាចជាឧទាហរណ៍ដ៏មានប្រយោជន៍នៅក្នុងន័យនេះ។ នៅក្នុងប្រទេសថៃ ប្រជាពលរដ្ឋអាចប្រើប្រាស់ប្រព័ន្ធអនឡាញ និងផ្ទៀងផ្ទាត់បញ្ជាក់ខ្លួនឯង ដោយការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ដោយត្រូវមានការផ្ទៀងផ្ទាត់ពីក្រសួងហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ថាតើលេខអត្តសញ្ញាណប័ណ្ណដែលបានប្រើប្រាស់កន្លងមក កំពុងមាននៅក្នុងប្រព័ន្ធចុះបញ្ជីដទៃទៀត ដែលបង្ហាញថាអ្នកដាក់ពាក្យសុំនេះ គួរតែត្រូវបានផាត់ចេញ ប្រសិនបើពួកគេជានិយោជិតក្នុងវិស័យក្នុងប្រព័ន្ធ ឬបានទទួលអត្ថប្រយោជន៍ផ្សេងទៀត។ ការទូទាត់របស់រដ្ឋាភិបាលត្រូវធ្វើឡើង តាមរយៈប្រព័ន្ធ PromptPay ដែលជាប្រព័ន្ធទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច ទៅកាន់គណនីដែលភ្ជាប់ជាមួយនឹងលេខអត្តសញ្ញាណប័ណ្ណ (ព័ត៌មាននេះគឺជាព័ត៌មានបឋម និងផ្អែកលើការសិក្សាផ្ទៃក្នុងរបស់ធនាគារពិភពលោក ដែលកំពុងអនុវត្តនៅឡើយ)។

# អនុសាសន៍គោលនយោបាយ

## កែលម្អទិដ្ឋភាពរួមអំពីជំនួយសង្គមនៅកម្ពុជា

**កម្មវិធីផ្ទេរសាច់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលកូវីដ 19 បង្ហាញឱ្យឃើញពីប្រសិទ្ធភាពនៃកិច្ចគាំពារសង្គម ដែលអាចមាននៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះ។** ទោះជាជំងឺរាតត្បាតចប់ទៅហើយ ក៏ផលប៉ះពាល់នៅតែបន្តមានរយៈពេលយូរ។ នៅពេលដែលកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះចប់ទៅ កម្ពុជានឹងត្រូវបង្កើតកម្មវិធីគាំពារសង្គមឱ្យកាន់តែប្រសើរថែមទៀត ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដែលបានរងការប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺរាតត្បាតនេះ ក៏ដូចជា ដោយសារវិបត្តិសេដ្ឋកិច្ច និងភាពងាយរងគ្រោះផ្សេងៗនាអនាគត។ វិធានការខាងក្រោមនេះអាចជួយតម្រង់ទិសកម្ពុជាឱ្យសម្រេចគោលដៅនេះបាន ។

**ពង្រីកវិសាលភាពកម្មវិធីប័ណ្ណក្រីក្រ។** កម្មវិធីផ្ទេរប្រាក់ឧបត្ថម្ភបច្ចុប្បន្ន បានកម្រិតទៅតាមវិសាលភាពនៃមូលដ្ឋានទិន្នន័យប័ណ្ណក្រីក្រ ដែលក្នុងចំណោមប្រាំគ្រួសារ មានមិនដល់មួយគ្រួសារផងក្នុងទិន្នន័យនេះ។ ផលប៉ះពាល់នៃជំងឺរាតត្បាតនេះមានលើសពី 17 ភាគរយនៃគ្រួសារក្នុងកម្មវិធីប័ណ្ណក្រីក្របច្ចុប្បន្ននេះ។ ក្នុងចំណោមគ្រួសារដែលមិនបានចូលក្នុងកម្មវិធីនេះ មានដូចជា គ្រួសារដែលស្ថិតនៅជិតបន្ទាត់ក្រីក្រ ឬងាយរងគ្រោះ គ្រួសារសហគ្រិនខ្នាតតូច អ្នកធ្វើការក្នុងវិស័យទេសចរណ៍ អ្នកពឹងផ្អែកលើចំណូលពីកម្មករចំណាកស្រុកដែលផ្ញើរប្រាក់មកគ្រួសារ ជាដើម។ កង្វះខាតមូលដ្ឋានទិន្នន័យដែលគ្របដណ្តប់ឱ្យបានទូលាយ លើសពីមូលដ្ឋានទិន្នន័យប័ណ្ណក្រីក្រនេះ ធ្វើឱ្យរដ្ឋាភិបាលមិនមានលទ្ធភាពក្នុងការកំណត់គោលដៅកម្មវិធីគាំពារសង្គមឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។

**បង្កើតមូលដ្ឋានទិន្នន័យប័ណ្ណក្រីក្រសម្រាប់ចុះឈ្មោះអ្នកដែលទទួលផលដែលមានសក្តានុពលនៃកម្មវិធីគាំពារសង្គមទាំងអស់។** ការពង្រីកវិសាលភាពកម្មវិធីប័ណ្ណក្រីក្រនឹងត្រូវធ្វើឡើងទន្ទឹមគ្នាជាមួយនឹងការកែទម្រង់បន្ថែមធ្វើយ៉ាងណាប្រែក្លាយមូលដ្ឋានទិន្នន័យនេះទៅជាបញ្ជីសង្គមមួយ សម្រាប់គ្រប់កម្មវិធីគាំពារសង្គមទាំងអស់។ ការកែទម្រង់ដែលត្រូវធ្វើជាចាំបាច់រួមមាន (1) ធ្វើទំនើបកម្មប្រព័ន្ធដាក់ពិន្ទុ (ដូចជាការប្រើតេស្តរកមធ្យមភាគជាស្វ័យប្រវត្តិក្នុងការកំណត់ពិន្ទុលើកម្រិតជីវភាព) ដើម្បីទទួលបានចំណាត់ថ្នាក់គ្រួសារបានកាន់តែប្រសើរ ដោយញែកជាកម្រិតផ្សេងៗនៃភាពក្រីក្រ និងងាយរងគ្រោះ (2) ភ្ជាប់កម្មវិធីនេះជាមួយនឹងប្រព័ន្ធអត្តសញ្ញាណប័ណ្ណជាតិ និងទិន្នន័យរដ្ឋបាលផ្សេងៗ ព្រមទាំង (3) បញ្ចូលការឆ្លើយតបទៅនឹងវិបត្តិ និងធាតុផ្សំផ្សេងៗនៃភាពងាយរងគ្រោះ ទៅក្នុងប្រព័ន្ធប័ណ្ណក្រីក្រ ដើម្បីធានាថា កម្មវិធីគាំពារសង្គមទាំងឡាយអាចកំណត់ក្រុមគោលដៅដាក់លាក់បន្ថែមទៀត ។

**ធានាឱ្យមានអត្ថប្រយោជន៍គ្រប់គ្រាន់នៃកម្មវិធីដែលមានស្រាប់។** ការទទួលបានកិច្ចគាំពារសង្គមមានសារៈសំខាន់ ប៉ុន្តែការទទួលបានអត្ថប្រយោជន៍គ្រប់គ្រាន់ក៏ជាកត្តាសំខាន់សម្រាប់ជាកិច្ចគាំពារសង្គមដែលមានប្រសិទ្ធភាពនោះ។ ដូចបានរៀបរាប់ខាងលើលទ្ធផលនៃកិច្ចគាំពារសង្គមកើនឡើងស្របនឹងបរិមាណប្រាក់ដែលបានផ្ទេរ ហើយសាច់ប្រាក់ផ្ទេរតិចពេកអាចធ្វើឱ្យគ្មានប្រសិទ្ធភាព។ ឧទាហរណ៍កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារតូច ផ្តល់ 190 ដុល្លារសហរដ្ឋអាមេរិក ដល់ស្ត្រីដែលត្រូវការការថែទាំងសុខភាពមុន និងក្រោយមាតុភាព សម្រាប់រយៈពេលបីឆ្នាំ។ អត្ថប្រយោជន៍ទាំងនេះអាចជំរុញឱ្យមានទម្លាប់ក្នុងការស្វែងរកការថែទាំសុខភាព ប៉ុន្តែ អត្ថប្រយោជន៍ទាំងនោះមិនបានគ្រប់គ្រាន់សម្រាប់បង្កើនអាហារូបត្ថម្ភសម្រាប់មាតា និងទារកនោះទេ។ អត្ថប្រយោជន៍កម្មវិធីកាន់តែច្រើនធ្វើឱ្យមានប្រសិទ្ធភាពកាន់តែខ្ពស់ក្នុងការជួយដល់ជនក្រីក្រ និងងាយរងគ្រោះឱ្យចាកចេញផុតពីភាពក្រីក្រ។

**បង្កើតកិច្ចគាំពារសង្គមដែលផ្អែកលើភស្តុតាង ដើម្បីជួយដល់ជនក្រីក្រ និងងាយរងគ្រោះ។** កម្មវិធីជួយឧបត្ថម្ភនេះផ្តល់ឱកាសល្អឱ្យកម្ពុជារៀនសូត្របានពីសារៈសំខាន់ និងប្រសិទ្ធភាពនៃកិច្ចគាំពារសង្គម។ តម្រូវការសម្រាប់កិច្ចគាំពារសង្គមរយៈពេលវែងត្រូវបានបង្ហាញឃើញយ៉ាងច្បាស់រួចហើយ។ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំពុងរៀបផែនការដាក់ចេញវិធានការគាំពារសង្គម សម្រាប់ពេលក្រោយជំងឺកូវីដ 19 ។ ទម្រង់កម្មវិធី និងវិសាលភាពគាំពារ គួរតែផ្អែកទៅលើភស្តុតាងជាសកល និងស្របតាមបរិបទនៃអត្ថប្រយោជន៍ និងប្រសិទ្ធភាពក្នុងការជួយដល់ជនក្រីក្រ និងងាយរងគ្រោះ។

## កែលម្អជំនួយសាច់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋនៅក្នុងសេណារីយ៉ូបច្ចុប្បន្ន

**ដូចបានរៀបរាប់ខាងលើ កម្មវិធីប្រាក់ឧបត្ថម្ភកូវីដ-19 ឃើញថាមានប្រសិទ្ធភាពនៅក្នុងការទៅដល់បណ្តាអ្នកទទួលផលជាច្រើនក្នុងរយៈពេលខ្លី ដែលត្រូវការចាំបាច់ក្នុងគ្រាអាសន្ន។** ការកែលម្អមួយចំនួនអាចលើកមកពិចារណាសម្រាប់កិច្ចការប្រហាក់ប្រហែលគ្នានេះនាពេលឆាប់ៗខាងមុខ ដោយសន្មតថា ស្ថានភាពបច្ចុប្បន្ននឹងមិនមានការផ្លាស់ប្តូរច្រើន ផ្អែកលើទស្សនៈវិស័យនៃបទដ្ឋានគតិយុត្តិហេដ្ឋារចនាសម្ព័ន្ធ បរិយាប័ន្នហិរញ្ញវត្ថុ និងការអប់រំ។

**ធនាគារជាតិកម្ពុជាគួរត្រូវបានចាត់ទុកជាភាគីសំខាន់ចំពោះការពិភាក្សាលើយន្តការផ្តល់សាច់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ។** ធនាគារជាតិគឺជាអ្នកត្រួតពិនិត្យប្រព័ន្ធទូទាត់ប្រាក់ជាតិ។ អាស្រ័យហេតុនេះ ធនាគារជាតិគួរតែធានាឱ្យបាននូវដំណើរការប្រព័ន្ធទូទាត់

ប្រាក់ជាតិ ដោយរលូន សុវត្ថិភាព និងប្រសិទ្ធភាព ដោយការផ្តល់ប្រាក់ប្រព័ន្ធទូទាត់ប្រាក់ជាតិជាផ្នែកមួយដែរ។ មតិរបស់ធនាគារជាតិមានសារៈសំខាន់ខ្លាំងសម្រាប់ណែនាំអង្គភាពផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការផ្តល់ឱ្យមានជម្រើសបង់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ សម្រាប់កំណត់រកមធ្យោបាយថ្មីៗ ដែលមានប្រសិទ្ធភាពបំផុត។ ចំណុចនេះរួមបញ្ចូលទាំង វិធីប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធជាតិនេះ (គឺ ប្រព័ន្ធទាំងឡាយដែលធនាគារជាតិ ប្រតិបត្តិ)។ លើសពីនេះទៀត ដោយសារតែវិសាលភាពនៃកម្មវិធីពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ ធនាគារជាតិគួរវាយតម្លៃលើលទ្ធផលដែលអាចនឹងទទួលបានមកពីយន្តការទូទាត់ប្រាក់ដែលមានចំពោះការប្រកួតប្រជែងនៅក្នុងទីផ្សារទូទាត់ប្រាក់។ ចុងបញ្ចប់ ធនាគារជាតិគួរតែប្រមូលផ្តុំយកទស្សនវិស័យបរិយាប័ន្នហិរញ្ញវត្ថុ ដោយសារការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋត្រូវបានចាត់ទុកថាជាករណីប្រើប្រាស់មានប្រសិទ្ធភាពដែលអាចជួយពង្រីកបរិយាប័ន្នហិរញ្ញវត្ថុ[45]។

**គួរតែមានការប្រឹងប្រែងបន្ថែមទៀតឱ្យមានអ្នកផ្តល់សេវាចំនួនលើសពីមួយ សម្រាប់ការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ។** នៅពេលដែលបែងចែកការទូទាត់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ វិធីមានប្រសិទ្ធភាពជាញឹកញាប់ គឺត្រូវប្រើប្រាស់ឱ្យបាននូវបណ្តាញផ្តល់សេវាទូទាត់ធំជាងគេនៅក្នុងប្រទេស។ ការសម្រេចគោលដៅនេះក្នុងរយៈពេលខ្លី ជាពិសេស ក្នុងករណីត្រូវពង្រីកសេវាឱ្យបានឆាប់រហ័ស ការបែងចែកបែបនេះអាចមានផលអវិជ្ជមានទៅលើទីផ្សារសេវាទូទាត់ប្រាក់នៅក្នុងប្រទេស។ ការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋអនុញ្ញាតឱ្យអ្នកផ្តល់សេវាធំជាងគេនោះពង្រឹងឥទ្ធិពលរបស់ខ្លួនកាន់តែខ្លាំងនៅក្នុងទីផ្សារ ពង្រីកបណ្តាញភ្នាក់ងារ ឬសាខា និងបង្កើនទំនុកចិត្ត ព្រមទាំងការពេញនិយមចំពោះស្លាកសញ្ញានៅក្នុងចំណោមប្រជាពលរដ្ឋ។ លំនាំនេះធ្វើឱ្យគូប្រកួតផ្សេងៗទៀតមិនងាយធ្វើទៅបាន បណ្តាលឱ្យរាំងស្ទះការប្រកួតប្រជែងក្នុងទីផ្សារ។ ជាលទ្ធផល ស្ថានភាពនេះអាចនឹងធ្វើឱ្យកម្មវិធីការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋនាពេលអនាគត កាន់តែត្រូវចំណាយខ្ពស់ ដោយសារអ្នកផ្តល់សេវាលេចធ្លោជាងគេនោះអាចនឹងចរចាបង្កើនកម្រៃសេវាប្រតិបត្តិការទូទាត់នេះ។

**អាចផ្តល់ជម្រើសក្នុងការទទួលថវិកាតាមប្រព័ន្ធអេឡិចត្រូនិកទៅក្នុងគណនី ឬប្រអប់ប្រាក់ ដល់អ្នកទទួលផល។** សាច់ប្រាក់គឺជាជម្រើសល្អដែលអ្នកទទួលផលពីការឧបត្ថម្ភនេះចង់បានជាងគេបំផុតនៅកម្ពុជាដូចដែលបានរៀបរាប់ខាងលើ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់អត្ថប្រយោជន៍សង្គមគួរតែចាត់ទុកជាឱកាសមួយសំខាន់ក្នុងការបង្កើត និងប្រើប្រាស់គណនីទូទាត់ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត។ កម្មវិធីផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ អាចជាឱកាសតែមួយគត់ដែលរាជរដ្ឋាភិបាលកម្ពុជាយកទៅប្រើក្នុងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា ដោយបង្កើនប្រជាប្រិយភាព និងការទុកចិត្តពីសំណាក់អ្នកទទួលផលទៅលើសេវាគាំពារសង្គមតាមមធ្យោបាយអេឡិចត្រូនិក។ ទោះជាស្ថានភាពបច្ចុប្បន្នមិនទាន់មានលក្ខណៈអំណោយផលសម្រាប់ទូទាត់តាមអេឡិចត្រូនិកតែមួយមុខ (ឬដោយស្វ័យប្រវត្តិ) នៅកម្ពុជាក៏ដោយ ដោយសារនៅមានចំណេះដឹងទាបផ្នែកហិរញ្ញវត្ថុ ការជំរុញបែបនេះនៅតែជាវិធានការដំបូងដែលត្រូវធ្វើ ដើម្បីផ្តល់ឱកាសឱ្យអ្នកទទួលផល មានជម្រើសធ្វើបាន ប្រសិនបើចង់ទទួលថវិកាចូលគណនី ឬប្រអប់ប្រាក់។

### កែលម្អការផ្តល់ជំនួយសាច់ប្រាក់របស់រដ្ឋាភិបាល ៖ សេណារីយ៉ូដែលអាចកើតមាននាពេលអនាគត

**ការអនុវត្តការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ អាចកែលម្អបន្ថែមនៅកម្ពុជា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវរបៀបវារៈកែទម្រង់ក្នុងទ្រង់ទ្រាយធំ។** តាមរយៈការដាក់នូវរបៀបវារៈកែទម្រង់ទ្រង់ ទ្រាយធំ និងបង្កើនការសម្របសម្រួលក្នុងចំណោមអាជ្ញាធរផ្សេងៗ រាជរដ្ឋាភិបាលអាចនឹងបង្កើនបានយ៉ាងច្រើននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋនៅកម្ពុជានាពេលអនាគត។ ការរៀបចំបែបនេះអាចធ្វើតាមវិធីស្រដៀងគ្នានឹងប្រទេសឥណ្ឌូណេស៊ី ដែលរដ្ឋាភិបាលតាមរយៈការឧបត្ថម្ភពីធនាគារពិភពលោកកំពុងតែកែទម្រង់ទ្រង់ទ្រាយធំលើវិស័យ (ហៅថា ការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ 4.0) ដើម្បីកែលម្អយន្តការអនុវត្តផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ នៅក្នុងប្រទេស ។

**ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូទាត់ជាតិ ដែលប្រតិបត្តិការដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានប្រើសម្រាប់បែងចែកការទូទាត់ការផ្តល់ប្រាក់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋនៅកម្ពុជា។** ធនាគារជាតិប្រតិបត្តិការប្រព័ន្ធទូទាត់ជាច្រើន (សូមមើលប្រអប់ S.2) ក្នុងនោះមានមួយចំនួនមានលទ្ធភាពបញ្ចេញថវិកាទៅក្នុងគណនីធនាគារ ឬប្រអប់ប្រាក់អេឡិចត្រូនិកជាច្រើនក្នុងពេលតែមួយ (ហៅថាការទូទាត់ជាចង្កោម)។ មុខងារនេះនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលបញ្ចេញ ចែកចាយអត្ថប្រយោជន៍សង្គមបានឆាប់រហ័ស និងមានប្រសិទ្ធភាពទៅដល់ក្នុងគណនីអ្នកទទួលផល។ ការចូលរួមបានទូលាយពីសំណាក់អ្នកផ្តល់សេវាទូទាត់ធនាគារ និងមិនមែនធនាគារ ទៅតាមប្រព័ន្ធទូទាត់ដែលពាក់ព័ន្ធ នឹងបង្កើនជាអតិបរិមាផលប្រយោជន៍នៃការប្រើវិធីសាស្ត្រនេះ។ ការដាក់ដោយឡែកពីគ្នាមិនមានលក្ខណៈជាប្រព័ន្ធនៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូទាត់ជាតិនាបច្ចុប្បន្នអាចរាំងស្ទះការចូលរួមឱ្យបានទូលាយ ដូច្នេះ ធនាគារជាតិគួរតែពិនិត្យឡើងវិញលើរចនាសម្ព័ន្ធទាំងមូលនៃប្រព័ន្ធទូទាត់ជាតិ ជារួម និងជាយុទ្ធសាស្ត្រ។

**អ្នកទទួលផលនៃការទូទាត់ប្រាក់ពីកិច្ចគាំពារសង្គម អាចនឹងទទួលបានជម្រើសពេញលេញពីអ្នកផ្តល់សេវាណាមួយ និងវិធីសាស្ត្រទូទាត់ណាមួយ។** ការធ្វើបែបនេះអាចជំរុញឱ្យទីផ្សារប្រកួតប្រជែង ហើយអាចលើកទឹកចិត្តឱ្យអ្នកផ្តល់សេវាទូទាត់បង្កើតផលិតផលជាក់លាក់ ដើម្បីពង្រីកមូលដ្ឋានអតិថិជនក្នុងចំណោមអ្នកមានប្រាក់ចំណូលទាប។ ឧទាហរណ៍ ក្នុងពេលណាមួយក្នុងអំឡុងពេលនៃ

---

45 BIS និង ធនាគារពិភពលោក ឆ្នាំ 2016។

ការបែងចែកការទូទាត់ប្រាក់ឧបត្ថម្ភកូវីដ 19 តម្រូវការប្រាក់សន្សំមានជាង 10 ភាគរយ[46] ប៉ុន្តែ តម្រូវការនេះមិនត្រូវបានបំពេញដោយផលិតផលណាមួយបាន ដោយសារអ្នកទទួលផលទាំងនោះអាចដកបានតែសាច់ប្រាក់។ ជាដំបូង ដើម្បីធានាឱ្យមានការផ្លាស់ប្តូរដោយរលូន និងចៀសវាងស្ថានភាពដែលនរណាម្នាក់ដែលត្រូវការថវិកាមិនអាចទទួលបានថវិកានោះ ជម្រើសទទួលសាច់ប្រាក់នេះអាចរក្សានៅដដែល។ ទោះយ៉ាងណាក៏ដោយជម្រើសទទួលថវិកាដាក់ក្នុងគណនីណាមួយ គួរតែធ្វើបានជាស្វ័យប្រវត្តិ។

**ការអប់រំហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជនគួរតែជាផ្នែកចាំបាច់ ដែលការកែទម្រង់នេះត្រូវធ្វើ។** ខណៈដែលអតិថិជនថ្មីៗបានប្រើសេវាហិរញ្ញវត្ថុ ដែលមិនធ្លាប់ដឹងពីមុនមក ជាការចាំបាច់ដែលត្រូវអមដំណើរអតិថិជនទាំងនោះនៅក្នុងការប្រតិបត្តិ ដោយយកឱកាសនោះផ្តល់ការអប់រំហិរញ្ញវត្ថុជាមូលដ្ឋានដល់អ្នកទទួលផល។ ការការពារអតិថិជនក្នុងនោះមានទាំងយន្តការគ្រប់គ្រាន់សម្រាប់ដោះស្រាយវិវាទគួរដាក់ឱ្យមានផងដែរ ដើម្បីធានាថា អ្នកទទួលផលនោះអាចដោះស្រាយដោយងាយស្រួលលើបញ្ហាដែលមានក្នុងការប្រើប្រាស់ផ្តល់សេវា។

### កម្មវិធីជំនួយសាច់ប្រាក់រដ្ឋាភិបាលនៅប្រទេសកម្ពុជា ៖ អតិក្រមជាយុទ្ធសាស្ត្រសម្រាប់កែទម្រង់

**បទពិសោធន៍ក្នុងការផ្តល់ការឧបត្ថម្ភជាបន្ទាន់ក្នុងអំឡុងជំងឺរាតត្បាតកូវីដ 19 គឺជាឱកាសមួយសម្រាប់រាជរដ្ឋាភិបាលកែទម្រង់កម្មវិធីទូទាត់ប្រាក់របស់ខ្លួននៅក្នុងការពិនិត្យឡើងវិញចំពោះប្រព័ន្ធផ្តល់អត្ថប្រយោជន៍សង្គមក្នុងប្រទេសទាំងមូល។** ចំនួននៃបុគ្គលដែលទទួលបានការទូទាត់សាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកពីរដ្ឋាភិបាលនៅប្រទេសកម្ពុជា មានអត្រាទាបខ្លាំង ត្រឹមតែ 2.9 ភាគរយ ធៀបទៅនឹង 12.2 ភាគរយនៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិក និង 8.8 ភាគរយនៅប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប[47]។ **ជាជំហានដំបូង រាជរដ្ឋាភិបាលកម្ពុជាគួរធ្វើការសិក្សាស្ថានភាពរួម ដោយកំណត់រាល់លំហូរការទូទាត់ប្រាក់របស់រដ្ឋាភិបាល (រួមទាំងជាឧទាហរណ៍ ប្រាក់បៀវត្សរ៍មន្ត្រីរាជការ អត្ថប្រយោជន៍កិច្ចគាំពារសង្គម ការទូទាត់ពាក់ព័ន្ធនឹងពន្ធដារ ការទូទាត់ទៅមកក្នុងអាជីវកម្ម) និងកំណត់សម្រាប់លំហូរនីមួយៗ និងសម្រាប់ប្រព័ន្ធទាំងមូល ថាតើកន្លែងណាខ្លះចាំបាច់ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិកឱ្យបាន។**

**កម្មវិធីទូទាត់ប្រាក់រដ្ឋាភិបាលគួរគាំទ្រដល់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈសមស្របមានប្រសិទ្ធភាព និងតម្លាភាព។** លើសពីនេះទៀត គួរមានការប្រឹងប្រែងធ្វើទំនើបកម្មកម្មវិធីទូទាត់ប្រាក់នេះ ដើម្បីពន្លឿនការបង្កើតប្រព័ន្ធទូទាត់ជាតិឱ្យបានកាន់តែទូលាយ ព្រមទាំងពង្រីកបរិយាប័ន្នហិរញ្ញវត្ថុ។ កម្មវិធីទាំងនេះគួរតែធានាសុវត្ថិភាព អាចទុកចិត្តបាន និងចំណាយតិច។ លើសពីនេះទៀត ការធ្វើកម្មវិធីទូទាត់នេះឱ្យទៅជាប្រព័ន្ធអេឡិចត្រូនិក គួរតែជាអាទិភាពដោយតម្រូវឱ្យមានវិធីសាស្ត្រស៊ីសង្វាក់គ្នាក្នុងក្របខណ្ឌរដ្ឋាភិបាលទាំងមូល ដើម្បីអនុវត្តកម្មវិធីទាំងនេះបានក្នុងរយៈពេលមធ្យម។

**រដ្ឋាភិបាលអាចធ្វើការងារជាច្រើនដើម្បីគាំទ្រទាំងផ្នែកតម្រូវការ និងផ្គត់ផ្គង់នៃសេវាកម្មនេះទូទាត់ប្រាក់របស់រដ្ឋាភិបាល និងជំរុញតម្រូវការពីសាធារណៈជនចំពោះសេវាកម្មបែបនេះ។** យ៉ាងណាក៏ដោយ ការងារតម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រទូលំទូលាយមួយចំពោះកំណែទម្រង់កម្មវិធីទូទាត់ប្រាក់នេះ និងការសម្របសម្រួលកម្រងសកម្មភាពជាច្រើនដែលត្រូវអនុវត្តលើកិច្ចការមួយចំនួន ដោយសារតែការប្រឈមដែលអាចប៉ះពាល់ដល់ការផ្លាស់ប្តូរទៅជាកម្មវិធីទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថល[48]។ ប្រទេសកាន់តែច្រើនបានអនុវត្តការផ្លាស់ប្តូរទៅជាប្រព័ន្ធឌីជីថលនេះ ប៉ុន្តែនៅក្នុងករណីខ្លះ ដំណើរការនេះបានជួបប្រទះបញ្ហាផ្សេងៗ រួមទាំងប្រព័ន្ធគ្មានប្រសិទ្ធភាព ឬគោលនយោបានមិនគ្រប់គ្រាន់ដែលប៉ះពាល់ដល់ការលើកទឹកចិត្ត ឬសមត្ថភាពចាំបាច់ដើម្បីសម្រេចគោលបំណងដែលចង់បាន។ ការបរាជ័យក្នុងការដោះស្រាយបញ្ហាទាំងនេះអាចធ្វើឱ្យមិនត្រឹមតែពន្យឺតដំណើរការផ្លាស់ប្តូរនេះទេ ប៉ុន្តែថែមទាំងបំផ្លាញទំនុកចិត្តលើផែនការរដ្ឋាភិបាលពីសំណាក់ប្រជាពលរដ្ឋ និងកាត់បន្ថយទំនុកចិត្តសាធារណលើនវានុវត្តន៍លើការទូទាត់ប្រាក់[49]។

**នៅក្នុងរយៈពេលមធ្យម រាជរដ្ឋាភិបាលកម្ពុជាគួរប្តេជ្ញាសម្រេចឱ្យបានលទ្ធផលកម្មវិធីទូទាត់នេះឱ្យបានគុណភាពខ្ពស់បំផុត។** លទ្ធផលនេះរួមមាន ការធានាថា (1) គ្រប់ផ្នែកនៃការអនុវត្តកម្មវិធីនេះ ក្លាយជាប្រព័ន្ធឌីជីថលពីដើមដល់ចប់ និង (2) គ្រប់ការទូទាត់របស់រដ្ឋាភិបាលមកពី និងទៅកាន់គ្រប់បុគ្គល និងអាជីវកម្មទាំងអស់នៅក្នុងប្រទេស ត្រូវតែទៅដល់ភាគីផ្ទាល់តែម្តង[50] ត្រឹមត្រូវចំគោលដៅ តាមពេលវេលាកំណត់ ចំទីតាំង ក្នុងទម្រង់ត្រឹមត្រូវ មានសុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងក្នុងចំនួនត្រឹមត្រូវ ហើយ (3) កម្មវិធីទូទាត់ប្រាក់នេះវិវត្តតាមពេលវេលា ដើម្បីបំពេញតាមតម្រូវការសេដ្ឋកិច្ច និងសង្គម ដែលមានការវត្តិទៅមុខ។ អនុសាស្ត្រខាង

---

46 គ្រួសារចំនួន 10 ភាគរយ ក្នុងការអង្កេតជុំទី 2 និងគ្រួសារចំនួន 11 ភាគរយក្នុងការអង្កេតជុំទី 4 បញ្ជាក់ថា ពួកគាត់ចង់សន្សំប្រាក់មួយចំនួនដែលទទួលបានពីកម្មវិធីនេះ។ ក្នុងការអង្កេតជុំទី 5 ភាគរយនេះបានថយមកត្រឹម 3 ភាគរយ ប្រហែលជាបណ្តាលមកពីបញ្ហានៃជំងឺកូវីដ 19 ក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាចំណុចនេះធ្វើឱ្យការផ្តល់ផលិតផលគ្រប់គ្រាន់មានសារៈសំខាន់ជាង ព្រោះថា គ្រួសារមួយចំនួនអាចសន្សំប្រាក់ក្នុងកញ្ចប់ថវិកាអេឡិចត្រូនិក ពីអត្ថប្រយោជន៍មួយចំនួនដែលទទួលបានក្នុងពេលមានជីវភាពប្រសើរជាងមុន (ប្រភព ៖ ការអង្កេតតាមទូរស័ព្ទស្តីពីជំងឺកូវីដ 19 នៅកម្ពុជា ធនាគារពិភពលោក សហភាពអឺរ៉ុប និងជំនួយអូស្ត្រាលី ឆ្នាំ 2020-2021)។

47 World Bank Global Findex ឆ្នាំ 2017។

48 ចំពោះការពិភាក្សាទូលំទូលាយអំពីបញ្ហាប្រឈមទាំងនេះ និងរបៀបដែលបញ្ហាទាំងនេះត្រូវបានលើកឡើងក្នុងករណីប្រទេសមួយចំនួនដែលត្រូវបានជ្រើសរើស សូមមើល Karandaaz Pakistan (2016)។

49 កម្សោយផ្នែករចនាសម្ព័ន្ធ ដូចជា បណ្តាញតភ្ជាប់មិនគ្រប់គ្រាន់ (ដែលធ្វើឱ្យប្រតិបត្តិការជាច្រើនត្រូវបានកាត់ផ្តាច់ ឬគាំងដំណើរការ) ការមិនអាចធ្វើប្រតិបត្តិការបានរវាងគណនី និងគណនី (ដែលកាត់បន្ថយការទូទាត់ក្នុងសេដ្ឋកិច្ច) ឬកង្វះបណ្តាញដកប្រាក់នៅទូទាំងប្រទេស អាចប៉ះពាល់យ៉ាងខ្លាំងដល់គុណតម្លៃនៃកម្មវិធីទូទាត់ឌីជីថលនេះ។

50 សម្រាប់កម្មវិធីទូទាត់ពីរដ្ឋាភិបាលទៅប្រជាពលរដ្ឋ ភាគីជាបុគ្គល ឬនីតិបុគ្គល។ សម្រាប់កម្មវិធីទូទាត់ពីប្រជាពលរដ្ឋទៅរដ្ឋាភិបាល ភាគីជាស្ថាប័នរដ្ឋាភិបាល។

ក្រោមនេះពន្យល់ពីវិធីសម្រេចទស្សនៈវិស័យនេះដែលចង់បានលទ្ធផលខ្ពស់ តែអាចធ្វើទៅបានអាចនឹងសម្រេចបានដោយរបៀបណានៅក្នុងរយៈពេលមធ្យមនៅប្រទេសកម្ពុជា។

**វិធីសាស្ត្ររួមមួយគួរភ្ជាប់ការផ្លាស់ប្តូរទៅការទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក ទៅនឹងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាតិ និងបរិយាប័ន្នហិរញ្ញវត្ថុ នៅក្នុងបរិបទអភិវឌ្ឍន៍សេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា ។** នេះមានន័យថា នៅពេលកម្ពុជាកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ជាតិរបស់ខ្លួន (ជាពិសេសផ្នែកលក់រាយ) និងធ្វើឱ្យមានបរិយាប័ន្នហិរញ្ញវត្ថុ ការផ្លាស់ប្តូរការទូទាត់សាច់ប្រាក់ទៅជាប្រព័ន្ធអេឡិចត្រូនិក គួរតែជាសសរស្តម្ភសំខាន់ក្នុងការសម្រេចគោលដៅទាំងពីរនេះ[51]។ ដូចគ្នានេះដែរ រដ្ឋាភិបាលគួរតែអនុវត្តការងារប្រកបដោយយុទ្ធសាស្ត្រ និងធ្វើឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនឹងបរិយាប័ន្នហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ជាតិ ដើម្បីធានាឱ្យបាននូវភាពស៊ីសង្វាក់ក្នុងចំណោមផែនការទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល ការកែលម្អប្រព័ន្ធទូទាត់ជាតិ និងបរិយាប័ន្នហិរញ្ញវត្ថុ ក៏ដូចជាដើម្បីប្រើប្រាស់អត្ថប្រយោជន៍នៃការអនុវត្តរួមគ្នាទាំងអស់នេះ។

**ជាគោលការណ៍ ការប្រតិបត្តិការអាជីវកម្មពេញលេញមួយនៃការផ្តល់សេវាកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាលអាចកែប្រែទៅជាប្រព័ន្ធអេឡិចត្រូនិក មិនមែនតែផ្នែកទូទាត់ប៉ុណ្ណោះនោះទេ។** ការធ្វើការទូទាត់ជាប្រព័ន្ធអេឡិចត្រូនិកតែមួយមុខ មិនអាចគ្រប់គ្រាន់ក្នុងការបង្កើតបានប្រសិទ្ធភាពពេញលេញតាមការរំពឹងទុកពីការផ្លាស់ប្តូរទៅជាកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ ដោយសារតែបុគ្គលដែលទទួល ឬទូទាត់ប្រាក់ពី ឬទៅឱ្យរដ្ឋាភិបាល អាចនៅតែត្រូវការចំណាយពេលវេលាដែលមិនចាំបាច់ ក្នុងការដាក់ឯកសារជាក្រដាស (ដូចជា វិញ្ញាប័ណ្ណប័ត្រ ទម្រង់ កំណត់ត្រា) ហើយឱ្យមន្ត្រីរដ្ឋាភិបាលបញ្ជាក់ពីភាពត្រឹមត្រូវទៅលើឯកសារទាំងនោះ។ នៅក្នុងស្ថានភាពបែបនោះ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកមិនអាចលុបបំបាត់ការតម្រូវឱ្យអតិថិជនធ្វើដំណើរទៅកាន់ការិយាល័យរដ្ឋាភិបាល ហើយឈរតម្រង់ជួរយូរ ដែលធ្វើឱ្យបាត់តម្លៃនៃការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ។ ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកតែមួយមុខក៏មិនអាចដោះស្រាយទាំងស្រុងនូវបញ្ហានៃការគ្រប់គ្រង និងការត្រួតពិនិត្យ (ដូចជា ការការពារកុំឱ្យប្រើប្រាស់ថវិកាខុសគោលដៅ ការបន្លំ ឬអំពើពុករលួយ) ដោយសារវាធ្វើឱ្យកែប្រែទិសដៅតាមរយៈភាគីទីបី ឬឧក្រិដ្ឋជន ដែលមិនមានការអនុញ្ញាត អាចកាត់យកផ្នែកខ្លះនៃថវិកាដែលទូទាត់នោះ។ ជាការចាំបាច់បំផុតសម្រាប់សម្រេចបានគោលបំណងជាយុទ្ធសាស្ត្រដូចបានលើកឡើងខាងលើ គឺថាកម្មវិធីទូទាត់ប្រាក់របស់រដ្ឋាភិបាលត្រូវធ្វើ "អេឡិចត្រូនិកពីដើមដល់ចប់" ពោលគឺ ការទូទាត់តម្លៃដែលពាក់ព័ន្ធទាំងអស់គួរតែធ្វើតាមប្រព័ន្ធអេឡិចត្រូនិកពីចំណុចចាប់ផ្តើមដល់ការផ្ទេរប្រាក់ រហូតដល់ការសង និងការទូទាត់ប្រាក់។ ចំណុចនេះតម្រូវជាការធ្វើផ្លាស់ប្តូរទៅជាកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវតែសម្របសម្រួលជាមួយនឹងរបៀបវារៈរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីធានាថាគ្រប់ផ្នែកទាំងអស់នៃការផ្តល់សេវានៃកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល ត្រូវបញ្ចូលរួមទៅក្នុងផែនការផ្លាស់ប្តូរទៅជាកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក។

**រាជរដ្ឋាភិបាលកម្ពុជាគួរប្រើប្រាស់វិធីសាស្ត្រច្បាស់លាស់ចំពោះបច្ចេកវិទ្យា ហើយរៀបចំទិសដៅទៅកាន់កម្មវិធីទូទាត់សាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។** ជាចុងបញ្ចប់ (និងជាការល្អបំផុត) រាល់ភ្នាក់ងារអាជីវកម្ម ឬបុគ្គល គួរតែអាចបង់ ឬទទួលប្រាក់ពីរដ្ឋាភិបាលដោយប្រើវិធីណាក៏បាន តាមរយៈអ្នកផ្តល់សេវាណាដែលខ្លួនពេញចិត្ត ហើយបង់ទៅកាន់ ឬក៏មកពីទីតាំងណាក៏បាននៅទូទាំងប្រទេស។ គួរតែធ្វើឲ្យមានជម្រើសច្រើន (ជាឧបករណ៍ មធ្យោបាយ និងអ្នកផ្តល់សេវា) សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ហើយជម្រើសថ្មីៗដែលកើតមានឡើង ក៏ដូចជាការចង់បានដែលធ្វើឲ្យមានជម្រើសផ្សេងៗ គួរតែជាលទ្ធផលនៃតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារ។ រដ្ឋាភិបាលគួរតែសម្របសម្រួលដំណើរការទីផ្សារនេះ ព្រមទាំងបង្កលក្ខណៈជំរុញឱ្យមានជម្រើសកាន់តែច្រើនតាមតែអាចធ្វើទៅបាន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទដែលត្រូវធ្វើដំណើរប្រាកដប្រជា និងសន្សឹមៗ រដ្ឋាភិបាលយ៉ាងហោចណាស់គួរតែធានាថា គ្រប់ប្រជាពលរដ្ឋ និងអាជីវកម្មទាំងអស់នៅទូទាំងប្រទេសអាចប្រើប្រាស់បានដោយស្រួល យ៉ាងហោចណាស់ក៏មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកជាមូលដ្ឋានណាមួយ (រួមទាំងតាមរយៈជំនួយរបស់ភ្នាក់ងារទូទាត់) សម្រាប់ការបង់ប្រាក់ទៅឱ្យ ឬទទួលប្រាក់ពីរដ្ឋាភិបាល។

**ការអនុវត្តការកែទម្រង់ទ្រង់ទ្រាយធំជាកញ្ចប់ ដែលបានស្នើឡើងនេះ នឹងផ្តល់នូវលទ្ធផលជាច្រើនដែលអាចវាស់វែងបាន និងមានលក្ខណៈជាក់ស្តែង។** លទ្ធផលទាំងនេះរួមមាន (1) កម្រៃសេវាទូទាត់ទាប (2) ការគ្រប់គ្រងថវិកាសាធារណៈមានភាពប្រសើរ (3) កាត់បន្ថយការបាត់បង់ប្រាក់ និងការបាត់ជំនឿទៅលើថវិកាសាធារណៈ និងឯកជន ដែលទុកនៅក្នុងគណនីចម្លង (4) ពេលវេលាកាន់តែតិចទៅលើការប្រតិបត្តិការបែបបទរដ្ឋបាល និងទូទាត់ (5) លុបបំបាត់តម្រូវការទំនាក់ទំនងមួយទល់មួយរវាងកម្មវិធីទូទាត់សាច់ប្រាក់របស់រដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ (6) តាមដាន និងលុបចោលអ្នកទទួលផលដែលមិនពិត និងរាប់ជាន់គ្នា (7) មានការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកកាន់តែច្រើន និង (8) ចំនួនមនុស្សច្រើនដែលទទួលបានតាមហិរញ្ញវត្ថុផ្លូវការ ។

---

51 ដូចបានកត់សម្គាល់ វិធីសាស្ត្រនេះកំពុងត្រូវបានស្នើឡើង ឬអនុម័តដោយក្រុមធនាគារពិភពលោកក្នុងបរិបទនៃសកម្មភាពជំនួយផ្នែកប្រឹក្សា និងជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក។ ជាក់ស្តែង គោលការណ៍ណែនាំទី 10 នៃគោលការណ៍ណែនាំទូទៅរបស់ធនាគារពិភពលោកស្តីពីការបង្កើតកម្មវិធីទូទាត់របស់រដ្ឋាភិបាល ស្នើឡើងថា រដ្ឋាភិបាលគួរ "ទាញប្រយោជន៍ពីកម្មវិធីទូទាត់របស់រដ្ឋាភិបាលដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ៖ ការទូទាត់យ៉ាងច្រើនដែលផ្តល់ដោយរដ្ឋាភិបាល ក៏ដូចជា លក្ខណៈនៃកម្មវិធីជាក់លាក់មួយចំនួន ដូចជា កម្មវិធីចំណាយសង្គម សុទ្ធសឹងជាឱកាសក្នុងការលើកកម្ពស់ ឬសម្របសម្រួលបរិយាប័ន្នហិរញ្ញវត្ថុទ្រង់ទ្រាយធំ"។

# ឧបសម្ព័ន្ធ ៖ សូចនាករសំខាន់ៗ

| សូចនាករសំខាន់ៗ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 E | 2021 F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ច** | | | | | | | | | | | | | | |
| កំណើន ផសស (% ប្រចាំឆ្នាំ) | 6.7 | 0.1 | 6.1 | 7.1 | 7.3 | 7.4 | 7.1 | 7.0 | 6.9 | 7.0 | 7.5 | 7.1 | -3.1 | 4.0 |
| កំណើន ផសស សម្រាប់ប្រជាជនម្នាក់ (% ប្រចាំឆ្នាំ, កំណើនពិត) | 5.1 | -1.4 | 4.5 | 5.4 | 5.6 | 5.6 | 5.4 | 5.3 | 5.3 | 5.4 | 5.9 | 5.5 | -4.4 | 2.6 |
| ផសស សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក, ណូមីណល) | 744.5 | 737.9 | 812.9 | 892 | 950 | 1,028 | 1,100 | 1,175 | 1,270 | 1,381 | 1,506 | 1,640 | 1,519 | 1,609 |
| កំណើនការប្រើប្រាស់ដោយឯកជន (% ប្រចាំឆ្នាំ) | 12.7 | -0.2 | 8.8 | 10.4 | 4.7 | 5.6 | 4.6 | 9.4 | 5.8 | 3.7 | 3.0 | 7.0 | -0.8 | 2.6 |
| ការវិនិយោគសរុប ( % នៃ ផសស ណូមីណល) | 17.3 | 20.1 | 16.2 | 16.0 | 17.4 | 18.7 | 20.9 | 21.4 | 21.7 | 21.9 | 22.6 | 23.4 | 24.6 | 27.6 |
| ការវិនិយោគសរុប - សាធារណៈ ( % នៃ ផសស ណូមីណល)[1] | 6.3 | 8.8 | 9.6 | 10.7 | 9.1 | 9.1 | 8.2 | 6.9 | 6.7 | 6.8 | 6.7 | 7.7 | 11.4 | 10.8 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | | | | | | | | | |
| អតិផរណា, តម្លៃអ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ, មធ្យមភាគតាមអំឡុង ពេល)[2] | 12.3 | 3.1 | 2.6 | 3.4 | 1.4 | 2.2 | 1.2 | 1.8 | 3.5 | 3.3 | 3.1 | 3.2 | 2.9 | 3.0 |
| រូបិយវត្ថុទូលាយ (% នៃ ផសស)[1] | 28.3 | 37.7 | 41.6 | 39.1 | 50.1 | 55.5 | 67.1 | 72.4 | 79.2 | 88.2 | 100.7 | 107.7 | 137.5 | 142.0 |
| ការផ្តល់ឥណទានក្នុងស្រុកដល់វិស័យឯកជន ( % នៃ ផសស)[1] | 23.5 | 24.6 | 27.6 | 28.3 | 38.7 | 52.0 | 62.7 | 74.3 | 81.7 | 86.7 | 99.6 | 114.2 | .. | .. |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយវត្ថុក្នុងស្រុកក្នុង 1 ដុល្លារអាមេរិក) | 4,060.0 | 4,140.0 | 4,044.0 | 4,016.0 | 4,033.0 | 4,027.0 | 4,030.0 | 4,025.0 | 4,058.0 | 4,062.0 | 4,067.0 | 4,070.0 | 4,077.4 | 4,070.0 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (2015=100) | 91.4 | 90.8 | 98.1 | 94.3 | 93.3 | 92.6 | 94.7 | 100.0 | 101.9 | 103.2 | 99.7 | 101.0 | 96.8 | 98.9 |
| **សារពើពន្ធ** | | | | | | | | | | | | | | |
| ប្រាក់ចំណូល (% នៃ ផសស) | 16.4 | 15.9 | 17.7 | 17.6 | 17.7 | 18.2 | 20.0 | 19.7 | 20.9 | 21.9 | 23.8 | 27.0 | 24.1 | 22.7 |
| ចំណាយ (% នៃ ផសស) | 16.1 | 20.5 | 21.0 | 23.0 | 21.9 | 21.4 | 21.9 | 20.2 | 21.1 | 22.7 | 23.4 | 25.5 | 26.8 | 26.0 |
| ការបង់ការប្រាក់ (% នៃ ផសស) | 0.2 | 0.2 | 0.3 | 0.3 | 0.5 | 0.7 | 0.7 | 0.3 | 0.4 | 0.4 | 0.4 | 0.4 | 0.6 | 0.5 |
| ចំណាយមិនមែនការប្រាក់ (% នៃ ផសស) | 15.9 | 20.3 | 20.7 | 22.7 | 21.4 | 20.7 | 21.2 | 19.9 | 20.7 | 22.3 | 23.0 | 25.1 | 29.4 | 29.3 |
| សមតុល្យសារពើពន្ធរួម (% នៃ ផសស) | 0.3 | -4.6 | -3.3 | -5.4 | -4.2 | -3.2 | -1.9 | -0.5 | -0.2 | -0.8 | 0.4 | 1.5 | -2.7 | -3.3 |
| សមតុល្យសារពើពន្ធបឋម (% នៃ ផសស) | 0.5 | -4.4 | -3.0 | -5.1 | -3.7 | -2.5 | -1.2 | -0.2 | 0.2 | -0.4 | 0.8 | 1.9 | -2.1 | -2.8 |
| បំណុលទូទៅរបស់រដ្ឋាភិបាល (% នៃ ផសស) | 27.0 | 28.5 | 28.7 | 29.7 | 31.5 | 31.7 | 31.9 | 31.2 | 29.1 | 30.0 | 28.4 | 28.1 | 34.6 | 35.2 |
| បំណុលសាធារណៈខាងក្រៅ (% នៃ ផសស)[1] | 24.5 | 26.3 | 27.1 | 26.9 | 30.4 | 31.5 | 31.4 | 31.2 | 29.1 | 30.2 | 28.7 | 28.1 | 34.6 | 35.2 |
| **គណនីខាងក្រៅ** | | | | | | | | | | | | | | |
| កំណើនការនាំចេញ, ទំនិញ និងសេវា (ដុល្លារអាមេរិកណូមីណល, % ប្រចាំឆ្នាំ) | 20.2 | -24.4 | 22.9 | 11.4 | 16.0 | 16.8 | 10.3 | 7.5 | 9.0 | 9.4 | 12.3 | 9.5 | -4.0 | 18.9 |
| កំណើនការនាំចូល, ទំនិញ និងសេវា (ដុល្លារអាមេរិកណូមីណល, % ប្រចាំឆ្នាំ) | 11.3 | -17.0 | 19.1 | 11.4 | 14.2 | 16.9 | 8.8 | 7.6 | 9.0 | 7.8 | 9.3 | 9.0 | -3.9 | 23.2 |
| ការនាំចេញទំនិញ (% នៃ ផសស) | 49.4 | 33.9 | 38.3 | 38.8 | 41.6 | 44.6 | 45.4 | 45.4 | 45.5 | 45.2 | 46.0 | 46.0 | 48.2 | 48.8 |
| ការនាំចូលទំនិញ (% នៃ ផសស) | 58.2 | 46.8 | 50.4 | 50.5 | 53.7 | 57.5 | 57.5 | 57.3 | 56.9 | 55.6 | 55.1 | 54.6 | 56.5 | 57.3 |
| សេវា, សរុប (% នៃ ផសស) | 6.5 | 6.2 | 6.8 | 6.3 | 7.3 | 7.8 | 7.7 | 7.5 | 7.0 | 7.0 | 7.4 | 7.2 | 6.8 | 4.2 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិកបច្ចុប្បន្ន) | -622.3 | -1,120.4 | -1,165.3 | -1,309.3 | -1,390.7 | -1,489.3 | -1,899.7 | -1,680.6 | -1,756.6 | -2,140.5 | -2,180.1 | -2,632.5 | -2,525.5 | -2,663.3 |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -6.0 | -10.8 | -10.0 | -10.1 | -9.9 | -9.6 | -11.3 | -9.2 | -8.8 | -9.7 | -8.9 | -9.7 | -9.9 | -9.8 |
| ការវិនិយោគផ្ទាល់ពីបរទេស, លំហូរចូលសរុប (% នៃ ផសស) | 7.6 | 8.8 | 11.9 | 11.6 | 13.9 | 13.0 | 10.5 | 9.5 | 12.0 | 12.1 | 12.6 | 13.2 | 13.7 | 13.8 |
| បំណុលខាងក្រៅ, សរុប (% នៃ ផសស)[1] | 25.5 | 31.7 | 35.6 | 36.2 | 47.9 | 49.9 | 49.7 | 52.2 | 50.2 | 51.5 | 55.0 | 56.6 | .. | .. |
| បំណុលពហុភាគី (% នៃបំណុលខាងក្រៅសរុប)[1] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| ផលធៀបបំណុល-សេវា (% នៃការនាំចេញទំនិញ និងសេវា)1 | 0.8 | 1.0 | 1.1 | 4.0 | 6.0 | 5.7 | 5.4 | 5.1 | 5.1 | 6.2 | 6.7 | 6.9 | .. | .. |
| **ប្រជាជន ការងារ និងភាពក្រីក្រ** | | | | | | | | | | | | | | |
| ប្រជាជន, សរុប (លាននាក់) | 13.9 | 14.1 | 14.3 | 14.5 | 14.8 | 15.0 | 15.3 | 15.5 | 15.8 | 16.0 | 16.2 | 16.5 | 16.7 | 16.9 |
| កំណើនប្រជាជន (% ប្រចាំឆ្នាំ) | 1.5 | 1.5 | 1.6 | 1.6 | 1.6 | 1.7 | 1.7 | 1.6 | 1.6 | 1.5 | 1.5 | 1.5 | 1.4 | 1.4 |
| អត្រានិកម្មភាព[1] | 0.8 | 0.6 | 0.8 | 0.6 | 0.5 | 0.4 | 0.7 | 0.4 | 0.7 | 0.7 | 0.7 | 0.7 | 0.7 | .. |
| វិសមភាព - មេគុណ Gini[1] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អាយុសង្ឃឹមរស់1 | 65.4 | 66.0 | 66.6 | 67.0 | 67.5 | 67.9 | 68.3 | 68.6 | 69.0 | 69.3 | 69.6 | .. | .. | .. |
| **សូចនាករផ្សេងទៀត** | | | | | | | | | | | | | | |
| ផសស (LCU បច្ចុប្បន្ន, លាន) | 41,968,385.0 | 43,056,732.0 | 47,047,985.0 | 52,068,693 | 56,616,800 | 62,219,524 | 67,740,436 | 73,422,702 | 81,241,866 | 89,830,525 | 99,544,275 | 110,014,048 | 103,511,609 | 110,763,826 |
| ផសស (ដុល្លារអាមេរិកបច្ចុប្បន្ន, លាន) | 10,337.0 | 10,400.2 | 11,634.0 | 12,965 | 14,038 | 15,451 | 16,809 | 18,242 | 20,020 | 22,115 | 24,476 | 27,030 | 25,484 | 27,215 |
| ផសស សម្រាប់ប្រជាជនម្នាក់គិតជា LCU (ពិត) | 2,062,211.6 | 2,033,232.3 | 2,124,292.2 | 2,238,619 | 2,363,486 | 2,495,841 | 2,630,660 | 2,769,140 | 2,915,146 | 3,071,748 | 3,252,348 | 3,431,774 | 3,279,153 | 3,365,284 |
| លេខរៀងនៃការធ្វើធុរកិច្ច[3] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | 144 | .. | .. |
| លេខរៀងនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស[4] | 142.0 | 142.0 | 143.0 | 143 | 145 | 144 | 144 | 146 | 146 | 145 | 144 | 144 | .. | .. |
| CPIA (ចំណាត់ថ្នាក់ជារួម)[1] | 3.3 | 3.3 | 3.4 | 3.4 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | .. | .. |
| ការគ្រប់គ្រងសេដ្ឋកិច្ច[1] | 3.8 | 3.8 | 4.0 | 3.8 | 3.8 | 3.8 | 3.8 | 4.0 | 4.0 | 4.0 | 4.2 | 4.2 | .. | .. |
| គោលនយោបាយរចនាសម្ព័ន្ធ[1] | 3.3 | 3.3 | 3.3 | 3.5 | 3.7 | 3.7 | 3.7 | 3.5 | 3.5 | 3.3 | 3.3 | 3.3 | .. | .. |
| គោលនយោបាយបរិយាប័ន្នសង្គម និងសមធម៌[1] | 3.3 | 3.3 | 3.4 | 3.5 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | .. | .. |
| ការគ្រប់គ្រងវិស័យសាធារណៈ និងស្ថាប័ន/គ្រឹះស្ថាន[1] | 2.7 | 2.7 | 2.7 | 2.8 | 2.8 | 2.8 | 2.8 | 2.7 | 2.7 | 2.7 | 2.6 | 2.6 | .. | .. |

*ចំណាំ ៖* “..” មានន័យថា គ្មាន, E = ការប៉ាន់ស្មាន, F = ការព្យាករ, ទិន្នន័យពី MFMOD លុះត្រាតែមានការកត់សម្គាល់ផ្សេងពីនេះ។

1/ មូលដ្ឋានទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោក និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក។

2/ មូលដ្ឋានទិន្នន័យ GEM របស់ធនាគារពិភពលោក; MRV = កម្រិតថ្មីបំផុត។

3/ សូចនាករនេះត្រូវបានកំណត់លេខរៀងក្នុងចំណោម 190 ប្រទេស (ការធ្វើធុរកិច្ចឆ្នាំ 2019)។ ទិន្នន័យត្រូវបានបង្ហាញសម្រាប់ឆ្នាំអង្កេត ជំនួសឱ្យឆ្នាំបោះពុម្ពផ្សាយ។ លេខរៀងនៃការធ្វើធុរកិច្ច ប្រែប្រួលទៅតាមពេលវេលា ដោយសារតែការផ្លាស់ប្តូរវិធីសាស្ត្រ និងគោលនយោបាយ។

4/ លេខរៀងនៃសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សនៅឆ្នាំ 2001 គឺធៀបនឹង 175 ប្រទេស ហើយនៅឆ្នាំ 2010 គឺធៀបនឹង 169 ប្រទេស។ ការកែលម្អវិធីសាស្ត្រសម្រាប់ការគណនាសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សធ្វើឱ្យប្រទេសនានាមានលេខរៀងប្រសើរជាងមុន។

*ប្រភព ៖* មូលដ្ឋានទិន្នន័យ MFMOD, មូលដ្ឋានទិន្នន័យ WDI របស់ធនាគារពិភពលោក និងមូលដ្ឋានទិន្នន័យ GEM, មូលនិធិរូបិយវត្ថុអន្តរជាតិ

# គន្ថនិទ្ទេស

BIS (Bank for International Settlements) and World Bank. 2016. "Payment aspects of financial inclusion." Committee on Payments and Market Infrastructures, Bank for International Settlements and World Bank Group, Washington, DC. http://documents.worldbank.org/curated/en/806481470154477031/Payment-aspects-of-financial-inclusion.

CBRE Cambodia. "2021 Fearless Forecast–Recession or Resurgence." CBR, Cambodia, Phnom Penh. https://images.cbre.com.kh/2021/02/2021_Fearless-Forecast_For-Circulation.pdf.

JoPACC (Jordan Payments & Clearing Company). "Lockdown but Not Shutdown: The Impact of the Covid-19 Pandemic on Financial Services in Jordan." Jordan Payments & Clearing Company (JoPACC), Amman, October.

Karandaaz Pakistan. 2016. *Global Landscape Study on Digitising P2G Payments*. Karandaaz Pakistan, Islamabad Capital Territory, Pakistan. https://www.karandaaz.com.pk/wp-content/uploads/2017/02/Global-Landscape-Study-on-Digitising-P2G-Payments.pdf.

Kehoe, T. J., and K. J. Ruhl. 2003. "How Important Is the New Goods Margin in International Trade?" Federal Reserve Bank of Minneapolis Research Department Staff Report 324. Federal Reserve Bank of Minneapolis, Minneapolis.

Ministry of Agriculture, Fisheries and Forestry. 2020. *Annual Report for Agriculture, Fisheries and Forestry for 2019–20 and Direction for 2020–21*. Ministry of Agriculture, Fisheries and Forestry, Phnom Penh.

———. 2021. *April 2021 Report on Agriculture, Fisheries and Forestry*. Ministry of Agriculture, Fisheries and Forestry, Phnom Penh.

Ministry of Economy and Finance. 2021. *Cambodia Public Debt Statistical Bulletin 11 (March 2021). Ministry of Economy and Finance, Phnom Penh.*

———. *2021. Monthly Government Finance Statistics 2021. Ministry of Economy and Finance, Phnom Penh.*

Ministry of Planning. 2021. *Cambodia National Accounts Statistics for 2020*. National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2021. *Monthly Cambodia Consumer Price Index 2021*. National Institute of Statistics, Ministry of Planning, Phnom Penh.

Ministry of Social Affairs, Veterans and Youth Rehabilitation 2020. *Presentation, Second Meeting on the Results of Cash Transfer Program for the Second Round, October 22, 2020*. Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation.

Ministry of Tourism. 2020. *Annual Tourism Statistics Report*. Phnom Penh: Ministry of Tourism.

———. 2020. "Monthly Tourist Statistics." Phnom Penh: Ministry of Tourism.

Morgan, P. J., and L. Q. Trinh. 2017. "Determinants and Impacts of Financial Literacy in Cambodia and Viet Nam. ADBI Working Paper 754. Asian Development Bank Institute, Tokyo. https://www.adb.org/publications/determinants-and-impacts-financialliteracy-cambodia-and-viet-nam.

National Bank of Cambodia. 2020. *Balance of Payments Statistics (March 2021). National Bank of Cambodia, National Bank of Cambodia.*

———. *2021. Monetary Statistic Bulletin (February 2021). National Bank of Cambodia, Phnom Penh.*

———. *2021. 2020 Annual Report.* Phnom Penh: National Bank of Cambodia, January.

Royal Government of Cambodia. 2020. *Budget settlement laws for 2019*. Royal Government of Cambodia, Phnom Penh.

———. 2021. Budget Law for 2021. Royal Government of Cambodia, Phnom Penh.

———. 2021. *Macro-fiscal framework for the 2022 budget*. Royal Government of Cambodia, Phnom Penh.

Sreymom, Sum, and Khiev Pirom. 2015. "Contract Farming in Cambodia: Different Models, Policy and Practice." CDRI Working Paper Series No. 104, CDRI, Phnom Penh.

World Bank. n.d. World Bank Findex. https://globalfindex.worldbank.org/sites/globalfindex/files/countrybook/Cambodia.pdf.

———. 2017. World Bank Global Findex 2017.

———. 2019. "Payments for the Digital Economy in Cambodia." World Bank, Washington, DC.

———. 2020. *Cambodia Economic Update, November 2020*. World Bank, Washington, DC.

———. 2021a. *Uneven Recovery: East Asia and Pacific Economic Update, April 2021*. Washington, DC: World Bank.

———. 2021a. "Vietnam Macroeconomic Poverty Outlook." World Bank, Washington, DC, April. https://pubdocs.worldbank.org/en/972091563917611616/mpo-vnm.pdf.

———. 2021b. (forthcoming) *June Global Economic Prospects.* Washington, DC: World Bank.

World Bank, European Union, and Australian Aid. 2020–2021. Cambodia COVID-19 High Frequency Phone Survey.


K-STREAM
Hapag-Lloyd


K LINE
MAERSK
SEALAND







ក្រុមធនាគារពិភពលោក

**ធនាគារពិភពលោក**
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
វេបសាយ: www.worldbank.org/cambodia